ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 18-Mar-2015, 16:00
CMS/CFO: Sann Rada

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អង្គជំនុំជម្រះសាលាដំបូង**
Trial Chamber
Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៥**

**ម៉ោង ០៩:០២នាទី**

**សវនាការលើកទី២៥៧**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន
ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*
ចៅក្រម យ៉ា សុខន
ចៅក្រម ហ្សង់ម៉ាក ឡាវែរ៍ន
*(Judge Jean-Marc LAVERGNE)*
ចៅក្រម យូរ ឧត្តរា
ចៅក្រម ធូ មណី (បម្រុង)
ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

កញ្ញា ជា ស៊ីវហ៉ាង
កញ្ញា រ៉ូប៊ីន្នី ក្រូហ្វត៍ *(Ms. Robynne CROFT)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក នីកូឡាស គូមជែន
*(Mr. Nicolas KOUMJIAN)*
លោក សេង ប៊ុនឃាង
កញ្ញា សុង ឆរិន្ត
លោក ស្រ៊ា រតនៈ
លោក ឌេល លីសាក់*(Mr. Dale LYSAK)*
លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

**ជនជាប់ចោទ៖**

លោក នួន ជា
លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ស្ហួន វិសាល

លោក វ៉ិចទ័រ កូប៉េ*(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក អាកទួរ វែកគែន

*(Mr. Arthur VERCKEN)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍

*(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖**

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោក ឡៅ ជុនធី

លោក វ៉េន ពៅ

លោកស្រី ជេត វណ្ណលី

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី ស្វ សុទ្ធារី

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| លោក វាំងសង់ វ៉ាយដ៍ ដេស្ទាងល | បារាំង |
| លោក ស្រ៊ា រតនៈ | ខ្មែរ |
| លោក អាក់ទួរ វែកគែន | បារាំង |
| លោក គង់ សំអុន | ខ្មែរ |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោក នាង អ៊ូច ហៅ តាសាន (2-TCW-803) | ខ្មែរ |
| លោក នុត នួវ (2-TCW-948) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក នាង អ៊ុច ហៅ តាសាន** (2-TCW-803)

សួរដោយលោក អាក់ទូរ វែកគែន ផ្តើមពី ....................................................................ទំព័រ ៣

សួរដោយលោក គង់ សំអុន ផ្តើមពី ..........................................................................ទំព័រ ៩

**ការសួរសំណួរទៅសាក្សី៖ លោក នុត នូច** (2-TCW-948)

សួរដោយប្រធានអង្គជំនុំ ផ្តើមពី ..........................................................................ទំព័រ ២២

សួរដោយលោក ស្រ៊ា រតនះ ផ្តើមពី ..........................................................................ទំព័រ ២៩

សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល ផ្តើមពី .......................................................ទំព័រ ៣៦

# កិច្ចដំណើរការនីតិវិធី

[០៩:០២:២៧]

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយសវនាការនៅថ្ងៃនេះ ព្រឹកនេះ យើងនឹង បន្តស្ដាប់សក្ខីកម្មសាក្សី នាង អ៊ួច បញ្ចប់ ហើយនិងបន្តស្ដាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-948។

ក្រឡាបញ្ជីសវនាការ កញ្ញា ជា ស៊ីវហ៊ាង ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន! សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្ដីនេះមានវត្តមាន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ។ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទ នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ សាក្សីដែលត្រូវមកផ្ដល់សក្ខីកម្មបន្តបញ្ចប់នៅថ្ងៃនេះ គឺលោក នាង អ៊ួច លោកនិងមេធាវីប្រឹក្សាលោក មឿន សុវណ្ណ មានវត្តមានរួចហើយនៅក្នុងបន្ទប់សវនាការនេះ។

នៅថ្ងៃនេះមានសាក្សីបម្រុងមួយរូបដែលមានរហស្សនាម 2-TCW-948 សាក្សីមានៗមេធាវីប្រឹក្សាលោក មឿន សុវណ្ណ។ សូមអរគុណលោកប្រធាន។

[០៩:០៤:០៩]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ កញ្ញា ស៊ីវហ៊ាង។

បាទមុននឹងផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដី លោក ខៀវ សំផន អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនា-ការដោយផ្ទាល់ ក្នុងបន្ទប់សវនាការនេះរបស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៥

ដែលបានបញ្ជាក់ថា គាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្តង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនាថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព គាត់សុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការនៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៥ ដោយគាត់បញ្ជាក់ថាមេធាវីការពារក្តីរបស់គាត់បានប្រាប់អំពីផលប៉ះពាល់នៃការលះបង់សិទ្ធិនេះថា ការលះបង់សិទ្ធិនេះមិនអាចបកស្រាយថា ជាការលះបង់សិទ្ធិរបស់ខ្លួនក្នុងការកាត់សេចក្តីដោយយុត្តិធម៌ ឬក៏សិទ្ធិក្នុងការជំទាស់ទៅនឹងភស្តុតាងក្នុងការដាក់បង្ហាញ ឬដាក់ជូនតុលាការនេះគ្រប់ពេលវេលានៃសវនាការលើរូបខ្លួនឡើយ។

[០៩:០៥:០៧]

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការពិនិត្យព្យាបាលថែទាំព្យាបាលសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៥ បានកត់សម្គាល់ថាស្ថានភាពសុខភាពរបស់លោក នួន ជា មានអាការៈឈឺចង្កេះជាប្រចាំ អង្គុយយូរធឹងធោង និង១បានផ្តល់អនុសាសន៍ថា សូមឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យ នួន ជា នៅតាមដានដំណើរការសវនាការពីបន្ទប់ខាងក្រោមសាលសវនាការនេះ។

ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គ-ជំនុំជម្រះយល់ព្រមនិងអនុញ្ញាតឲ្យលោក នួន ជា នៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។ លោក នួន ជា លះបង់សិទ្ធិចូលរួមក្នុងដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ។

ហើយបង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ ក្នុងអំឡុងពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

បាទ ជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សី នាង អ៊ូច។

**លោក អាកទួរ វែកកែន៖**

សូមអរគុណលោកប្រធាន។

[០៩:០៦:២៤]

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក អាកទូរ វែកគែន៖**

**ស៖** ជម្រាបសួរលោកសាក្សី! ខ្ញុំមានសំណួរតិចតួចទេលោកសាក្សី។ ដូច្នេះ ប្រហែលជាខ្ញុំត្រូវការពេលខ្លីទេ ជាសំណួរសូមឲ្យលោកបញ្ជាក់នូវចម្លើយរបស់លោក។ សំណួរទី១ ពាក់ព័ន្ធទៅនឹងការទំនាក់ទំនងរបស់លោកជាមួយ តារ៉ុន។ ខ្ញុំចង់ឲ្យលោកនិយាយឡើងវិញពីព្រោះថាខ្ញុំគិតថាប្រហែលជាមានបញ្ហាបកប្រែ។ អ៊ីចឹង ខ្ញុំចង់ដឹងថាតើចម្ងាយរវាងផ្ទះលោក ហើយនិងផ្ទះ តារ៉ុនហ្នឹងមានចម្ងាយប្រហែលប៉ុន្មានគីឡូម៉ែត្រដែរ?

**លោក នាង អ៊ួច៖**

**ឆ៖** ផ្ទះខ្ញុំនិងផ្ទះតារ៉ុន ចម្ងាយ៦គីឡូម៉ែត្រ។

**ស៖** លោកបានឆ្លើយថា នៅពេលដែលលោកត្រូវការទៅទទួលបញ្ជាពីតារ៉ុន គឺលោកជិះម៉ូតូក្នុងចម្ងាយ៦គីឡូម៉ែត្រហ្នឹង ដើម្បីទៅទទួលយកការបញ្ជាពី តារ៉ុន។ តើអ៊ីចឹងមែនទេ?

**ឆ៖** អ៊ីចឹងមែន ខ្ញុំជិះម៉ូតូ ជិះតែប្រហែល៥នាទី ១០នាទីអីទេដល់ផ្ទះគាត់ មិនដល់ផង ប៉ុណ្ណឹង។

**ស៖** លោកអាចបញ្ជាក់បានទេថា តើការសម្រេចបែបណាដែរ ដែលតម្រូវឲ្យលោកទៅទទួលការបញ្ជាពីគាត់នោះ? ថាតើ -- ខ្ញុំចង់ថាសេចក្តីសម្រេចប្រភេទណាដែលលោកត្រូវជិះម៉ូតូទៅទទួលការបញ្ជា ឬក៏ការណែនាំពីតារ៉ុននោះ។ មានកម្រិតនៃការសម្រេចហ្នឹងគឺថាសំខាន់ខ្លាំង ឬក៏យ៉ាងម៉េចដែលថាលោកចាំបាច់ត្រូវជិះម៉ូតូទៅទទួលការបញ្ជាពីគាត់នោះ?

[០៩:០៨:៥១]

**ឆ៖** ខ្ញុំៗបានឆ្លើយហើយតើក្នុងរឿងដែលមានកន្លងមកនេះ ក្នុងឯកសារជាច្រើនដែលត្រូវសម្រេចជិះម៉ូតូទៅជួបគាត់ គឺមានឯកសារខាងៗការសម្រេចលើជនជាប់ចោទ។ អ៊ីចឹង មានការរាយការណ៍ពីគ្រប់ទីកន្លែងមក គឺខ្ញុំយកសេចក្តីសម្រេចហ្នឹងយកទៅជូនគាត់សម្រេចភ្លាមៗតែម្តង ព្រោះកន្លែងខ្ញុំនិងកន្លែងគាត់ជិតគ្នា។

**ស៖** ដូច្នេះ តាមចម្លើយរបស់លោក គឺថាអត់មានកម្រិតនៃសារៈសំខាន់ដែលលោកត្រូវទៅទេ អ៊ីចឹងគឺថារាល់សម្រេចទាំងអស់ គឺតារ៉ុនជាអ្នកធ្វើ ហើយឲ្យតែមានការសុំការសម្រេចអីមួយ គឺលោកត្រូវតែជិះម៉ូតូ៦គីឡូម៉ែត្រហ្នឹងទៅជួបគាត់ដើម្បីសុំការណែនាំពីគាត់។ អ៊ីចឹងមែនទេ?

**ឆ៖** បាទ អ៊ីចឹងមែន។

**ស៖** កាលពីប៉ុន្មានថ្ងៃកន្លងមកនេះ លោកក៏បានឆ្លើយផងដែរថា នៅពេលដែលលោកទៅជួប តារ៉ន លោកបង្ហាញរបាយការណ៍ ហើយគាត់ៗជាអ្នកសម្រេច។ ហើយបន្ទាប់មកលោកសរសេរជាលាយលក្ខណ៍អក្សរនូវការសម្រេចរបស់គាត់។ អ៊ីចឹងខ្ញុំចង់ដឹងថា របៀបនៃការដំណើរការហ្នឹងវាយូរទេ? នៅពេលដែលលោកទៅផ្ទះគាត់ ហើយរាយការណ៍ទៅគាត់។ អ៊ីចឹងតើគាត់មានត្រូវការពេលវេលាដើម្បីសម្រេចទេ ឬក៏លោកទៅដល់ភ្លាម គាត់សម្រេចភ្លាម ហើយលោកត្រឡប់មកវិញភ្លាម ឬក៏ តារ៉ន គាត់ត្រូវការពេលមួយយូរដើម្បីគិតហើយសម្រេចលើអ្វីដែលលោកបានរាយការណ៍នោះ?

**ឆ៖** គាត់មានការគិត ការគិត ប្រហែលជាពីរបីម៉ោងអ៊ីចឹងទៅ ហើយបានគាត់សម្រេចឲ្យខ្ញុំសរសេរ។

**ស៖** លោកបានឆ្លើយថា តារ៉ន នៅថ្នាក់តំបន់។ គាត់ជាអ្នកត្រួតពិនិត្យស្រុកត្រាំកក់ផ្ទាល់ តាមរយៈបែបបទដែលលោកទើបតែរៀបរាប់មកនេះ។ អ៊ីចឹងតាមការដឹងរបស់លោកនោះ តើការរៀបចំនៅស្រុកផ្សេងហ្នឹង គេរបៀបដូចគ្នាហ្នឹងស្រុកត្រាំកក់ដែរ អ៊ីចឹងមែនទេ?

**ឆ៖** នៅស្រុកផ្សេងខុសគ្នាពីស្រុកត្រាំកក់ ដោយស្រុកត្រាំកក់ហ្នឹងនៅជាប់នឹងតំបន់។ ស្រុកត្រាំកក់ហ្នឹងគឺយកទីរួមខេត្តហ្នឹងជាស្រុកត្រាំកក់ដែរ ដូចខេត្តកណ្ដាលអ៊ីចឹង ខេត្តកណ្ដាលដែលនៅជាប់ក្រុងភ្នំពេញអ៊ីចឹងវានៅជិតគ្នាអ៊ីចឹង។ អ៊ីចឹងបានថា នៅស្រុកត្រាំកក់គាត់ចុះបានផ្ទាល់ដោយសារស្រុកត្រាំកក់នៅជាប់នឹងទីរួមខេត្ត ទីរួមខេត្តតាកែវ។ ឯស្រុកផ្សេងដែលស្ថិតនៅឆ្ងាយៗ គេមានគណៈស្រុកគេសម្រេចកិច្ចការ គឺថាមានគណៈកម្មាធិការស្រុកត្រឹមត្រូវ។ ប៉ុន្តែនៅស្រុកត្រាំកក់នេះ គាត់សម្រេចចុះក្ដាប់ដោយខ្លួនគាត់ផ្ទាល់។

[០៩:១៣:១៤]

**ស៖** តើលោកដឹងទេ ថាហេតុអីបានជាមានការរៀបចំរបៀបហ្នឹង ដែលពិសេសសម្រាប់តែស្រុកត្រាំកក់របស់លោកមួយហ្នឹង?

**ឆ៖** បញ្ហានេះ ខ្ញុំអត់យល់ដែរ ថ្នាក់លើរៀបរយអ៊ីចឹង។

**ស៖** នៅពេលដែលគេអានរបាយការណ៍ឲ្យលោកស្ដាប់ ហើយលោកទទួលស្គាល់ថាលោកជាអ្នកសរសេរ ហើយគេសរសេរហ្នឹង សរសេរជាមនុស្សទី១ទៀត។ អ៊ីចឹងលោកសរសេរខ្លួនឯង ហើយលោកអត់មានបញ្ជាក់ថា បញ្ហាហ្នឹងមកពី តារ៉ន ទេ ហេតុអីបានជានៅក្នុងរបាយការណ៍ហ្នឹងលោក

សរសេរទៅជាលោកខ្លួនឯងទៅវិញ ម៉េចក៏លោកមិនដាក់ថា អូ! តាមបញ្ជាពី តារ៉ន មកត្រូវសម្រេចបែបនេះៗ?

**ធ៖** ខ្ញុំមិនដឹងវិធីសាស្ត្ររបស់គាត់យ៉ាងណាទេ ខ្ញុំមិនដឹងទេ។ ប៉ុន្តែគាត់ប្រើឲ្យខ្ញុំសរសេរឲ្យខ្ញុំនេះអ៊ីចឹងប្រហែល ខ្ញុំដេកគិតពិចារណាទៅប្រហែលជា គាត់គិតថា វាអាចមានថ្ងៃហ្នឹងៗ។ អ៊ីចឹងហើយគាត់មិនឲ្យខ្លួនគាត់ដែលពាក់ព័ន្ធក្នុងការសរសេរហ្នឹងទេ។ គាត់បញ្ជាឲ្យខ្ញុំសរសេរតាមសម្ដីគាត់ ហើយឲ្យខ្ញុំចុះហត្ថលេខាអ៊ីចឹង។

**ស៖** ក៏ប៉ុន្តែតើ តារ៉ន ហ្នឹង គាត់ប្រាប់ឲ្យលោកសរសេរអ៊ីចឹង ទៅជាលោកខ្លួនឯងផ្ទាល់ ដូចជាលោកវិញទេជាអ្នកបញ្ជានោះ ពីព្រោះថាបញ្ជានោះបញ្ជាចេញពី តារ៉ន ក៏ប៉ុន្តែនៅពេលដែលលោកសរសេរអ៊ីចឹងទៅ ដូចដាក់លោកផ្ទាល់ខ្លួនឯងអ៊ីចឹង ដូចជាលោកអ៊ីចឹងជាអ្នកសរសេរចេញបញ្ជា ជាអ្នកធ្វើសេចក្ដីសម្រេចដោយខ្លួនឯងនោះ។ គាត់ប្រាប់ឲ្យលោកធ្វើអ៊ីចឹងមែនទេ?

**ធ៖** គាត់ប្រាប់ឲ្យខ្ញុំសរសេរតាមសម្ដីគាត់អ៊ីចឹង ហើយឲ្យខ្ញុំសរសេរដោយចុះឈ្មោះខ្ញុំអ៊ីចឹង។ ខ្ញុំមិនមែនប៊ានធ្វើអ្វីខុសពីសម្ដីគាត់បញ្ជាទេ។

[០៩:១៦:១៥]

**ស៖** អ៊ីចឹង ហេតុអីបានជាលោកចុះហត្ថលេខាដោយដាក់ឈ្មោះលោកផ្ទាល់នោះ ដោយមិនដាក់ថាជាការសម្រេចរបស់ តារ៉ន នោះ?

**ធ៖** ខ្ញុំបញ្ជាក់ដដែលៗហើយតើរឿងហ្នឹង ខ្ញុំថាគាត់បញ្ជាឲ្យខ្ញុំសរសេរអ៊ីចឹង ឲ្យខ្ញុំចុះឈ្មោះខ្ញុំ។ ប្រហែលជាគាត់មានអាថ៌កំបាំងអី បានជាគាត់បញ្ជាឲ្យធ្វើអ៊ីចឹង។

**ស៖** អ្នកនៅស្រុកដែលត្រូវទទួលបញ្ជាហ្នឹង តើគាត់ដឹងទេថាបញ្ជាហ្នឹងចេញមកពី តារ៉ន?

**ធ៖** នៅក្នុងស្រុក គេដឹងៗថាបញ្ជាហ្នឹងចេញពីមក តារ៉ន។ ព្រោះខ្ញុំតែងប្រាប់គេថា ខ្ញុំទៅជួប តារ៉ន សិន។ គេយកសេចក្ដីរាយការណ៍អីមក ខ្ញុំថាខ្ញុំទៅជួប តារ៉ន សិន។

**ស៖** តើប្រព័ន្ធដែលលោកត្រូវទៅមក ទៅថ្នាក់តំបន់ហ្នឹង វាដំណើរការរហូតទៅដល់ថ្ងៃណា ខែណា ឆ្នាំណាដែរ?

**ធ៖** ខ្ញុំទៅរហូតដល់ថ្ងៃដែលវៀតណាមវ៉ៃចូលកម្ពុជា។

**ស៖** មានន័យថា រហូតដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ មែនទេ?

**ធ៖** មិនមែនដល់ថ្ងៃទី០៦ហ្នឹងទេ។ ទី០៦ហ្នឹង ទី០៧ វៀតណាមចូលដល់ភ្នំពេញ ដូច្នេះគ្រាន់តែ

កាំភ្លើងធ្លាក់ក្បែរៗទីក្រុងតាកែវ ដកចេញបាត់អស់ហើយ។ មិនមែនៗនេះទេ ដល់តែពេលរត់ -- ពេលរត់ដែលវៀតណាមចូលមកកម្ពុជា។ ដូច្នេះ ខ្ញុំមិនចាំថ្ងៃ ចាំខែច្បាស់ទេ ប៉ុន្តែនៅតាកែវហ្នឹងក៏ ខេត្តតាកែវតាមព្រំដែនជាមួយវៀតណាមហ្នឹង ក៏វៀតណាមវ៉ៃ ហើយវ៉ៃរហូតតាមជួរព្រំដែនហ្នឹង។ ដូច្នេះតែកម្លាំងទ័ពមកកៀកដល់ យើងដកថយអស់ហើយ។ ដូច្នេះថ្ងៃៗវាកៀកៗ ចុងខែធ្នូ ៧៨អីហ្នឹង ១៩៧៨អីហ្នឹងដកថយអស់ហើយ។

[០៩:១៩:៤០]

**ស៖** អ៊ីចឹង គឺថារហូតដល់ចុងខែធ្នូ ឆ្នាំ១៩៧៨នុ៎ង គឺថាលោកនៅបន្តទៅយកបញ្ជាពីគាត់រហូតរហូតដល់ចុងខែធ្នូ ៧៨។ គឺអ៊ីចឹងមែនទេ តាមចម្លើយរបស់លោក?

**ឆ៖** ព្រោះត្រូវៗសួរសាកសួរគាត់ទៅណាមកណា គេចទៅណា ដកទៅណាអី គឺសួរគាត់ជាប់រហូត។

**ស៖** ខ្ញុំនិយាយអំពីការទៅទទួលបញ្ជាពីគាត់ លោកៗនិយាយពីការរត់ ខ្ញុំអត់សួរពីការរត់ទេ។ ខ្ញុំសួរចង់ដឹងថា តើលោកនៅតែបន្តទៅទទួលបញ្ជាពីគាត់រហូតទៅដល់ចុងខែធ្នូ ឆ្នាំ១៩៧៨។ តើអ៊ីចឹងមែនទេ?

**ឆ៖** ខ្ញុំទៅជួបគាត់ដល់ចុងឆ្នាំ៧៨ហ្នឹង ជួបគាត់រឿងទៅណាមកណា ហើយមានបញ្ហាយ៉ាងណាទៀត បញ្ជាឲ្យដកចេញពីឃុំពីស្រុកពីកន្លែងហ្នឹងទៅរកភ្នំរកអីដែលការពារសន្តិសុខផ្ទាល់ៗខ្លួនសិន។ ហ្នឹងមានៗអ៊ីចឹង បាទ។

[០៩:២១:២៨]

**ស៖** សូមអរគុណ។ ឥឡូវនេះ ខ្ញុំប្តូរទៅប្រធានបទផ្សេង។ ខ្ញុំចង់សុំឲ្យលោកពន្យល់បន្ថែមអំពីលោក ពេជ្រ ជឹម។ នៅពេលដែលលោកឆ្លើយទៅនឹងសំណួររបស់លោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍កាលពីម្សិលម្ងៃគឺនៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៥ គឺក្រោយម៉ោង ១៥:០៣:២៩ វិនាទី។ លោកថាលោកស្គាល់ ពេជ្រ ជឹម ហ្នឹងមុនឆ្នាំ៧០ ពីព្រោះថាផ្ទះគាត់ហ្នឹងនៅជិតផ្ទះប្រពន្ធរបស់លោក។ លោកថាគាត់មិនដែលធ្លាប់ធ្វើជាជំនួយការរបស់លោកទេ។ អ៊ីចឹង ខ្ញុំចង់ដឹងថា តើតួនាទីជាលេខាស្រុកនេះ ត្រូវបានកាន់ ដោយ ពេជ្រ ជឹម ដែរឬទេ? អ៊ីចឹង ខ្ញុំចង់ដឹងថាតើលោក ពេជ្រ ជឹម ហ្នឹងគាត់ធ្លាប់មានកាន់តំណែងជាលេខាស្រុកទេ? ហើយបើកាន់ តើកាន់រហូតដល់ឆ្នាំណាដែរ?

**ឆ៖** ឆ្នាំ៧០ លោក ពេជ្រ ជឹម នៅក្នុងស្រុកត្រាំកក់ តែតួនាទីជាលេខាស្រុកគឺឈ្មោះ ខុម

កូនស្រីទី១ របស់តាម៉ុក។ តែលោក ពេជ្រ ជឹម ខ្ញុំមិនដឹងគាត់កាន់តួនាទីអីទេក្នុងស្រុកហ្នឹង តែឈ្មោះ ខុម ស្រីទេដែលកាន់តួនាទីជាលេខាស្រុកត្រាំកក់។ កូនបង្កើតទី១ របស់តាម៉ុក។

**ស៖** អ៊ីចឹង លោកដឹងទេថាតើ ពេជ្រ ជឹម គាត់កាន់មុខងារអ្វីខ្លះក្រោយខែមេសា ឆ្នាំ១៩៧៥ ហ្នឹង?

**ឆ៖** ក្រោយខែមេសា ឆ្នាំ១៩៧៥ កម្ពុជាប្រជាធិបតេយ្យចាត់តាំងគាត់ឲ្យទៅនៅចំការកៅស៊ូ ចំការអណ្ដូង៧ ខេត្តកំពង់ធំ ឬខេត្តកំពង់ចាម ខ្ញុំចាំមិនច្បាស់ទេ។ តែខ្ញុំមិនដឹងតួនាទីគាត់ជាប្រធាន ឬជាស្អីទេ ប៉ុន្តែដឹងថាគាត់ទៅចំការកៅស៊ូ ចំការអណ្ដូង។

**ស៖** តើលោកដឹងទេថា ក្រោយខែមេសា ឆ្នាំ៧៥ នៅពេលណាមួយនោះ ពេជ្រ ជឹម គាត់ធ្វើជាលេខាស្រុកនៅកន្លែងណាមួយក៏ដោយ ខ្ញុំមិនសំដៅទៅលើត្រាំកក់ទេ?

[០៩:២៥:១៨]

**ឆ៖** ខ្ញុំក្រោយថ្ងៃ១៧ មេសា ៧៥ ខ្ញុំអត់ដឹង ពេជ្រ ជឹម ធ្វើការងារខាងស្រុកទេ តែគ្រាន់តែខ្ញុំដឹងថា អង្គការបញ្ជូនគាត់ឲ្យទៅចំការកៅស៊ូ ចំការអណ្ដូង។

**ស៖** មិនអីទេ អ៊ីចឹងខ្ញុំប្ដូរប្រធានបទ។ នេះជាខ្សែសំណួរចុងក្រោយ។ ឥឡូវនេះ ខ្ញុំចង់ត្រឡប់មកសួរលោកអំពីចម្លើយ ដែលលោកបានឆ្លើយនៅពេលដែលលោកត្រូវបានស្ដាប់ចម្លើយនៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤ គឺកំណត់ហេតុស្ដាប់ចម្លើយទី១របស់លោក ឯកសារ E319.1.15 សំណួរចម្លើយ៨៨, ៨៩។ អ្នកស៊ើបអង្កេតបានសួរលោក ខ្ញុំសូមដកស្រង់៖ “តើលោកមានការភ្ញាក់ផ្អើលដែរឬទេ នៅពេលដែលរបបកម្ពុជាប្រជាធិបតេយ្យដួលរលំនៅឆ្នាំ១៩៧៩ ហើយថ្នាក់ដឹកនាំរត់ខ្លួនទៅតាមព្រំដែន និងព័ត៌មានដែលថាប្រជាជនប្រហែលជាងពីរពាន់នាក់ត្រូវបានស្លាប់ -- ២លាននាក់ (សូមទោស)”។ លោកឆ្លើយថា ខ្ញុំសូមដកស្រង់ “ខ្ញុំមិនដែលឮព័ត៌មានទាំងអស់នេះទេ ប៉ុន្តែខ្ញុំដឹងថាមានមនុស្សស្លាប់នៅពេលដែលរត់យួន ដោយមានអ្នកខ្លះស្លាប់ដោយអត់អាហារ អ្នកខ្លះស្លាប់ដោយសារយួនបាញ់សម្លាប់”។ អ្នកស៊ើបអង្កេតសួរលោកទៀតថា៖ “មានកុន មានឯកសារបានបង្ហាញថាមានមនុស្សប្រហែលជាង ២លាននាក់ត្រូវបានស្លាប់ក្នុងរបបខ្មែរក្រហម ប៉ុន្តែរហូតមកដល់ពេលនេះ តើលោកនៅជឿថានៅក្នុងរបបខ្មែរក្រហមអត់មានអ្នកស្លាប់ទេ ឬក៏មានតែអ្នកស្លាប់នៅពេលរត់យួន?” លោកឆ្លើយថា ខ្ញុំសូមដកស្រង់៖ “វាច្រើនពេក យុវជនស្លាប់ច្រើនណាស់នៅពេលដែលវៃជាមួយនិង លន់ នល់ ហើយអាមេរិកាំងទម្លាក់គ្រាប់បែកស្លាប់កប់ផ្អឹងយ៉ាងច្រើន ហើយកន្លែងសពយុវជនខ្លះ ខ្ញុំទៅក៏អត់ឃើញដែរ មិនដឹងគេ

គាស់យកទៅកន្លែងណានោះទេ”។ សូមបញ្ចប់ការដកស្រង់។

ខ្ញុំចង់សួរលោកពាក់ព័ន្ធនឹងឃ្លាចុងក្រោយរបស់លោក ដែលលោកថាសាកសពយុវជនហ្នឹងមិនដឹងគេគាស់យកទៅកន្លែងណាទេ លោកអាចឆ្លើយបញ្ជាក់ទៅលើឃ្លាហ្នឹងបានទេ? លោកនិយាយអំពីអ្វីនៅកន្លែងហ្នឹង នៅពេលដែលលោកនិយាយថាគេគាស់សាកសពនេះ លោកចង់និយាយពីអ្វីនៅត្រង់ចំណុចនេះ?

[០៩:២៨:២៧]

**ឆ៖** នៅក្នុងសង្គ្រាមរវាងកម្ពុជាប្រជាធិបតេយ្យរវាងនឹងសាធារណរដ្ឋលន់នល់ យុទ្ធជនកងទ័ពរបស់កម្ពុជាប្រជាធិបតេយ្យហ្នឹង គឺស្លាប់ច្រើន ហើយសាកសពរបស់យុទ្ធជនហ្នឹង មានកប់នៅតាមកន្លែងវិមានសព ហៅថា “វិមានសព”។ ដូចខ្ញុំស្គាល់ គឺនៅស្រុកកោះអណ្តែតកប់នៅភូមិដូងខ្ពស់ ឃុំអង្គខ្នុរ ហើយនៅស្រុកត្រាំកក់ វិមានសពនៅអង្គរកា។ សព្វថ្ងៃនេះគឺផ្សារអង្គរកា។ ហើយវិមានសពទាំងអស់នេះនៅភូមិដូចខ្ពស់ ឃុំអង្គខ្នុរនេះក៏បាត់អស់ សាកសពហ្នឹងបាត់អស់ វាទៅជាកន្លែងសង់ផ្ទះសង់សម្បែងរបស់ប្រជាជនទៅវិញ។ ហើយនៅខាងអង្គរកានេះ វិមានសពនេះក៏បាត់អស់ដែរ ផ្ទះនេះក៏បាត់អស់ដែរ វាទៅជាកន្លែងមន្ទីរពេទ្យ មណ្ឌលសុខភាព។ នៅកន្លែងហ្នឹងទៅជាមណ្ឌលសុខភាពទៅវិញ។ អ៊ីចឹងបានខ្ញុំមិនដឹងថា មិនដឹងថាយ៉ាងម៉េចទេ ព្រោះខ្ញុំទៅឃើញជាក់ស្តែងអ៊ីចឹង។

**សៈ** ហេតុអ្វីបានជា -- ពេលនុ៎ងលោកមិននិយាយលម្អិតបែបហ្នឹងទៅឲ្យអ្នកស៊ើបអង្កេត នៅពេលដែលអ្នកស៊ើបអង្កេតសួរលោកអំពីការដឹងឮអំពីចំនួនជនរងគ្រោះនៃរបបកម្ពុជាប្រជាធិបតេយ្យ? ហេតុអីបានជានៅពេលនុ៎ងហើយទើបតែលោកនិយាយអំពីការគាស់សាកសពហ្នឹង? អ៊ីចឹងខ្លឹមសារហ្នឹងវាមានន័យយ៉ាងម៉េចដែរ នៅពេលដែលលោកផ្តល់ព័ត៏មានលម្អិតអ៊ីចឹងទៅអ្នកស៊ើបអង្កេតនោះ?

**ឆ៖** ចំនួនមនុស្សស្លាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យហ្នឹង ខ្ញុំមិនអាចបានដឹងអស់ទេ ព្រោះវាគ្មានៗវិទ្យុណាដែលផ្សាយ គ្មានព័ត៏មានអីក្រៅពីនៅកន្លែងយើង យើងដឹង កន្លែងគេ គេដឹង យើងមានបានដឹងព័ត៏មានកន្លែងដទៃឯណា អត់ដឹងទេ។ ហ្នឹងសូមលោកជ្រាប។ អ៊ីចឹងហើយបាននិយាយអំពីឃើញ ខ្ញុំឃើញវិញ គឺថាពេលរត់យួន ឃើញសពប្រជាជនស្លាប់ច្រើនណាស់តាមភ្នំ ហើយនិងខ្ញុំនិយាយថាឃើញកន្លែងវិមានសពវាបាត់អស់ សាកសពដែលយុទ្ធជនច្បាំងជាមួយនឹង លន់ នល់ ច្បាំងជាមួយអាមេរិកាំងវាបាត់ ដូចនៅដូងខ្ពស់ ដូចនៅអង្គរកា។ ដូច្នេះ ការបាត់សាកសពទាំងអស់នេះទៅ ខ្ញុំមិនដឹងថាវាបាត់បងដោយរបៀបណា ឬក៏ម៉ែឪគេមកគាស់យកទៅធ្វើបុណ្យ ឬយ៉ាងណា ខ្ញុំមិនដឹងទេ។ ប៉ុន្តែខ្ញុំ

ទៅនេះ ក្រោយពេលដែលកម្ពុជាប្រជាធិបតេយ្យនេះ កងទ័ពខ្មែរក្រហមធ្វើសមាហរណកម្មជាមួយនឹងកម្លាំងកងទ័ពរដ្ឋាភិបាលបច្ចុប្បន្ននេះ។ ឆ្នាំ៩៩–១៩៩៩ ឆ្នាំ២000អី ដែលខ្ញុំបានទៅភូមិកំណើតខាងត្រពាំងធំតាម ឆ្លងកាត់តាមអង្គរកា ហើយខ្ញុំទៅលេងនៅស្រុកកោះអណ្តែតតាមផ្លូវលេខ០១ ពីខាងត្បូងភ្នំខ្ពែងទៅកំពង់អំពិល។ ដូច្នេះ វិមានសពដូងខ្ពស់ហ្នឹងនៅជាប់ពីខាងត្បូងផ្លូវហ្នឹង។ អ៊ីចឹងទៅឃើញអត់មាន។

[០៩:៣២:៤៨]

**ស៖** កាលពីម្សិលមិញ នៅពេលដែលលោកឆ្លើយទៅនឹងសំណួររបស់លោកមេធាវី វ៉ិចទ័រ កូប៉េ លោកបានបញ្ជាក់ថាលោកមិនចង់ឆ្លើយអ្វីច្រើនពាក់ព័ន្ធនឹងវៀតណាមទេ ដើម្បីធានាសន្តិសុខរបស់លោក។ អ៊ីចឹងខ្ញុំចង់ដឹងថាតើលោកយល់ព្រមឆ្លើយសំណួរពាក់ព័ន្ធនឹងប្រធានបទហ្នឹងទេ ប្រសិនបើគេធ្វើសវនាការជាអសាធារណៈនោះ?

**ឆ៖** ខ្ញុំ -- និយាយទៅខ្ញុំមិនចង់ឆ្លើយក្នុងរឿងហ្នឹងដើម្បីសេចក្តីសុខរបស់ខ្ញុំ។ នៅជាប់ៗផ្ទះខ្ញុំខាងប៉ៃលិនក៏ជនជាតិវៀតណាមមួយគំនរ ដូច្នេះខ្ញុំខ្លាច។ នៅខាងសំឡូតក៏មាន ន៎ធ្វើសវនាការអសា-ធារណៈហ្នឹងក៏ខ្ញុំមិនចង់បាននិយាយអីទេ។ ខ្ញុំសូមមិននិយាយរឿងហ្នឹង។

**លោក អាកឡូវ វែកគែន៖**

ខ្ញុំអស់សំណួរហើយលោកប្រធាន។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី គង់ សំអុន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ សូមគោរពអង្គជំនុំជម្រះ អង្គសវនាការទាំងមូល។ សូមជម្រាបសួរលោកសាក្សីផងដែរ។

[០៩:៣៤:៥២]

**សួរដោយលោក គង់ សំអុន៖**

**ស៖** ខ្ញុំសូមត្រឡប់លោកទៅពីសម័យកាលឆ្នាំ១៩៧០ ទាក់ទងទៅនឹងចម្លើយរបស់លោកប៉ុន្មានថ្ងៃមុនថាលោកធ្លាប់ជាសមាជិករណសិរ្សរបស់ស្រុក។ ខ្ញុំចង់ឲ្យលោកជួយបញ្ជាក់ថាក្នុងនាមជាសមាជិករណសិរ្សនោះលោកមានតួនាទីធ្វើអ្វីខ្លះដែរក្នុងពេលនោះ?

**លោក នាង អ៊ួច៖**

**ឆ៖** ពេលនោះខ្ញុំមានតួនាទីឃោសនា ផ្សព្វផ្សាយឲ្យប្រជាជនស្រឡាញ់រណសិរ្សរួបរួមជាតិកម្ពុជា ឲ្យដើរតាមនយោបាយរណសិរ្សរួបរួមជាតិកម្ពុជាដែលមានសម្ដេចឪ គាត់ធ្វើប្រធានរណសិរ្សរួបរួមជាតិកម្ពុជានេះ។

**ស៖** លោកដឹងពីបេសកកម្មរបស់រណសិរ្សរួបរួមជាតិកម្ពុជាហ្នឹងដើម្បីអ្វីទេ?

**ឆ៖** គោលបំណងនៃរណសិរ្សរួបរួមកម្ពុជាដើម្បីធ្វើការតស៊ូ ប្រឆាំងនឹងសាធារណរដ្ឋលន់ នល់ ហើយដើម្បីយកសម្ដេចឪចូលមកក្នុងប្រទេសវិញ។ ខ្ញុំដឹងប៉ុណ្ណឹង។

**ស៖** បាទ ចុះលោកអាចបង្ហាញពីភាពខុសគ្នា នៅ -- រវាងរណសិរ្សរួបរួមជាតិកម្ពុជា ជាមួយនឹងបក្សដែលជាបក្សកុម្មុយនីស្ដកម្ពុជាហ្នឹង?

[០៩:៣៧:១៣]

**ឆ៖** ខ្ញុំមិនដឹងភាពខុសគ្នាយ៉ាងម៉េចទេ ប៉ុន្តែដំបូងឡើយ ឆ្នាំ៧០មកហ្នឹង គឺថាឆ្នាំ៧០ ពេលដែលមានរដ្ឋប្រហារហើយ មានជារណសិរ្សរួបរួមជាតិកម្ពុជា ហើយបានបន្ទាប់មក មិនចាំជាឆ្នាំណាទេ បានមានផ្សព្វផ្សាយអំពីថាបក្សកុម្មុយនីស្ដកម្ពុជា។ តែគោលនយោបាយយ៉ាងណាៗ ខ្ញុំអត់បានយល់ថាវាខុសគ្នាប៉ុនណា អីប៉ុនណាទេ ប៉ុនខ្ញុំដឹងអីចឹង។ ដឹងដំបូងឡើយ រណសិរ្សរួបរួមជាតិកម្ពុជា ហើយបន្ទាប់មកបានផ្សព្វផ្សាយពីបក្សកុម្មុយនីស្ដកម្ពុជា។

**ស៖** បាទសូមអរគុណ។ នៅក្នុងមូលដ្ឋានស្រុករបស់លោកហ្នឹងមានរចនាសម្ព័ន្ធដឹកនាំដោយឡែកពីគ្នាទេ រវាងរណសិរ្សរួបរួមជាតិកម្ពុជា ហើយនិងបក្សកុម្មុយនីស្ដកម្ពុជា?

**ឆ៖** ខ្ញុំៗមិនច្បាស់ទេ ប៉ុន្តែខ្ញុំមានតួនាទីត្រឹមឃោសនា ផ្សព្វផ្សាយនយោបាយរបស់រណសិរ្សរួបរួមជាតិកម្ពុជា។ ឯនារីខុម, តាគារ គាត់ខាងកសាងកម្លាំងបក្សអីខ្ញុំអត់បានដឹងទេ គាត់ធ្វើការងារផ្សេងអីចឹង។ ប៉ុន្តែឲ្យដឹងថារចនាសម្ព័ន្ធខុសគ្នាយ៉ាងណា ខ្ញុំក៏អត់ដឹងដែរ។ ហើយបន្ទាប់មកក៏ខ្ញុំត្រូវដកចេញពីហ្នឹង ដោយតាស៊ី ដែលខ្ញុំបានបញ្ជាក់កន្លងរួចហើយហ្នឹង។

**ស៖** បាទ លោកដឹងថារណសិរ្សរួបរួមជាតិកម្ពុជាហ្នឹង ត្រូវបញ្ចប់នៅពេលណាទេ? ក្រោយពីលោកចេញទៅបញ្ចប់តែម្ដង ឬក៏មានអ្នកដែលបន្តវេនការងារហ្នឹងដែរ?

[០៩:៣៩:៣៤]

**ឆ៖** ខ្ញុំអត់បានដឹងថាចប់នៅពេលណាទេ។ ខ្ញុំចេញទៅ ហើយខ្ញុំវិលមកវិញហ្នឹងក៏អត់បានដឹង

ថាចប់នៅពេលណាដែរ ខ្ញុំដេកឈឺ៦ខែ ឈឺគ្រុន។

**ស៖** បាទ សូមអរគុណ។ ខ្ញុំសូមពិភាក្សាបន្ថែមទាក់ទងទៅនឹងតួនាទីរបស់លោក។ លោកបានបញ្ជាក់រួចហើយថាលោកមានឋានៈជាជំនួយការស្រុក ហើយអាចថាពីរៗស្រុក ហើយលោកមិនដែលធ្វើជាគណៈស្រុកទេ។ ខ្ញុំចង់ឲ្យលោកបញ្ជាក់ថា ការងារសម្របសម្រួលរបស់លោកក្នុងឋានៈជាជំនួយការស្រុកនុ៎ង លោកធ្វើការជាមួយអ្នកណាខ្លះ?

**ឆ៖** លោកសួរខ្ញុំពីរស្រុក។ ដូច្នេះនៅកោះអណ្តែត ខ្ញុំជួយការងាររបស់ តាសៀង និងតាចាន់។ គាត់ត្រូវការឲ្យខ្ញុំចុះទៅការដ្ឋាន ខ្ញុំចុះទៅការដ្ឋាន។ គាត់ត្រូវការឲ្យខ្ញុំទៅមើលអី ខ្ញុំទៅតាមការបញ្ជាការណែនាំរបស់គាត់។ ហើយមកស្រុកត្រាំកក់ ខ្ញុំត្រូវការជួយតាៗគិត ជួយតាគិត ហើយនិងតាចាយ។ គាត់ឲ្យខ្ញុំទៅធ្វើប្រឡាយ ទៅការដ្ឋានទំនប់ ទៅការដ្ឋានធ្វើស្រែ ខ្ញុំទៅតាមការងារដែលគាត់ឲ្យខ្ញុំទៅជួយហ្នឹង។

[០៩:៤១:៥៥]

**ស៖** បាទ ខ្ញុំសួរលោកបញ្ជាក់ពីការសម្របសម្រួលហ្នឹង គឺខ្ញុំចង់សំដៅទៅលើកន្លែងធ្វើការ ឬក៏កម្មាភិបាលដែលមានឋានៈប្រហាក់ប្រហែលលោក ដែលលោកបានបញ្ជាក់អម្បាញ់មិញទាក់ទងទៅនឹងការដ្ឋាន។ អ៊ីចឹងអ្នកណាដែលនៅការដ្ឋានហ្នឹង ក្នុងឋានៈជាអ្វីដែលលោកត្រូវធ្វើការជាមួយគេហ្នឹង។ លោកអាចបញ្ជាក់បានទេ?

**ឆ៖** នៅការដ្ឋានធ្វើទំនប់ ធ្វើប្រឡាយនេះ គឺមានតែប្រធានកងចល័ត។ ប្រធានកងចល័តស្រុក ប្រធានកងចល័តយុវជន យុវនារីតាមឃុំ។ ដូច្នេះ ខ្ញុំសម្របសម្រួលជាមួយប្រធានកងចល័តស្រុក ប្រធានកងចល័តឃុំ ធ្វើការប្រជុំជាមួយគ្នា។ ឥឡូវនេះ ផែនការស្រុកត្រូវធ្វើអ៊ីចេះ! ត្រូវធ្វើប្រឡាយ ដូចថាពីៗផ្លូវលោក ពីទំនប់ផ្លូវលោកកាត់ខាងកើតវត្តទួលសង្កែមកត្រពាំងអណ្តើកអ៊ីចឹងទៅ ពិគ្រោះពិភាក្សាគ្នាត្រូវធ្វើពីណាទៅណាមុន ហើយប្រឡាយផ្សេងៗទៀតក៏ធ្វើដូចគ្នាអ៊ីចឹង ពិគ្រោះពិភាក្សាគ្នាចែកកម្លាំងៗវាស់វែងទៅ វាស់វែង ឃុំណាត្រូវបានប៉ុន្មានម៉ែត្រៗ ជាការងារបច្ចេកទេសជួយសម្រួលការងារអ៊ីចឹង។

**ស៖** បាទ សូមអរគុណ។ លោកបានបញ្ជាក់ពីការសម្របសម្រួលជាមួយយុវជនស្រុក ឬកងចល័តស្រុក។ ខ្ញុំចង់ដឹងថា ការសម្របសម្រួលនេះក្នុងន័យស្មើភាពគ្នា ឬមួយក៏មានអ្នកថ្នាក់ទាប អ្នកថ្នាក់ខ្ពស់រវាងមេកងចល័ត ហើយនិងលោក មួយណាមានឋានៈខ្ពស់ជាង?

[០៩:៤៤:១៥]

**ឆ៖** កិច្ចការហ្នឹង យើងប្រជុំគ្នាអ៊ីចឹងទៅ ហើយថ្នាក់ទាបថ្នាក់ខ្ពស់ដូចជាខ្ញុំ -- ក្នុងពាក្យនេះ ខ្ញុំមិនយល់ទេ ហេតុតែថាបើប្រគល់ឲ្យគេដាច់ដោយឡែកហ្នឹង វាជជែកគ្នាចង់បានដីត្រង់នេះស្រួល ដីត្រង់នោះមិនស្រួលអ៊ីចឹងទៅ ហើយយើងៗៗប្រជុំ យើងអាកាត់អ៊ីចេះអ៊ីចុះអ៊ីចឹង វាមានការសម្រេចជាៗសមូហភាពអ៊ីចេះ។ អ៊ីចឹង រឿងថ្នាក់ទាបថ្នាក់ខ្ពស់ ខ្ញុំគ្រាន់តែសម្របសម្រួលរបៀបហ្នឹងទេ។ ត្រូវវាស់ដាក់ឲ្យឃុំនេះមុន ឃុំនោះក្រោយ ឃុំនោះបន្ទាប់។ អ៊ីចឹង។

**ស៖** បើចុះក្នុងការអនុវត្តជាក់ស្ដែង នៅពេលដែលមានទំនាស់ ឧទាហរណ៍ថាឃុំមួយទារកន្លែងមួយដែលជាស្ថានភាពដីស្រួល ហើយលោក ឃុំដទៃទៀតនោះក៏ចង់បានកន្លែងដីស្រួលអ៊ីចឹងដែរ តើលោកមានការធ្វើការសម្រេចទេ ក្នុងករណីបែបអ៊ីចឹង លោកមានជួបប្រទះទេ?

**ឆ៖** ខ្ញុំអត់មានជួបប្រទះទេ។ តែថាសម្រេចក្នុងអង្គប្រជុំសម្រេចយ៉ាងម៉េចហើយ អ្នកនេះទី១ ឃុំនេះទី១ ឃុំនោះទី២ ឃុំនោះទី៣ អ៊ីចឹងទៅគឺវាស់តាមហ្នឹងអត់មានប្រកែកប្រណាំងអីគ្នាទេ អត់មានទាស់ទែងទំនាស់អីទេ ទារដីស្រួល ដីមិនស្រួលអីអត់ទេ អត់មានជួបប្រទះទេរឿងហ្នឹង។

**ស៖** លោកអាចបញ្ជាក់បានទេថា អ្នកណាជាគណៈអធិបតីក្នុងការបើកអង្គប្រជុំ ឬក៏ការប្រជុំពិភាក្សាគ្នាហ្នឹង?

[០៩:៤៦:៣០]

**ឆ៖** កងចល័តទាំងមូលគឺខាងប្រធានកងចល័ត ហៅកងចល័តតាមឃុំមកមូលគ្នាហើយ គេបើកអង្គប្រជុំទៅ ហើយខ្ញុំចូលរួមស្ដាប់ជាមួយគេ។ អ៊ីចឹង មិនមានថា ហ្អេ! ខ្ញុំទៅបើកអង្គប្រជុំអី មិនទេ។ ខាងកងចល័តគេ គេបើកអង្គប្រជុំខ្លួនគេ គេហៅប្រធានកងចល័តតាមឃុំមកប្រជុំ។ ពេលខ្លះ ខ្ញុំអត់នៅក៏គេធ្វើកើតដែរ គេធ្វើការប្រជុំការដោះស្រាយគ្នាគេហ្នឹងទៅ។ មិនមែនបានន័យថាខ្ញុំនៅចិតថេររហូតមួយថ្ងៃ មួយខែទល់មួយខែទេ អត់ទេ។ ឬថាកន្លែងខ្លះដែលឆ្ងាយ ខ្ញុំវិលមកដេកផ្ទះវិញ ដូចការដ្ឋានជីកប្រឡាយពីទំនប់ផ្លូវលោក កាត់ខាងកើតវត្តទួលសង្កែហ្នឹង វាដីប្រហែលជា២០គីឡូជាងពីខ្ញុំ ពីលាយបូរទៅ ២០ ទៅ ៣០ ហើយខ្ញុំត្រូវវិលត្រឡប់មកដេកផ្ទះខ្ញុំវិញ។ ដូច្នេះ ការងារដោះស្រាយនៅក្នុងការដ្ឋានហ្នឹងលើប្រធានកងចល័តស្រុកអ៊ីចឹងទៅ។ ហើយពេលណាខ្ញុំទៅប៉ះគេប្រជុំគ្នាអ៊ីចឹងទៅ ខ្ញុំចូលរួមស្ដាប់គេអ៊ីចឹងទៅ។

**ស៖** លោកអាចវាយតម្លៃបានទេថា រយៈពេលប៉ុន្មានម៉ោងក្នុង១ថ្ងៃដែលលោកត្រូវចំណាយក្នុងការដ្ឋាន? តាមបទពិសោធន៍ក្នុងការងាររបស់លោកជាក់ស្ដែង?

**ឆ៖** ខ្ញុំចំណាយពេលតាំងពីព្រឹកដល់ល្ងាចបានវិលត្រឡប់មកផ្ទះ។ បាយថ្ងៃត្រង់ជាមួយនឹងកងចល័ត។ ឯនៅបឹងអង្គរបូរី នៅបឹងព្រៃកណ្តៅត្រង់លិច ខ្ញុំនៅដេកជាមួយគេរាប់ៗខែនៅហ្នឹងតែម្តង។

**ស៖** ចុះមានករណីប្រធានកងចល័តឃុំ ឬក៏ស្រុក ប្រធានយុវជនស្រុក ពេលត្រូវការឈប់សម្រាកអីចឹងគេមានសុំការអនុញ្ញាតពីអ្នកណាដែរ?

**ឆ៖** ពេលឈប់សម្រាកយ៉ាងម៉េច? ព្រោះពេលវេលាធ្វើការគេកំណត់ម៉ោងប្រាំពីរចូលការដ្ឋានម៉ោងដប់មួយ សម្រាក។ ម៉ោងមួយចាប់ធ្វើការវិញ ម៉ោងបួនកន្លះទៅម៉ោងប្រាំ សម្រាក។ មានសុំច្បាប់ពីណា? អាហ្នឹងគឺគេកំណត់ច្បាស់លាស់ក្នុងអង្គភាពហ្នឹង។

[០៩:៥០:០៥]

**ស៖** ខ្ញុំចង់និយាយអំពីការងាររបស់កងចល័ត។ ឧទាហរណ៍ គណៈកងចល័តស្រុក ឬក៏ឃុំនៅពេលដែលមានធុរៈ មានការចាំបាច់ ឬក៏ត្រូវមានជំងឺ ត្រូវសម្រាកព្យាបាល តើគេត្រូវសុំការអនុញ្ញាតពីអ្នកណា?

**ឆ៖** បញ្ហានេះ ដូចជាមិនមានការសុំការអនុញ្ញាតអីទេ។ ដូចថា ឈឺៗ ឃើញជាក់ស្តែងឈឺទៅហើយ គេសម្រាកនៅកន្លែងហ្នឹង ឬថាធ្ងន់ កម្លាំងយុវជគេនាំគ្នាយកទៅពេទ្យទៅអីចឹងទៅ។ ដូចជាមិនមានការសុំច្បាប់សុំអីទេ។ ការជាក់ស្តែងវាអីចឹង។

**ស៖** បាទ ទាក់ទងទៅនឹងការគ្រប់គ្រងឃុំ ក្នុងនាមលោកជាជំនួយការស្រុក តើលោកមានទំនាក់ទំនងដូចម្តេចខ្លះជាមួយគណៈឃុំនីមួយៗក្នុងស្រុករបស់លោក?

**ឆ៖** សំណួរនេះ ខ្ញុំអត់យល់។

**ស៖** ក្នុងលោក លោកបានឆ្លើយបញ្ជាក់ជាច្រើនដងហើយថាលោកជាជំនួយការស្រុក។ ខ្ញុំចង់ដឹងថាក្នុងឋានៈលោកជាជំនួយការស្រុកនេះ លោកមានទំនាក់ទំនងអ្វីជាមួយនឹងគណៈឃុំដែរទេ ឃុំទាំងឡាយដែលស្ថិតនៅក្នុងស្រុករបស់លោក?

[០៩:៥២:២០]

**ឆ៖** ខ្ញុំមានទំនាក់ទំនងជាមួយខាងឃុំដែលមានន័ ឧទាហរណ៍ថា តាចាយ ឬតាគិត គាត់ឲ្យទៅជួបខាងឃុំនោះ។ ខ្ញុំនាំពាក្យ តាចាយ តាគិត ទៅពិភាក្សាជាមួយឃុំហ្នឹងទៅ ខ្ញុំទៅជួបឃុំហ្នឹងទៅ។ ហ្នឹងមានការទាក់ទងអីចឹង។

**ស៖** លោកអាចបែងចែកជាប្រភេទការងារបានទេ ថាការងារអីខ្លះដែលលោកមានទំនាក់ទំនង

ជាមួយនឹងឃុំ?

**ឆ៖** ការងារទំនាក់ទំនងជាមួយឃុំ ដូចថាខាងការងារការដ្ឋាន ខាងការងារសេដ្ឋកិច្ច ខាងការងារដោះស្រាយស្បៀង – ដោះស្រាយស្បៀងអី ដូចថា ខាងស្រុកត្រូវការស្បៀងផ្តល់ៗដល់កម្លាំងកងចល័តស្រុក។ អ៊ីចឹងត្រូវការប្រាប់ឃុំនេះ យកប៉ុណ្ណេះទៅ យកប៉ុណ្ណោះទៅ។ ហ្នឹងជាកិច្ចការដែលយើងប្រាស្រ័យទាក់ទងជាមួយតាមឃុំ។

**ស៖** ចុះទាក់ទងអាបញ្ហាសន្តិសុខ លោកមានការងារទាក់ទងនឹងបញ្ហានេះទេ?

**ឆ៖** ខ្ញុំសុំពិគ្រោះជាមួយមេធាវី។

**ស៖** សូមអញ្ជើញ។

**ប្រធានអង្គជំនុំ៖**

សាក្សីឆ្លើយតប។

**លោក នាង អ៊ូច៖**

**ឆ៖** ការងារខាងសន្តិសុខនេះគឺនៅលើកម្លាំងខាងកងឈ្លបស្រុក និងកងឈ្លបឃុំ។

[០៩:៥៦:២២]

**សួរដោយលោក គង់ សំអុន៖**

**ស៖** បាទ ទាក់ទងនឹងការងារសន្តិសុខនេះ លោកមានទំនាក់ទំនងក្នុងនាមជាជំនួយការស្រុកហ្នឹង ទាក់ទងផ្ទាល់ជាមួយនឹងឈ្លបឃុំហ្នឹងដែរទេ?

**ឆ៖** ខ្ញុំមិនបានទាក់ទងជាមួយឈ្លបឃុំទេ។

**ស៖** ចុះខាងណា ឬក៏អ្នកណាដែលជាអ្នកមានទំនាក់ទំនងហ្នឹងមកលោកផ្ទាល់?

**ឆ៖** ខាងឃុំគឺមានការទំនាក់ទំនងមកខ្ញុំ មកតាចាយ មកតាគិតអ៊ីចឹងទៅ ហើយតាចាយ តាគិតអីគឺឲ្យលិខិត ឲ្យសេចក្តីរាយការណ៍ពីឃុំមកខ្ញុំ ខ្ញុំយកសេចក្តីរាយការណ៍នេះទៅជូន តារ៉ន។

**ស៖** បាទ អ៊ីចឹង ខ្ញុំចង់បញ្ជាក់ឲ្យច្បាស់ខាងការងារសន្តិសុខ គឺលោកបានមានទំនាក់ទំនងតាមរយៈឃុំ ហើយបានលោកហ្នឹងបន្តទៅ តាគិត ឬ តារ៉ន ទៀត។ អ៊ីចឹងមែនទេ?

**ឆ៖** ការងារខាងសន្តិសុខហ្នឹងគឺខាងឃុំគេយកមករាយការណ៍ជូនគណៈស្រុក ដូចជា តាគិត ឬតាចាយ ហើយបានគាត់បន្តឲ្យខ្ញុំទៅជួប តារ៉ន តាប៊ិត ព្រោះតាគិតហ្នឹងគាត់មានសុខភាពទ្រុឌទ្រោមគាត់របេង។ តាចាយហ្នឹងក៏គាត់ចាស់ មិនសូវជិះម៉ូតូកើតទេ ឯទីកន្លែងរស់នៅរបស់គាត់នៅជើងភ្នំ

ដំរីរមៀលឯណោះ ហៅឈ្មោះហៅថា "ចំការសៀង"។ គិតពីចំការសៀង ទៅតាកែវវាចូល ៣០គីឡូ។ ដូច្នេះ វាមានតែខ្ញុំទេដែលនៅជិត តារ៉ន តាប៊ិត។

[០៩:៥៩:១៥]

**ស៖** បាទ ខ្ញុំ តាមខ្ញុំស្តាប់យល់អំមិញ គឺពេលដែលគេបញ្ជូនព័ត៌មានពីបញ្ហាសន្តិសុខ ឬក៏រាយ-ការណ៍ពីបញ្ហាសន្តិសុខ គេអត់បានរាយការណ៍ទៅលោកទេ គេរាយការណ៍ទៅ តាគិត ឬ តារ៉ន ផ្ទាល់ពីឃុំទៅ។ ហើយបាន -- សុំទោស តាទិត្យ និងតាចាយ -- តាគិត ហើយនិងតាចាយ បាទ។ ហើយនៅពេលដែលមានការសម្រេចពី តាគិត និង តាចាយ បែបណានោះ បានគេផ្តល់ព័ត៌មានហ្នឹងមកលោកឲ្យធ្វើសេចក្តីសម្រេច ហើយបញ្ជូនមកឃុំវិញ។ ខ្ញុំយល់អ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** អត់ត្រឹមត្រូវទេ ព្រោះន៎ខ្ញុំបញ្ជាក់ហើយ តាគិត សុខភាពគាត់ឈឺ តាចាយនៅឆ្ងាយ។ គាត់ទទួលព័ត៌មានហ្នឹងហើយ គាត់ប្រើខ្ញុំឲ្យទៅជួប តារ៉ន យកព័ត៌មានហ្នឹងទៅឲ្យ តារ៉ន។ ហើយ តារ៉នសម្រេចយ៉ាងម៉េច ឲ្យខ្ញុំសរសេរតាមការសម្រេចរបស់ តារ៉ន ហ្នឹងមកវិញ។

**ស៖** បាទ សូមអរគុណ។ ទាក់ទងទៅនឹងអាការអនុវត្តនូវសេចក្តីសម្រេច។ លោកមានព័ត៌មានរបាយការណ៍ ឬក៏ការតាមដានណាមួយទាក់ទងទៅនឹងការអនុវត្តសេចក្តីសម្រេច ដែលលោកបានធ្វើ ឬក៏ទទួលបញ្ជាពី តារ៉ន មកដែរឬទេ?

**ឆ៖** ការសម្រេចទាំងអស់ហ្នឹង គឺថាខ្ញុំទទួលបញ្ជាពី តារ៉ន។

[១០:០១:៣៧]

**ស៖** ខ្ញុំយល់ពីការទទួលបញ្ជា ប៉ុន្តែខ្ញុំចង់សួរបន្ថែមទៅលើការតាមដានទៅលើការអនុវត្តបញ្ជា ឬក៏អនុវត្តសេចក្តីសម្រេច។ តើមានវិធានការ ឬក៏បែបបទក្នុងការតាមដានការអនុវត្តសេចក្តីសម្រេចដែរទេ?

**ឆ៖** ខ្លួនខ្ញុំផ្ទាល់ ខ្ញុំអត់បានតាមដាន អត់បានតាមដានទេ។

**ស៖** បាទ សូមអរគុណ។ ទាក់ទងទៅនឹងបញ្ហាសេដ្ឋកិច្ចដែលលោកបានបញ្ជាក់ថាជាការងារមួយរបស់លោកជួបជាមួយនឹងឃុំ។ ខ្ញុំចង់ឲ្យលោកបញ្ជាក់ថា តើបញ្ហាអ្វីខ្លះដែលជាការងារសេដ្ឋកិច្ចដែលលោកបានធ្វើជាមួយនឹងថ្នាក់ឃុំ?

**ឆ៖** ការងារសេដ្ឋកិច្ចដែលខ្ញុំបានធ្វើជាមួយថ្នាក់ឃុំ គឺថានាំៗពាក្យពី តាគិត ឬក៏ តាចាយ ទៅប្រាប់ឃុំថា ន៎កងចល័តចុះទៅការដ្ឋាននេះ ឃុំនេះត្រូវការអង្ករ ត្រូវការម្ហូបជាមាន់ ជាជ្រូក ត្រូវការ

បន្លែ។ ដូច្នេះសុំឲ្យខាងឃុំហ្នឹងដឹកជញ្ជូនយកទៅឲ្យ គឺថាការដ្ឋាននេះវាត្រូវការប្រញាប់ ខ្វះខាតបន្ទាន់។ បាទ ខ្ញុំមានការទាក់ទងជាមួយឃុំ តាមរបៀបសេដ្ឋកិច្ច គឺអ៊ីចឹង។

**សៈ** មានករណីសំណើឆ្លងឃុំ ពីឃុំមួយទៅឃុំមួយ។ ឧទាហរណ៍ថាឃុំណាមួយខ្វះសម្ភារៈអ្វីមួយហើយមានការស្នើសុំទៅថ្នាក់លើតាមរយៈលោកដែរទេ ហើយលោកមានដឹងពីការងារដែលថាក្នុងឃុំហ្នឹងមានការសម្របសម្រួលចំពោះការខ្វះខាត រវាងពីឃុំមួយទៅឃុំមួយដែរទេ?

**ឆៈ** ខ្ញុំៗមិនបានជួបប្រទះពីឃុំមួយទៅឃុំមួយ សុំជួយផ្តល់ខាងសេដ្ឋកិច្ច ខាងអីអ៊ីចឹង គឺខ្ញុំមិនៗដែលបានជួបប្រទះរឿងថា ឃុំស្នើទៅឃុំនោះអត់ទេ។ កាលណាឃុំខ្វះខាតអីអ៊ីចឹង គេស្នើទៅ តាគិត ឬក៏តាចាយ។

[១០:០៥:២៥]

**សៈ** ប៉ុន្តែសម្រាប់លោកផ្ទាល់ធ្លាប់មានបទពិសោធន៍នៃការទទួល ឬក៏អនុវត្តនូវសំណើបែបហ្នឹងទេ?

**ឆៈ** ខ្ញុំអត់ទេ។

**សៈ** ទាក់ទងនឹងបញ្ហាឃុំនេះដែរ បញ្ហាសេដ្ឋកិច្ច ខាងស្រុកមានផែនការសម្រាប់ឲ្យឃុំរៀបចំសេដ្ឋកិច្ចរបស់ឃុំនីមួយៗបែបណាដែរទេ?

**ឆៈ** បញ្ហាសេដ្ឋកិច្ចនេះ គឺក្នុងការប្រជុំស្រុកម្តងៗ តាគិត តាចាយ អីតែងតែរៀបចំផែនការឲ្យតាមឃុំនីមួយៗខិតខំធ្វើការ ខិតខំដោះស្រាយដោះស្បៀង ខិតខំបង្កបង្កើនផលឲ្យបានច្រើន ហើយបើថាស្រូវវាអត់គ្រប់គ្រាន់ទេ គឺធ្វើចម្ការតាមជើងភ្នំដំរីរមៀល ចម្ការដំឡូង ចម្ការអីៗហ្នឹង ហៅថា ដាំណាំរួមផ្សំៗ ជើងភ្នំហ្នឹងមកជួយជាបន្លែជាស្អីហ្នឹង។ គេមានគម្រោងផែនការ មានផែនការនៅតាមអង្គប្រជុំស្រុកម្តងៗ។

[១០:០៧:២៩]

**សៈ** ក្នុងតួនាទីរបស់លោកជាជំនួយការស្រុក លោកមានបានធ្លាប់ទទួលសំណើ ឬក៏នៅស្រុករបស់លោកមានទទួលសំណើអំពីការខ្វះខាតស្បៀងពីថ្នាក់ឃុំ ឬក៏ពីក្រុមការងារ កងការងារណាមួយដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ស្រុកដែរទេ ហើយលោកដោះស្រាយដូចម្តេចប្រសិនបើមាន?

**ឆៈ** ខ្ញុំបានបញ្ជាក់ហើយកិច្ចការទាំងអស់នេះ គឺឆ្លងតាមការប្រជុំរួមៗ នៅក្នុងស្រុកហ្នឹង គឺគណៈកម្មាធិការស្រុក តាចាយ តាគិត អីគាត់អញ្ជើញពីគ្រប់ឃុំមកប្រជុំ ហើយរួមគ្នាដោះស្រាយ គឺ

ដោះស្រាយនៅពេលដែលប្រជុំហ្នឹង។

**ស៖** ប្រជុំៗញឹកញាប់ទេ ពីបញ្ហាស្បៀងហ្នឹង?

**ឆ៖** ប្រជុំ ការងារប្រជុំនៅក្នុងស្រុកដោយអញ្ជើញគ្រប់ឃុំ គណៈឃុំមកចូលរួមនេះ គឺប្រជុំរៀងរាល់ខែ។ ១ខែម្ដងៗអ៊ីចឹង។

**ស៖** ការប្រជុំហ្នឹង ដឹកនាំដោយអ្នកណាដែរ លោកអាចបញ្ជាក់បានទេ?

**ឆ៖** អង្គាល់ដែល តាគិត នៅគាត់ធ្វើប្រធានអង្គប្រជុំ ដឹកនាំដោយតាគិត ហើយតាចាយ។ តាចាយនៅ តាគិតចេញទៅ តាចាយគាត់ធ្វើប្រធានអង្គប្រជុំ។

[១០:០៩:៤៧]

**ស៖** បាទ សូមអរគុណ។ សម្រាប់លោកផ្ទាល់ លោកធ្លាប់ជាតំណាងឲ្យ តាគិត តាចាយ ឬក្នុងនាមខ្លួនលោកផ្ទាល់ធ្វើជាប្រធានអង្គប្រជុំដែរទេ?

**ឆ៖** ខ្ញុំៗអត់ទេ។

**ស៖** បាទ មុននេះ ព្រឹកមិញហ្នឹងលោកឆ្លើយថា លោកធ្វើការជាមួយ តារ៉ន រហូតដល់ពេលបែក ពេលដែលរត់ យួនចូល។ ខ្ញុំចង់ឲ្យលោកបញ្ជាក់ថា តារ៉ន គាត់នៅធ្វើការជាប្រធានតំបន់រហូត ឬមួយក៏មានការផ្លាស់ប្ដូរដែរនៅពេលចុងក្រោយ? លោកអាចបញ្ជាក់បានទេ?

**ឆ៖** តាមខ្ញុំចាំ តារ៉ន គាត់ធ្វើការរហូតដល់ដំណាក់កាលចុងក្រោយដែលវៀតណាមចូលមក។

**ស៖** តើលោកមានដឹងថាមានការផ្លាស់ប្ដូរប្រធានតំបន់១៣ ចុង -- នៅដំណាក់កាលចុងក្រោយដែរទេ? នៅពេលណាមួយ?

**ឆ៖** ខ្ញុំឃើញ បងប្រាក់ មកមុនតារ៉ន។ បងប្រាក់មកបាន១ខែ ២ខែមិនដឹងទេ ខ្ញុំមិនចាំទេ ហើយក៏ឃើញ តារ៉ន មករហូតដល់ព្រឹត្តការណ៍ដែលកងទ័ពវៀតណាមចូលមកកម្ពុជា ជាមួយ សំ ប៊ិត។

**ស៖** លោកមានចូលរួមប្រជុំជាមួយនឹងថ្នាក់ឃុំ ដោយប្រកាសពីប្រធានតំបន់ថ្មីដែរទេ? ក្នុង -- អាចថាជាឆ្នាំចុងក្រោយ ៧៨ ក្នុងឆ្នាំ៧៨ ជាដើម?

**ឆ៖** ខ្ញុំមិនដែលបានប្រកាស ប្រធានតំបន់អីទេ ប៉ុន្តែគេដឹង គេស្គាល់ទាំងអស់គ្នា ខាងឃុំគេស្គាល់គេដឹង ខ្ញុំមានបានប្រកាសទេ ព្រោះគាត់ចុះជាប់នៅក្នុងស្រុកត្រាំកក់អ៊ីចឹង គាត់ៗអញ្ជើញទៅតាមឃុំតាមអី មានម៉ូតូដឹកគាត់អ៊ីចឹងទៅ។

**ស៖** ក្រោយ-- សំណួរចុងក្រោយរបស់ខ្ញុំទាក់ទងទៅនឹង តាម៉ុក។ ដោយសារលោកធ្លាប់ស្គាល់

តាម៉ុក ហើយជាអ្នកមានសាច់ញាតិជាមួយគាត់ទៀត លោកអាចបញ្ជាក់អំពីលក្ខណៈនៃការដឹកនាំរបស់តាម៉ុក បានយ៉ាងដូចម្ដេចដែរក្នុងរយៈពេលកន្លងមក ក្នុងឋានៈ តាម៉ុក ជាប្រធានភូមិភាគនិរតី?

**ឆ៖** ខ្ញុំៗពិបាកយល់អំពីបញ្ហានេះ ការដឹកនាំរបស់គាត់ ឃើញគាត់ -- និយាយទៅគាត់ៗដើរចូលច្រើនការដ្ឋាន។ គាត់ចុះតាមភូមិតាមឃុំ ដោយគាត់ធ្វើដំណើរអីចឹងទៅៗៗគ្រប់ច្រកល្ហកច្រើនដែរ។ ហើយដូចនៅទំនប់ខាងអង្គរបូរីអី គឺគាត់ចុះជាប់រៀងរហូត។ ហើយការដឹកនាំរបស់គាត់ និយាយទៅគាត់ទូលំទូលាយ។ ទូលំទូលាយហ្នឹងចង់និយាយថាការស្នើអីៗ ដែលគាត់មានគឺគាត់ឲ្យ គាត់ប្រគល់ឲ្យជាកំណាត់ ជាសម្លៀកបំពាក់ ឬក៏ជាគ្រឿងចក្រអីៗ ត្រូវការដូចថាត្រាក់ទ័រទៅនេះទៅនោះអី ទៅភ្ជួរស្រែឯនេះ ភ្ជួរស្រែឯនោះអី គឺស្នើបានទូលំទូលាយ។ ជាក់ស្ដែង ដូចខ្ញុំនៅកាលនៅស្រុកកោះអណ្ដែត គោបញ្ជាន់ស្រូវព្រោះ ហើយបញ្ជាន់ទៅវាដាច់ស្នូងវាអស់ទៅ វានៅសល់៩០លានទៀតដែលត្រូវបញ្ជាន់ មានខាងៗឃុំអីគាត់នាំពាក្យមក តាចាន់ គាត់ជិះម៉ូតូមកស្នើ តាម៉ុក សុំយកត្រាក់ទ័រទៅបញ្ជាន់ស្រូវ គាត់ឲ្យទៅភ្លាម។ ដូច្នេះខ្ញុំឃើញការដឹកនាំរបស់គាត់ទូលំទូលាយ។

[១០:១៦:៤៤]

**ស៖** ទូលំទូលាយដែលលោកនិយាយអម្បាញ់មិញនេះ តើអាចបញ្ជាក់បានទេថាវាជាការងារដែលតាម៉ុកធ្វើ សូម្បីតែរឿងតូចតាចក៏គាត់ធ្វើដែរ ដូចជាករណីដែលលោកមានប្រសាសន៍អំមិញពីរឿងបញ្ជាន់ស្រូវរឿងអីជាដើមហ្នឹង។ តើលោកអាចបញ្ជាក់ពីការចូលរួមរបស់តាម៉ុក ជាមួយនឹងការសម្រេចចិត្តទៅលើបញ្ហាពីថ្នាក់ ពីបញ្ហាធំៗមកបញ្ហាតូចៗហ្នឹងបានដោយយ៉ាងម៉េចដែរ? លោកអាចផ្ដល់ពីការយល់ឃើញតាមបទពិសោធន៍របស់លោកដែលលោកបានស្គាល់តាម៉ុកហ្នឹង?

**ឆ៖** ខ្ញុំមិនដឹងជម្រាបជូនលោកយ៉ាងម៉េចទេហ្នឹង ខ្ញុំមិនយល់ការងារធំៗរបស់គាត់ ខ្ញុំអត់ដឹងទេ ដូចជាការងារៗកំណត់ថាការងារធំៗ ដូចជាការងារយោធា បទបញ្ជាដាក់ទៅកម្លាំងទ័ព ការពារព្រំដែនយ៉ាងម៉េច ខ្ញុំអត់បានដឹងទេ ក៏ប៉ុន្តែការងារជាក់ស្ដែងនៅតាមមូលដ្ឋានដូចជាទំនប់ប្រឡាយ ដោះស្រាយជីវភាពជូនប្រជាជនអី គឺខ្ញុំបានឃើញគាត់ដុតដៃដុតជើងក្នុងការដោះស្រាយទាំងអស់ហ្នឹង។

**ប្រធានអង្គជំនុំ៖**

លោកមេធាវីនៅប៉ុន្មានសំណួរទៀត ពេលវេលាដូចជាច្រើនហើយ។ លើសដល់ជិត ១០មីនុតហើយណា!

**លោក គង់ សំអុន៖**

សល់មួយសំណួរទៀត លោកប្រធាន។

**សួរដោយលោក គង់ សំអុន៖**

**ស៖** សំណួរចុងក្រោយទាក់ទងនឹងតាម៉ុកនេះ យើងឃើញនូវពាក្យមួយដែលគេច្រើននិយាយថា "នៅលើតាម៉ុកមានមួក នៅលើមួកមានមេឃ" លោកធ្លាប់ឮពាក្យនេះទេ? ហើយលោកអាចធ្វើការបកស្រាយបានដូចម្ដេចដែរចំពោះពាក្យនេះបាទ?

[១០:១៩:០៨]

**លោក នាង អ៊ួច៖**

**ឆ៖** ខ្ញុំឮតាមរយៈអ្នកដែលគេមើលទូរទស្សន៍ ឬក៏ស្ដាប់វិទ្យុ ឬក៏មើលកាសែតអីហ្នឹង គឺក្នុងពេលដែល តាម៉ុក រដ្ឋាភិបាលនាំមកនៅកន្លែងទួលស្លែងនេះ ស្ដាប់ឮនៅពេលហ្នឹង។ គាត់ថា៖ "នៅលើក្បាលម៉ុកមានមួក នៅលើមួកមានមេឃ"។ ដូច្នេះន័យហ្នឹងវាបកស្រាយទៅគឺថា មានតែគាត់ទេដែលនៅលើផែនដីនេះគឺមានតែគាត់ទេ មានតែលើគាត់ទៀតមានតែមួកហើយនិងមេឃទេ មានតែគាត់ទេដែលខ្ពស់ជាងគេ។ ហ្នឹងចង់បកស្រាយថាអ៊ីចឹង ខ្ញុំតាមការយល់របស់ខ្ញុំទេ ប៉ុន្តែអស់លោកមិនដឹងយល់យ៉ាងណា ខ្ញុំមិនដឹង។

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោក។ សូមអរគុណលោកប្រធាន។ ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះសូមអរគុណចំពោះលោក នាង អ៊ួច ដែលបានចំណាយពេលវេលាដ៏មានតម្លៃមកផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះក្នុងរយៈពេល ៣ថ្ងៃកន្លះកន្លងមកនេះ ក្នុងឋានៈជាសាក្សី។ ហើយសក្ខីកម្មរបស់លោកនឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតនៅក្នុងរឿងក្ដីនេះ។ ការផ្ដល់សក្ខីកម្មរបស់លោកបានដល់ទីបញ្ចប់ហើយ ហើយវត្តមានរបស់លោកនៅអ.វ.ត.កនេះ លែងមានភាពចាំបាច់ទៀតហើយ។ លោកអាចវិលត្រឡប់ទៅកាន់លំនៅដ្ឋានរបស់លោក ឬក៏គោលដៅណាដែលលោកមានបំណងចង់ទៅវិញបានហើយ។ សូមលោកធ្វើដំណើរត្រឡប់ទៅវិញប្រកបដោយសុវត្ថិភាព។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញជូនលោក នាង អ៊ួច វិលត្រឡប់ទៅកាន់ទីលំនៅរបស់គាត់ ឬក៏គោលដៅណាដែលគាត់មានបំណងចង់

ទៅបានហើយ។ ហើយអរគុណ ចំពោះមេធាវីប្រឹក្សាសាក្សី។

បាទ ឥឡូវនេះដល់ពេលសម្រាកហើយ។ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះ តទៅរហូតដល់ម៉ោងដប់មួយខ្វះម្ភៃនាទីសូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយសវនាការជាបន្តអង្គជំនុំជម្រះនឹងផ្តើមស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-448 ហើយដែលមានមេធាវីប្រឹក្សាសាក្សីគឺលោក មឿន សុវណ្ណ ដដែល។

សម្រាកចុះ!

**ប្រធានអង្គជំនុំ៖**

អាយ.ធី បើកក្បាលមីក្រូហ្វូនឲ្យសាក្សីនិយាយ គាត់ស្នើសុំនិយាយចុងក្រោយប៉ុន្មានម៉ាត់។

**លោក នាង អ៊ួច៖**

ខ្ញុំសូមអរគុណចំពោះលោកប្រធានអង្គសវនាការ។ អរគុណចំពោះព្រះរាជអាជ្ញា។ អរគុណចំពោះលោកមេធាវីទាំងអស់។ ខ្ញុំមកនេះគឺថាខ្ញុំបានទទួលរាយការណ៍ពីចម្ការរបស់ខ្ញុំ ចម្ការរបស់ខ្ញុំ ន៉ែចម្ការធូរេន ១៧០ដើម។ ខ្ញុំមកនេះគ្មានអ្នកណាថែទាំទេ។ ហើយតាមសេចក្តីរាយការណ៍តាមទូរស័ព្ទមកថាចម្ការខ្ញុំនេះ ធូរេនដែលក្តិបប៉ុនៗមេដៃមេជើងហើយ គ្មានខ្ញុំថែទាំគឺជ្រុះអស់១៥ដើម។ ដូច្នេះ សូមលោកប្រធានជ្រាបការខូចខាតនេះ តើលោកប្រធាននឹងអង្គសវនាការដោះស្រាយចំពោះខ្ញុំយ៉ាងណា?

[១០:២២:៥៣]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណហើយ យើងខ្ញុំនឹងពិគ្រោះជាមួយខាងអង្គភាព វី.ស៊ូ ហើយនិងជូនដំណឹងជម្រាបជូនសាក្សីជាក្រោយណ៎ា។

**លោក នាង អ៊ួច៖**

បាទៗ។

**ប្រធានអង្គជំនុំ៖**

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:២៣ នាទី ដល់ម៉ោង ១០:៤៣ នាទី)*

[១០:៤៣:៣៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយមុននឹងកោះហៅសាក្សី TCW-948 ចូលមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ អង្គជំនុំជម្រះផ្តល់ភារៈជូនទៅលោកស្រីចៅក្រម ក្លូឌា ហ្វេនស៍ ដើម្បីសួរបញ្ជាក់ ទៅលោកមេធាវី វ៉ិចទ័រ កូប៉េ ពាក់ព័ន្ធនឹងសំណើសុំរបស់លោកមេធាវីដែលបានធ្វើកាលពីថ្ងៃមុន។ សូមឱ្យអង្គជំនុំជម្រះចុះទៅពិនិត្យមើលទីតាំងនៃកន្លែងសម្លាប់មនុស្សដែលជាអង្គហេតុចោទប្រកាន់ក្រាំងតាចាន់។

សូមអញ្ជើញលោកស្រី ក្លូឌា ហ្វេនស៍!

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

សូមអរគុណលោកប្រធាន។ ដូចដែលលោកប្រធានបានបញ្ជាក់រួចទៅហើយ នេះគឺជាសំណើសុំចុះពិនិត្យទីតាំងនៅក្រាំងតាចាន់។ យើងបានកត់សម្គាល់ឃើញថា សំណើហ្នឹងគឺមានសំអាងហេតុដែលលើកឡើងជាទូទៅ ព្រោះថាវាជាការលើកឡើងបន្តផ្ទាល់ ហើយភាគីដទៃទៀតបានជំទាស់។ ឥឡូវនេះអង្គជំនុំជម្រះបានពិនិត្យមើលទៅលើរបាយការណ៍កំណត់ទីតាំង គឺឯកសារមានលេខ E3/5828 ហើយយើងបន្ទាប់ពីពិនិត្យមើលរបាយការណ៍ហើយ យើងបានស្នើទៅមេធាវីការពារក្តីឱ្យធ្វើការបញ្ជាក់ថាតើមានព័ត៌មានអ្វីទៀត ដែលអាចទទួលបានពីការចុះទៅមើលផ្ទាល់នៅទីតាំងនោះ។

[១០:៤៥:២៤]

គឺថាតើការដែលចុះទៅមើលផ្ទាល់នោះ វាមានប្រយោជន៍អ្វីលើសពីការអានរបាយការណ៍។ ហើយយើងបានផ្តល់ពេលវេលាដល់មេធាវីការពារក្តីដើម្បីមើលរបាយការណ៍កំណត់ទីតាំង ដែលយើងរំពឹងថានឹងមានការបញ្ជាក់ឱ្យដឹងច្បាស់ថាតើអ្វីពី -- អ្វីជាផលប្រយោជន៍នៃការចុះទៅមើលផ្ទាល់ជាជាងគ្រាន់តែអានរបាយការណ៍។ គឺថាយើងនឹងផ្តល់ពេលវេលារហូតទៅដល់សម្រាកអាហារថ្ងៃត្រង់ ដើម្បីឱ្យមេធាវីការពារក្តីបានពិនិត្យមើលទៅលើរបាយការណ៍កំណត់អត្តសញ្ញាណទីតាំង។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកចៅក្រម ហ្វេនស៍។

បាទ ជាបន្តនេះ អង្គជំនុំជម្រះបង្គាប់ឱ្យមន្ត្រីរដ្ឋបាលតុលាការកោះអញ្ជើញសាក្សី TCW-948

ចូលមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ រួមទាំងមេធាវីប្រឹក្សារបស់គាត់ លោក មឿន សុវណ្ណ។

*(សាក្សីចូលក្នុងបន្ទប់សវនាការ)*

[១០:៤៨:០០]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្តីលោកសាក្សី តើលោកឈ្មោះអី?

**លោក នុត នូវ ៖**

**ឆ៖** សូមគោរពលោកប្រធាន ចៅក្រម និងអស់លោក លោកស្រីទាំងអស់ ជាទីគោរព និងជាទីរាប់អាន។ ខ្ញុំបាទឈ្មោះ នុត នូវ អាយុ៧៤ឆ្នាំ រស់នៅក្នុងភូមិអង្គរនាប ឃុំត្រាំកក់ ស្រុកត្រាំកក់ ខេត្តតាកែវ។ បច្ចុប្បន្នមានតួនាទីជាសមាជិកក្រុមប្រឹក្សាឃុំនិងអាចារ្យពន្លាវៀបមង្គលការ។ សូមអរគុណ។

**ស៖** បាទ អរគុណលោក នុត នូវ ហើយលោក នុត នូវ ដែលឈ្មោះ នូវ របស់លោក សរសេរម៉េច? សរសេរ “ន-ូ” និង “វ” ឬក៏ “ន-ៅ”?

កុំអាលទាន់ឆ្លើយតបលោក នូវ រង់ចាំក្បាលមីក្រូហ្វូនប្រតិបត្តិការដោយឲ្យភ្លើងសញ្ញាពណ៌ក្រហមណ៎ះ! ទើបសំឡេងរបស់លោកបានចូលក្នុងប្រព័ន្ធចែកចាយសំឡេងនៅក្នុងសាលសវនាការនេះ។

**ឆ៖** បាទ ឈ្មោះហ្នឹង សរសេរ “ន-ូ” ដាក់ “វ”។

**ស៖** បាទ អរគុណ ហើយអម្បាញ់មិញនេះ លោកបានបញ្ជាក់ហើយនូវទីកន្លែងសព្វថ្ងៃ។ ប៉ុន្តែអង្គជំនុំជម្រះសួរថា តើទីកន្លែងកំណើតរបស់លោក លោកកើតនៅទីកន្លែងណា?

**ឆ៖** កំណើតសព្វថ្ងៃរស់នៅទីកន្លែងបច្ចុប្បន្ន បាទ។

[១០:៤៩:៤៩]

**ស៖** ចុះឪពុកបង្កើតរបស់លោក គាត់ឈ្មោះអី? ហើយម្តាយបង្កើតរបស់លោកគាត់ឈ្មោះអីដែរ?

**ឆ៖** ឪពុកឈ្មោះ នុត ណុប (ស្លាប់)។ ម្តាយឈ្មោះ មុត ផែន (ស្លាប់) រស់នៅភូមិជាមួយ។

**ស៖** អរគុណ។ ចុះភរិយារបស់លោកគាត់ឈ្មោះអី? ហើយលោកមានកូនប៉ុន្មាននាក់?

**ឆ៖** ភរិយារបស់ខ្ញុំ ប៊ូ ស។ សព្វថ្ងៃពិការដោយសារឡានបុកជាង១២ឆ្នាំហើយ ដេកនៅកន្លែង។

កូនមានប្រាំបីនាក់ -- ប្រាំបួននាក់ ប្រុសប្រាំពីរ ស្រីពីរ។ ប្រុសមួយ ប៉ុល ពត យកទៅបាត់ទៅ ប្រុសបង។ សព្វថ្ងៃនៅប្រាំបីនាក់។

**ស៖** បាទ អរគុណ។ ហើយលោក នុត នូវ តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការថា តាមសមត្ថភាពដែលលោកអាចដឹងគឺថា លោកមិនមានឪពុកម្ដាយ បុព្វញាតិ កូន បច្ឆាញាតិ បងប្អូនប្រុសស្រី បងប្អូនថ្លៃ ប្រពន្ធ ត្រូវបានទទួលស្គាល់ជាដើមបណ្ដឹងរដ្ឋប្បវេណីក្នុងរឿង សំណុំរឿង០០២ នេះទេ។ តើជាការពិតមែនដែរឬទេ?

**ឆ៖** បាទ នេះជាការពិត។

**ស៖** ហើយរបាយការណ៍ដដែលថា លោកបានស្បថរួចហើយ នៅមុខអ្នកតាដំបងដែក នៅខាងកើតសាលសវនាការនេះ មុននឹងចូលមកផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះ។ គឺបានស្បថកាលពីម្សិលមិញ។ តើជាការពិតមែនដែរឬទេ?

**ឆ៖** បាទ ពិត បានស្បថរួចហើយលោក។

[១០:៥១:៣៦]

**ស៖** ឥឡូវនេះ យើងប្រាប់អំពីសិទ្ធិនិងករណីយកិច្ចចំពោះលោក ក្នុងនាមលោកជាសាក្សី។ អំពីសិទ្ធិលោក នុត នូវ ក្នុងនាមលោកជាសាក្សីនៅក្នុងកិច្ចដំណើរការនិតិវិធីសវនាការចំពោះមុខអង្គជំនុំជម្រះនេះ លោកអាចបដិសេធក្នុងការឆ្លើយតបទៅនឹងសំណួរ ឬការសុំឲ្យលោកធ្វើអំណះអំណាងណាមួយ ឬច្រើនដែលនាំឲ្យដាក់វិរុទ្ធភាពលើខ្លួនឯង។ មានន័យថា សិទ្ធិមិនឆ្លើយ មិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។ មានន័យថាដោយសារតែចម្លើយ ឬអំណះអំណាងរបស់លោកនោះហើយ ដែលនាំឲ្យលោកនឹងត្រូវទទួលរងការចោទប្រកាន់។ អំពីករណីយកិច្ច លោក នុត នូវ ក្នុងនាមលោកជាសាក្សីផ្ដល់សក្ខី-កម្មនៅក្នុងកិច្ចដំណើរការសវនាការនៅចំពោះមុខអង្គជំនុំជម្រះនេះ លោកត្រូវតែឆ្លើយតបរាល់សំណួរទាំងឡាយដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក លើកលែងតែសំណួរដែលនាំឲ្យឆ្លើយតបរបស់លោក ឬការថាធ្វើអត្ថាធិប្បាយណាមួយ ឬច្រើនដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង។ ដូចយើងប្រាប់អំពីសិទ្ធិខាងលើរួចហើយអម្បាញ់មិញនេះ។ ហើយក្នុងនាមលោកជាសាក្សីត្រូវតែឆ្លើយការណ៍ណាដែលពិត ដែលលោកបានដឹង បានឮ បានឃើញ បានចងចាំ ឬធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬបានធ្វើការសង្កេតដោយផ្ទាល់នៅព្រឹត្តហេតុ ហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធនឹងសំណួរដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក។ តើលោកយល់អំពីសិទ្ធិ និងករណីយកិច្ចដែល

យើងជម្រាបលោកនេះដែរឬទេ លោក នុត នូវ?

**ឆ៖** បាទ ខ្ញុំបាទយល់។

**ស៖** អរគុណលោក នុត នូវ។ តើលោកធ្លាប់បានផ្តល់សក្ខីកម្ម ឬក៏ផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យស៊ើបអង្កេតដែរឬទេ ក្នុងអំឡុងពេលប៉ុន្មានឆ្នាំកន្លងមកនេះ? ហើយប្រសិនបើធ្វើ ធ្វើប៉ុន្មានដង? ធ្វើនៅទីកន្លែងណា?

**ឆ៖** បាទ ខ្ញុំបាទបានធ្វើ រាប់ដូចជាប្រាំពីរដងហើយ ប៉ុន្មានស្មានទេវាភ្លេច ប៉ុន្តែចាំនៅចុងក្រោយគឺនៅសាលាឃុំត្រាំកក់។ បាទមិនបានចាំ។

[១០:៥៤:០៤]

**ស៖** បាទ អរគុណ ហើយនៅមុនពេលចូលមកចំពោះមុខអង្គជំនុំជម្រះនៅពេលនេះ តើលោកបានពិនិត្យមើល ឬក៏បានអាននូវកំណត់ហេតុដែលលោកបានផ្តល់សក្ខីកម្មកាលពីពេលមុន ដែលលោកផ្តល់ឲ្យទៅអ្នកស៊ើបអង្កេត នៅការិយាល័យស៊ើបអង្កេតនៅមន្ទីរឃុំនោះ ដើម្បីរំឭកការចងចាំដែរឬទេ?

**ឆ៖** បាទ ខ្ញុំបាទបានអានឯកសារនេះកាលនៅមន្ទីរឃុំ ប៉ុន្តែវាអាចភ្លេចខ្លះ ឬចាំខ្លះ សុំលោកប្រធានជ្រាប។

**ស៖** ហើយតាមសមត្ថភាពដែលលោកអាចដឹងនិងចងចាំ តើលោកអាចបញ្ជាក់បានដែរទេថា កំណត់ហេតុស្តាប់ចម្លើយដែលលោកបានអានដើម្បីរំឭកការចងចាំហ្នឹងវាពិតជាត្រឹមត្រូវ ឬវាសមស្របស៊ីចង្វាក់គ្នាទៅនឹងចម្លើយដែលលោកបានផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតកាលពីពេលមុននោះដែរឬទេ?

**ឆ៖** បាទ ណាស់ គឺសមស្របដែលខ្ញុំបានឆ្លើយនៅមន្ទីរឃុំ។

**ស៖** បាទ អរគុណលោក នុត នូវ។ នៅពេលនេះលោកបានទទួលជំនួយមេធាវីប្រឹក្សា ដែលអង្គជំនុំជម្រះផ្តល់ឲ្យតាមរយៈអង្គភាពគាំពារសាក្សី និងអ្នកជំនាញតាមសំណើរបស់លោក។ ហើយលោកមេធាវីប្រឹក្សារបស់លោក គឺលោក មឿន សុវណ្ណ។ តើលោកបានប្រឹក្សាយោបល់ជាមួយនឹងមេធាវីប្រឹក្សារបស់លោករួចហើយឬនៅមុននឹងចូលមកចំពោះអង្គជំនុំជម្រះនាពេលនេះ?

**ឆ៖** បាទ ខ្ញុំបាទបានប្រឹក្សារួចហើយ។ គាត់បានផ្តល់មតិខ្លះៗ។

**ប្រធានអង្គជំនុំ៖**

**ស៖** បាទ អរគុណ។ ហើយនៅក្នុងការសួរដេញដោលចំពោះសាក្សីនេះ អនុវត្តតាមវិធាន៩១

ស្ទួន នៃវិធានផ្ទៃក្នុងអ.វ.ត.ក អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញាសួរដេញដោលសាក្សី នុត នូវ មុនភាគីដទៃទៀតនៃរឿងក្តី។ ហើយសូមបញ្ជាក់ថា សហព្រះរាជអាជ្ញា រួមទាំងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានរយៈពេលមួយពេល និងមួយវគ្គនៃថ្ងៃសវនាការក្នុងការសាកសួរសាក្សីរូបនេះ។ សូមអញ្ជើញព្រះរាជអាជ្ញា!

បាទ កុំអាលសិនលោកសហព្រះរាជអាជ្ញា! សូមអញ្ជើញលោក វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន ហើយខ្ញុំអភ័យទោសផងដែរ ដែលខ្ញុំងើបឡើង ព្រោះថា តើយើងស្តាប់ឮត្រឹមត្រូវដែរឬទេ ដែលថាសាក្សីមានចម្លើយប្រាំពីរដង។ យើងមិនមានចម្លើយដល់ទៅប្រាំ ព្រោះថាយើងយល់ឃើញថា ប្រសិនបើបាត់ឯកសារចម្លើយដល់ប្រាំ វាអត់មានប្រយោជន៍អីដែលយើងត្រូវបន្តទៅមុខទៀតនោះទេ។ ដូច្នេះខ្ញុំស្នើសុំថា ចង់ឲ្យលោកប្រធានមេត្តាពិនិត្យបញ្ជាក់បន្ថែមទៅលើចំណុចទាំងអស់នេះ។ ប្រសិនបើវាជាការពិត ដែលថាគាត់មានចម្លើយប្រាំពីរ យើងនឹងស្នើសុំឲ្យមានការផ្អាកសវនាការនេះ។ សូមអរគុណ។

[១០:៥៧:២១]

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** លោក នុត នូវ តើលោកផ្តល់សក្ខីកម្មចំពោះអ្នកស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬទូទៅគេហៅថា “តុលាការខ្មែរក្រហមនេះ” ប៉ុន្មានដង? ហើយធ្វើនៅកន្លែងណានៅពេលណា? គឺយើងសួរតែលោកផ្តល់សក្ខីកម្មឲ្យអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាប៉ុណ្ណោះ?

**លោក នុត នូវ៖**

**ឆ៖** បាទ អរគុណណាស់ ក្នុងការស៊ើបអង្កេតនេះមានការសាកសួរនៅគេហដ្ឋានរបស់ខ្ញុំហ្នឹងបីដង ប៉ុន្តែមិនចាំថ្ងៃពិតប្រាកដទេ។ ហើយនៅផ្ទះលោក ហ៊ូ ហ៊ាំ ម្តង និងនៅសាលាឃុំម្តង។ សូមអរគុណ។

**ស៖** នៅផ្ទះរបស់លោកហ្នឹង ធ្វើបីដងហ្នឹងជាប់គ្នារាល់ថ្ងៃ ឬក៏ធ្វើហ្នឹងមានការដាច់គ្នាពីពេលមួយទៅពេលមួយ។ បានន័យថាពីមួយលើកទៅមួយលើកហ្នឹង មានរយៈពេលដាច់ឃ្លាតឆ្ងាយពីគ្នា ហើយរកនឹកមើល៍ ថាតើលើកទី១ ធ្វើនៅពេលណា? លើកទី២ ធ្វើនៅពេលណា? ហើយលើកទី៣

ធ្វើនៅពេលណា?

**ឆ:** បាទ ធ្វើវាដាច់គ្នា។ ជួន១ឆ្នាំ ជួន២ឆ្នាំ ទៅសាកសួរម្ដង ហើយពេល សុំអភ័យ ខ្ញុំបាទមិនបានចាំទេ ព្រោះអត់មានឯកសារ។

**ស:** បីដងដែលធ្វើនៅ -- លោកផ្ដល់សក្ខីកម្មនៅផ្ទះរបស់លោកហ្នឹង តើខាងណាដែលគេធ្វើដំណើរទៅស្ដាប់សក្ខីកម្មរបស់លោកនៅនឹងផ្ទះរបស់លោក រហូតដល់ទៅបីដងនោះ។ ខាងណាគេ? លោកចាំទេ អង្គភាពខាងណាដែរ ហើយលោកចាំឈ្មោះគេទេ?

[១០:៥៩:៥៨]

**ឆ:** ភ្លេច។ បាទ អង្គភាពខាងមន្ត្រីស៊ើបពិនិត្យក្រុមការងាររបស់លោក ឆាំង យុ។ បាទ មានឈ្មោះ សុជាតិ, មាន ជួង សុភារិទ្ធ អីជាដើមបន្តបន្ទាប់ ខ្ញុំបាទមិនចាំអស់ទេ។

**ស:** ធ្វើ -- ស្ដាប់សក្ខីកម្មរបស់លោកនៅនឹងផ្ទះរបស់លោកហ្នឹង ទាំងបីដងហ្នឹងសុទ្ធតែអង្គភាពរបស់លោក ឆាំង យុ។ អ៊ីចឹងពិតមែនទេ?

**ឆ:** បាទ ពិតប្រាកដមែន។

**ស:** ចុះចំណែកឯការដែលលោកផ្ដល់សក្ខីកម្មនៅនឹងផ្ទះរបស់ឈ្មោះ ហ៊ូ ហាំ មួយដង។ ផ្ទះ ហ៊ូ ហាំ នោះ នៅភូមិអីគេ? ភូមិណា? ឃុំណា? ស្រុកណា?

**ឆ:** ផ្ទះ ហ៊ូ ហាំ នុ៎ងនៅភូមិជាមួយគ្នា ផ្ទះជិតគ្នា។

**ស:** ហើយធ្វើម្ដងហ្នឹង ដែលធ្វើនៅផ្ទះ ហ៊ូ ហាំ ហ្នឹងខាងណាជាអ្នកស្ដាប់សក្ខីកម្មរបស់លោក?

**ឆ:** ខាងអង្គការស្រាវជ្រាវឯកសារហ្នឹងដែរ ប៉ុន្តែមានសាសន៍ម្នាក់ មិនដឹងសាសន៍កូរ៉េ ឬក៏សាសន៍បារាំង។ បាទ ប្រហែលជាបារាំង។

**ស:** មានខ្មែរទៅជាមួយទេ?

**ឆ:** បាទ មាន ប៉ុន្តែខ្ញុំបាទមិនស្គាល់ឈ្មោះ។

**ស:** អ៊ីចឹងមានទាំងខ្មែរ មានទាំងជនជាតិបរទេស ហើយសរុបមានគ្នា ខ្មែរប៉ុន្មាននាក់? បរទេសប៉ុន្មាននាក់ដែរ ដែលទៅសួរលោកនៅផ្ទះ ហ៊ូ ហាំ នោះ?

**ឆ:** បាទ ខ្មែរពីរនាក់ ទាំងអ្នកតែកុងឡាន បរទេសតែមួយទេ នារី។

**ស:** អរគុណ ហើយលោកចាំទេនៅថ្ងៃខែឆ្នាំណាដែរ លោកចាំទេ? លោកនឹកបន្តិចមើលរកនឹកបន្តិចមើល?

[១១:០២:៤២]

**ធៈ** បាទ ខ្ញុំបាទសូមអភ័យទោស អធ្យាស្រ័យ ព្រោះភ្លេចថ្ងៃខែ អត់បានចាំ អត់បានកត់។ សូមអភ័យទោស។

**សៈ** ចុះលោកចាំឆ្នាំទេ ឆ្នាំណាទេ?

**ធៈ** ឆ្នាំក៏មិនអាចប្រាកដដែរ។

**សៈ** ចុះការដែលធ្វើនៅនឹងសាលាឃុំម្តង នៅសាលាឃុំអីគេម្តង?

**ធៈ** នៅសាលាឃុំត្រាំកក់ហ្នឹង តែម្តង។

**សៈ** ហើយខាងណាដែរ ដែលគេទៅស្តាប់នូវសក្ខីកម្ម ទៅធ្វើកំណត់ហេតុស្តាប់សក្ខីកម្មរបស់លោកនៅសាលាឃុំត្រាំកក់នោះ?

**ធៈ** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**សៈ** សូមលោកឆ្លើយណ៎ា អំមិញលោកមិនទាន់ឆ្លើយទេ។ លោកឆ្លើយដែលក្បាលមីក្រូហ្វូនមិនទាន់ប្រតិបត្តិការស្មើនឹងមិនទាន់ឆ្លើយ។

**ធៈ** ធ្វើនៅសាលាឃុំត្រាំកក់។ បាទ ឆ្នាំខាងសាលាក្តីខ្មែរក្រហមជាអ្នកទៅសាកសួរ មានអ្នកបកប្រែម្នាក់ មានលោកខាងសាកសួរម្នាក់ និងមានបរទេសម្នាក់។

**សៈ** លោកចាំទេ ចាំថានៅថ្ងៃខែឆ្នាំណាទេ?

**ធៈ** បាទ ឯកសារហ្នឹង ខ្ញុំយកមកដែរ មិនចាំថ្ងៃ យកមកជាមួយដែរ។

**សៈ** យកមកទាំងពីរលើកទេ? ពិតមែនទេ?

**ធៈ** យកមកតែមួយលើក។

[១១:០៥:៤៧]

**សៈ** ការដែលលោកផ្តល់សក្ខីកម្មនៅផ្ទះ ហ៊ូ ហាំ មួយលើក ហើយនិងធ្វើលើកទី២ ធ្វើមួយលើកទៀតនៅសាលាឃុំត្រាំកក់ ដែលធ្វើឡើងដោយមន្ត្រី ដែលទៅពីសាលាក្តីខ្មែរក្រហមទៅ។ តើមានឃ្លាតគ្នា ពេលគ្នា រយៈពេលប៉ុន្មានថ្ងៃដែរ? ប៉ុន្មានខែ ប៉ុន្មានឆ្នាំដែរ? ពីធ្វើនៅផ្ទះ ហ៊ូ ហាំ មកធ្វើលើកដែលនៅនឹងសាលាឃុំត្រាំកក់?

**ធៈ** បាទ ឃ្លាតគ្នាប្រហែល៤ឆ្នាំ។

**ប្រធានអង្គជំនុំ៖**

ក្រឡាបញ្ជី អ៊ំ! មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារដែលគាត់មាននៅក្នុងដៃយកមកឲ្យយើងពិនិត្យ។

*(មន្ត្រីតុលាការយកឯកសារជូនប្រធានអង្គជំនុំ)*

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការទទួលយកឯកសារវិញចុះ។ រក្សាទុកឲ្យគាត់វិញចុះ!

មានបញ្ហាអីទៀតទេ លោក វ៉ិចទ័រ កូប៉េ?

[១១:០៩:២៤]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំគិតថាគួរតែមានរបាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ហើយខ្ញុំគិតថាយើងគួរតែអាចចូលពិនិត្យមើលទៅក្នុងៗឯកសារទាំងអស់នេះ ប៉ុន្តែខ្ញុំស្វែងរកទៅតែអត់មានឃើញមានឯកសារទេ ហើយខ្ញុំក៏មិនដឹងថាខាងព្រះរាជអាជ្ញាមានឯកសារនេះ ឬក៏អាចចូលពិនិត្យឯកសារនេះបានដែរឬក៏អត់នោះទេ។ ខ្ញុំដឹងថាអ្នកស៊ើបអង្កេត ឬក៏មន្ត្រីច្បាប់ក្នុងសំណុំរឿង០៣, ០៤ ប្រហែលជាអាចឆ្លើយបានទៅលើបញ្ហានេះ។ ខ្ញុំគិតថាប្រហែលជាយើងអាចចាប់ផ្តើមសាកសួរសាក្សីនេះសិន ហើយយើងនឹងសម្រេចបន្តទៀតក្រោយពេលសម្រាកអាហារថ្ងៃត្រង់។

**ប្រធានអង្គជំនុំ៖**

អញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

បាទ ជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រមជាទីគោរព! ឥឡូវ យើងស្ថិតនៅក្នុងស្ថានភាពដូចមេធាវីការពារក្តីដែរគឺថា យើងមានកំណត់ហេតុស្តាប់ចម្លើយតែពីរហ្នឹងទេ ហើយយើងមិនដឹងថាគាត់ពីមុនមកហ្នឹងបានផ្តល់កិច្ចសម្ភាសន៍ដល់មជ្ឈមណ្ឌលឯកសារកម្ពុជានោះដែរ ហើយយើងមិនដែរមានកំណត់ហេតុនៃការស្តាប់ចម្លើយគាត់ពីមុនមកដែរ។ ដូច្នេះ យើងអាចស្វែងរកឯកសារទាំងនេះពេលសម្រាក ក៏ប៉ុន្តែទន្ទឹមហ្នឹងនេះភាគីទាំងអស់គ្នាហ្នឹងស្ថិតនៅក្នុងស្ថានភាពដូចគ្នា គឺយើងអត់មានឯកសារដូចគ្នា។ អ៊ីចឹង យើង -- ខ្ញុំគិតថាគ្មានរឿងហេតុអ្វីដែលមិនអាចឲ្យយើងបន្តចប់សំណួរបាននោះទេ ពីព្រោះយើងស្ថិតនៅក្នុងស្ថានភាពស្មើគ្នា។ បាទ លោកប្រធាន។

[១១:១១:០៤]

**ប្រធានអង្គជំនុំ៖**

សហព្រះរាជអាជ្ញាអាចបន្តតាំង -- ការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះហើយ!

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ស្រ៊ា រតនះ៖**

សូមគោរពលោកប្រធានអង្គជំនុំជម្រះ លោក លោកស្រីចៅក្រម និងអង្គសវនាការទាំងមូល!

**ស៖** សូមជម្រាបសួរលោកសាក្សី ខ្ញុំបាទឈ្មោះ ស្រ៊ា រតនៈ ជាសហព្រះរាជអាជ្ញារងជាតិនៃ អ.វ.ត.ក ខ្ញុំបានមានសំណួរមួយចំនួននឹងសាកសួរទៅលោកសាក្សី ហើយជាបន្តបន្ទាប់ទៅទៀត សហការីខ្ញុំបាទនឹងបន្តសំណួរបន្ទាប់ពីខ្ញុំបានបញ្ចប់។ កន្លងមកតាមរយៈការសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត តាមរយៈឯកសារលេខ E3/5521 ត្រង់ចម្លើយទី១ លោកបានឆ្លើយថា៖ “មុនឆ្នាំ១៩៧០ ខ្ញុំជាកសិករនៅភូមិអង្គរនាប ឃុំត្រាំកក់ ស្រុកត្រាំកក់”។ ជាមួយគ្នានេះដែរ នៅក្នុងឯកសារដដែលនេះដែរ នៅចម្លើយទី៤ លោកបានឆ្លើយថា៖ “ក្រោយខ្មែរក្រហមចូលកាន់កាប់ឆ្នាំ១៩៧០ ពួកខ្មែរក្រហមបានតែងតាំងខ្ញុំឲ្យធ្វើជាមេក្រុម”។ ខ្ញុំបាទចង់សួរលោកសាក្សីថា តើលោកជាមេក្រុមហ្នឹង នៅភូមិណា? នៅឃុំណា?

**លោក នុត នូវ៖**

**ឆ៖** បាទ លោកមេក្រុមហ្នឹង នៅភូមិអង្គរនាប ឃុំត្រាំកក់ ស្រុកត្រាំកក់។

**ស៖** តើលោកនៅទីនោះពីឆ្នាំដល់ឆ្នាំណាដែរ?

**ឆ៖** បាទ នៅពីឆ្នាំ១៩៧០ ដល់ ៧៣។

**ស៖** ដូចគ្នានេះដែរ នៅក្នុងឯកសាររបស់ -- ក្នុងការសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ក្នុងឯកសារលេខ E3/5521 ត្រង់ចម្លើយទី៥ លោកធ្លាប់បានឆ្លើយថា៖ “ក្នុងឆ្នាំ១៩៧០ ដល់ ១៩៧៣ គេឲ្យប្រជាជនធ្វើស្រែប្រវាស់ដៃ។ ក្រុមប្រវាស់ដៃនេះជាក្រុមបង្កបង្កើនផលធ្វើស្រែរួម ប៉ុន្តែចែកផលទៅតាមមនុស្ស ដូចជាប្រភេទទី១ មនុស្សពេញកម្លាំង ទី២ មនុស្សដែលមានអាយុ១៨ឆ្នាំចុះ និងទី៣ ក្មេងៗនិងចាស់ៗ”។ តើក្រុមប្រវាស់ដៃនេះ ខុសពីសហករណ៍ដូចម្តេចដែរ?

[១១:១៣:៥៩]

**ធ៖** បាទ ក្រុមប្រវាស់ដៃនេះ វាខុសប្លែកពីសហករណ៍។ សហករណ៍ គឺយើងធ្វើរួម ហូបរួម។ ហើយដល់ប្រវាស់ដៃ យើងចែកផលគ្នា។ បាទសូមជ្រាប។

**ស៖** នៅក្នុងឯកសារដដែល ត្រង់ចម្លើយទី២០ លោកឆ្លើយថា៖ "នៅក្នុងឆ្នាំ១៩៧៤ ខ្ញុំបានចូលបម្រើយោធា ដល់ក្រោយមកខ្ញុំមានជំងឺគ្រុនចាញ់ និងបូសអន្ទង់ ថ្នាក់លើបានចាត់តាំងឲ្យខ្ញុំមកនៅមន្ទីរឃុំញ៉ែងញ៉ង"។ តើលោកនៅមន្ទីរឃុំញ៉ែងញ៉ងនេះ រហូតដល់ឆ្នាំណា?

**ធ៖** បាទ ខ្ញុំបាទនៅមន្ទីរឃុំញ៉ែងញ៉ងរហូតដល់ឆ្នាំ១៩៧៦ -- ៧៧ បាទ សូមអភ័យទោស។

**ស៖** លោកធ្វើអ្វីដែលនៅទីនោះ?

**ធ៖** ខ្ញុំធ្វើនៅមន្ទីរ។

**ស៖** ខ្ញុំចង់ដឹងពីកិច្ចការប្រចាំថ្ងៃរបស់លោក នៅឃុំញ៉ែងញ៉ង។ តើលោកធ្វើអ្វីបំពេញជាការងារប្រចាំថ្ងៃ?

**ធ៖** បំពេញការងារប្រចាំថ្ងៃនៅមន្ទីរឃុំញ៉ែងញ៉ង គឺសុំស្បៀងជូនទៅសមរភូមិមុខ។ មានម្ហូប មានបន្លែជាដើម។

**ស៖** នៅឆ្នាំ១៩៧៥ តើលោកបានដឹងអំពីការជម្លៀសប្រជាជនដែរឬទេ?

**ធ៖** បាទ អរគុណណាស់។ នៅឆ្នាំ១៩៧៥ ពីមុនមិនបានដឹងថាជម្លៀសប្រជាជនទេ ប៉ុន្តែដល់ក្រោយមកឃើញប្រជាជនមកច្រើន បានយល់ថាការជម្លៀសប្រជាជនចេញពីទីក្រុង។ សូមអរគុណ។

[១១:១៦:២៥]

**ស៖** តើនៅពេលដំបូងហ្នឹងមានអីកើតឡើងចំពោះអ្នកដែលជម្លៀសទាំងនោះ នៅក្នុងឃុំរបស់លោក?

**ធ៖** ហាក់ដូចជាគ្មានអីកើតឡើងទេ។

**ស៖** សូមលោកបញ្ជាក់កន្លែងនេះឲ្យច្បាស់ជាងនេះបន្តិច។ អត់មានអ្វីកើតឡើងហ្នឹង បានន័យថាដូចម្ដេចដែរ?

**ធ៖** បាទ អរគុណ។ ឃើញប្រជាពលរដ្ឋដែលមកអ៊ីចឹងទៅ ខាងឃុំហ្នឹងរៀបចំកន្លែងឲ្យស្នាក់នៅ នៅតាមភូមិនីមួយៗ។ អ៊ីចឹងបានខ្ញុំថាអត់មានអីកើតឡើង។

**ស៖** តើនៅក្នុងឃុំរបស់លោក លោកអាចដឹងបានទេថា មានប្រជាជន១៧មេសា ហ្នឹងប៉ុន្មានគ្រួសារដែរ?

**ធ៖** ខ្ញុំមិនអាចដឹងបានទេ។

**ស៖** ខ្ទង់ៗរយ ឬក៏ខ្ទង់រាប់សិប ឬក៏ខ្ទប់រាប់ពាន់?

**ធ៖** ខ្ទង់រាប់ពាន់ក្នុងមួយឃុំៗ។ ប៉ុន្តែពាន់នាក់ទេ មិនមែនពាន់គ្រួសារទេ ពាន់នាក់។

[១១:១៨:១០]

**ស៖** ពាក់ព័ន្ធនឹងករណីនេះ តើពេលដំបូងៗមានផែនការឲ្យពួកប្រជាជនថ្មីទាំងអស់ហ្នឹងបំពេញប្រវត្តិរូបដែរឬទេ?

**ធ៖** ពីដំបូងឡើយគឺមិនមានអីឲ្យបំពេញធ្វើជាប្រវត្តិរូបអីទេ ឃើញថាមកនៅ រស់នៅជាមួយគ្នា ហូបបាយជាមួយគ្នា។

**ស៖** តើធ្វើដូចម្តេចបានគេញែក បានគេអាចញែកបានថា ពេលនោះអ្នកណាជាប្រជាជនថ្មី និងប្រជាជនចាស់?

**ធ៖** ញែកជាប្រជាជនថ្មី ជាប្រជាជនចាស់ គេមានបញ្ជីរបស់គេ ប្រជាជនដែលទើបចូលមក និងប្រជាជនដែលនៅមូលដ្ឋានយូរហើយ។

**ស៖** តើនៅក្នុងចំណោមប្រជាជនថ្មីទាំងអស់ហ្នឹង គេអាចដឹងថាសមាសភាពអ្នកហ្នឹងជាអ្វីដែរទេ? ត្រង់នេះខ្ញុំចង់សំដៅថាជាទាហានលន់នល់ ឬក៏អ្នករដ្ឋការសម័យលន់នល់។ តើមាន តើគេអាចសម្គាល់បានដឹងដែរឬទេ កាលពីសម័យនោះ?

**ធ៖** បាទ អត់អាចសម្គាល់បានទេ។

[១១:២០:០០]

**ស៖** នៅក្នុងឯកសារដដែលនេះដែរ គឺ E3/5521។ ខ្ញុំសូមដកស្រង់ត្រង់នៅសំណួរទី៣០៖ "តើនៅក្នុងភូមិរបស់លោកមានគេប្រកាសប្រាប់ថា បើអ្នកណាធ្លាប់ធ្វើជាទាហាន ឬគ្រូបង្រៀន ឬមន្ត្រីរដ្ឋការ គេឲ្យធ្វើការនៅកន្លែងដើមវិញដែរឬទេ? ចម្លើយ៖ ពិតជាមាន។ អ្នកទាំងនោះ មិនដែលឃើញហៅទៅណាទេ ប៉ុន្តែបើមាន មិនស្រប ឬប្រឆាំងអ្វី គឺហៅទៅរៀនសូត្រ ហើយអ្នកទាំងនោះ មិនដែលឃើញត្រឡប់មកវិញទេ"។ សូមបញ្ចប់ការដកស្រង់។ ត្រង់ចំណុចនេះខ្ញុំចង់សួរទៅលោកថា តើចម្លើយរបស់លោកកាលនោះ ដូចអ្វីដែលខ្ញុំបានអានហ្នឹង តើមានន័យថាដូចម្តេច? មានន័យថាម៉េចដែរ ចម្លើយប៉ុណ្ណឹង?

**ធ៖** បាទ ចម្លើយនេះមានន័យថា គេមានប្រាប់អីចឹងទៅ វាមានឃោសនាឲ្យថា អ្នកណាធ្វើអី

ទៅធ្វើការវិញ។ តែឃើញមនុស្សហ្នឹងនៅដដែល តែបើមានការប្រឆាំងនឹងរបបកម្ពុជាប្រជាធិបតេយ្យ ឃើញគេចាប់យកទៅហូរហែអ៊ីចឹងដែរ ប៉ុនអត់ឃើញត្រឡប់មកវិញទេ ហើយសួរគេ គេថា "យកទៅរៀនសូត្រ"។ នេះសូមអង្គជម្រាប។

**ស៖** ពាក្យថា "ប្រឆាំងនឹងរបបកម្ពុជាប្រជាធិបតេយ្យហ្នឹង" ខ្ញុំចង់ឲ្យលោកបញ្ជាក់ឲ្យច្បាស់បន្តិច តើប្រឆាំងនឹងការ -- ប្រឆាំងនឹងបញ្ជាគេ ដែលគេ -- ប្រឆាំងនឹងការឃោសនារបស់គេហ្នឹង ឬក៏ប្រឆាំងនឹងគោលការណ៍របស់កម្ពុជាប្រជាធិបតេយ្យ?

**ឆ៖** ប្រឆាំងនឹងគោលការណ៍រួម បាទ។

**ស៖** តើនៅពេលនោះលោកបានជួបនឹងករណីជាក់ស្តែងណាមួយ ពាក់ព័ន្ធនឹងការប្រឆាំងនឹងគោលការណ៍រួមនេះទេ? សូមលោកលើកជាករណីមួយ ឬពីរ តាមដែលលោកបានជួបប្រទះ។

**ឆ៖** ការពិត គឺខ្ញុំមិនដែលបានជួបទេ គ្រាន់តែឮគេនិយាយ។ ព្រោះខ្ញុំនៅតែមន្ទីរ មន្ទីរហ្នឹង។

[១១:២២:៥៤]

**ស៖** ពាក់ព័ន្ធនឹងករណីមួយទៀត គឺនៅក្នុងឯកសារ E3/5521ដដែល។ ខ្ញុំសូមដកស្រង់ ត្រង់សំណួរទី៣៩៖ "សួរថាតើនៅឃុំញ៉ែងញ៉ង មានសហករណ៍ប៉ុន្មាន? ចម្លើយ៖ ជាដំបូង គេរៀបចំតាមភូមិ ដល់ក្រោយមកទៀតគេរៀបចំតាមកង"។ សូមបញ្ចប់ការដកស្រង់។ ខ្ញុំចង់ជម្រាបសួរលោកថា តើនៅពេលណាដែលគេបែងចែកសហករណ៍តាមភូមិ? ខ្ញុំចង់បានកាលបរិច្ឆេទជាឆ្នាំ ជាខែ ឬជាថ្ងៃ បើសិនជាលោកនៅចងចាំបាន។

**ឆ៖** គេរៀបចំតាមកង គេរៀបចំឆ្នាំ១៩៧៧ – ចុង៧៧ ឈានចូល៧៨។

**ស៖** ចុះពាក់ព័ន្ធនឹងក្រុមប្រវាស់ដៃដែលខ្ញុំបានជម្រាបសួរលោកពីខាងដើមមុននេះបន្តិចហ្នឹង តើក្រុមប្រវាស់ដៃហ្នឹង បានក្លាយមកជាសហករណ៍ហ្នឹងនៅឆ្នាំណា?

**ឆ៖** ក្រុមប្រវាស់ដៃក្លាយមកជាសហករណ៍នៅឆ្នាំដែលរំដោះ ១៩៧៥។ ពេលនោះ ប្រជាជនជម្លៀសទៅច្រើន គឺហូបបាយរួម។ អាហ្នឹងតាមខ្ញុំចាំ។

**ស៖** តើលោកមានការពន្យល់ឲ្យច្បាស់ជាងនេះបន្តិចបានទេ រវាងចម្លើយៗពីរ។ អាចខ្ញុំមានការភាន់ច្រឡំនៅក្នុងនេះ។ ខ្ញុំសួរ ចម្លើយដែលខ្ញុំសួរថានៅពេលដែលគេបែងចែកសហករណ៍តាមភូមិ? លោកបានឆ្លើយថា នៅរវាងឆ្នាំ -- ចុងឆ្នាំ៧៧ ឬក៏ដើមឆ្នាំ៧៨។ តែទន្ទឹមគ្នានឹងដែរ ចំពោះសំណួរដែលសួរថា តើក្រុមប្រវាស់ដៃបានក្លាយជាសហករណ៍ហ្នឹងនៅឆ្នាំណា? លោកបានឆ្លើយថា នៅឆ្នាំ១៩៧៥។

អ៊ីចឹង អាចមានៗន័យថា នៅចន្លោះឆ្នាំ៧៥ ដល់ឆ្នាំ៧៧ ហ្នឹងមានក្រុមអីផ្សេងទៀត ដែលមានរបៀបដូច សហករណ៍ ឬក៏សហករណ៍ត្រូវបានបង្កើតដែរ ប៉ុន្តែគេបង្កើតទៅតាមរបៀបផ្សេង? លោកយល់នឹង សំណួរខ្ញុំទេ? ខ្ញុំនិយាយញាប់ពេកឬយ៉ាងម៉េច? បើលោកអត់យល់សួរខ្ញុំវិញ។

**ផ៖** ខ្ញុំចង់ឲ្យលោកបំភ្លឺម្តងទៀត។

[១១:២៥:៤៦]

**ស៖** នៅក្នុងនេះមាន -- ខ្ញុំសួរលោកលើកទី១ សួរថា សំណួរមុននេះ សួរថាតើនៅឆ្នាំណា ឬក៏ នៅពេលណាដែលគេបែងចែកសហករណ៍នៅតាមភូមិ? ហើយខ្ញុំសួរបែបនេះដែលមានពាក្យថា "សហ-ករណ៍" គេបង្កើតសហករណ៍នៅតាមភូមិ គឺតាមអ្វីដែលលោកបានឆ្លើយជាមួយនឹងអ្នកស៊ើបអង្កេតនៃ ការិយាល័យសហចៅក្រមស៊ើបអង្កេតតាំងពីពេលមុន ហើយលោកបានឆ្លើយថាការបែងចែកសហករណ៍ ធ្វើតាមភូមិនេះគឺនៅចុងឆ្នាំ រវាងចុងឆ្នាំ១៩៧៧ ឬក៏ដើមឆ្នាំ១៩៧៨។ ហើយនៅខ្ញុំក៏សួរបន្តទៅទៀត សួរថាតើនៅពេលណាដែលក្រុមប្រវាស់ដៃបានក្លាយទៅជាសហករណ៍? លោកបានឆ្លើយថាគឺនៅឆ្នាំ ១៩៧៥។ អ៊ីចឹងខ្ញុំចង់ដឹងថា ឆ្នាំ១៩៧៥ ហ្នឹងទៅដល់ឆ្នាំ១៩៧៧ ឬក៏ដើមឆ្នាំ១៩៧៨ហ្នឹង មានសហ ករណ៍ហើយឬនៅ? ត្រូវបានបង្កើតហើយឬនៅ? ហើយបើបង្កើតតើបង្កើតតាមរបៀបណា? តើបង្កើត តាមភូមិដូចអ្វីដែលលោកបានលើកឡើងខាងដើម ឬក៏មានវិធីនៃការបង្កើតសហករណ៍តាមបែបផ្សេង?

**ផ៖** បាទ សុំអធ្យាស្រ័យ ខ្ញុំដូចច្រឡំ។ ការពិតទៅឆ្នាំ១៩៧៥ ដែលប្រជាជនទៅពីទីក្រុងច្រើន ហ្នឹង គេចែក ប៉ុនក្នុងចន្លោះនេះគឺគ្មានរៀបអីក្រៅហ្នឹងទៀតទេ មានតែក្រុមប្រវាស់ដៃ និងរៀបចំសហ-ករណ៍។ សូមអរគុណ។

**ស៖** អ៊ីចឹង តើនៅពេលណាដែលកម្មសិទ្ធិឯកជនត្រូវបានលុបបំបាត់ នៅក្នុងឃុំរបស់លោក?

[១១:២៧:៥២]

**ផ៖** បាទ ខ្ញុំមិនបានចាំអស់ទេ ព្រោះភ្លេចវាយូរហើយ។

**ស៖** ចុះនៅពេលណាដែលរូបលោកផ្ទាល់ដែលគេកំណត់ឲ្យហូបរួម ធ្វើការរួមហូបរួម?

**ផ៖** ហូបរួម ធ្វើការរួមហ្នឹង ចំពោះខ្លួនខ្ញុំផ្ទាល់ ទាំងអស់គ្នាគឺ១៩៧៦មក។

**ស៖** អ៊ីចឹង បើខ្ញុំយល់មិនច្រឡំទេ តាមរយៈចម្លើយលោកប្រៀបធៀបរវាងសហករណ៍ ហើយ និងក្រុមប្រវាស់ដៃ ឃើញថាសហករណ៍គឺធ្វើការរួមហូបរួម។ អ៊ីចឹងហើយចំពោះលោកថាចាប់ផ្តើម ហូបរួមនៅឆ្នាំ១៩៧៦។ អ៊ីចឹង តើខ្ញុំអាចនិយាយបានថាសហករណ៍កើតឡើងនៅឆ្នាំ១៩៧៦ បានទេ?

**ឆ៖** បាទ ខ្ញុំបានច្រឡំ អាហ្នឹងមិនប៉ាន់វិនិច្ឆ័យ។

**ស៖** ពាក់ព័ន្ធនឹងការងារ (សុំទោស) ពាក់ព័ន្ធនឹងចម្លើយរបស់លោកត្រង់ចម្លើយទី៤០ នៅក្នុងឯកសារដដែលនេះ គឺលោកបានបញ្ជាក់បន្ថែមទៀតថា ដំបូងឡើយគេបែងចែកសហករណ៍តាមភូមិ ក្រោយមកបានបែងចែកជាកង ហើយនៅក្នុងនោះគេមានបែងចែកជាប្រជាជនពេញសិទ្ធិ ប្រជាជនត្រៀម និងប្រជាជនបញ្ញើ។ តើលោកអាចពន្យល់ពីលក្ខខណ្ឌហ្នឹងបន្តិចបានទេ ហើយតើការបែងចែកប្រជាជនមកតាម -- បែងចែកសហករណ៍ជាប្រជាជនតាមកងវិញនៅឆ្នាំណាដែរ?

[១១:៣០:២៧]

**ឆ៖** បាទ ពិតណាស់ គេចែក អង្កាល់នោះគឺមានប្រជាជនពេញសិទ្ធិ មានប្រជាជនត្រៀម មានប្រជាជនបញ្ញើ។ ប្រជាជនពេញសិទ្ធិគឺជាប្រជាជនដែលស្មោះត្រង់ រួមការងារជាមួយអង្គការ។ ប្រជាជនត្រៀម ប្រជាជនដែលមានគេយកកូនទៅរៀនសូត្រ មានកូននៅតំបន់ខ្លាំងអីចឹងទៅ គឺប្រជាជនត្រៀម។ ប្រជាជនបញ្ញើ គឺប្រជាជនមកពីទីក្រុងទាំងអស់ ហៅថា "ប្រជាជនបញ្ញើ"។

**ស៖** លោកចាំបានទេថា តើការបែងចែកនេះគេធ្វើឡើងនៅឆ្នាំណា?

**ឆ៖** សូមអភ័យទោស ព្រោះកាលហ្នឹង ខ្ញុំដូចភ្លេចភ្លាំង មិនពិតប្រាកដទេ។

**ស៖** ដូចៗអ្វីដែលលោកបានរៀបរាប់ពីខាងលើ គឺ ហើយក៏ដូចជាចម្លើយរបស់លោកនៅក្នុងឯកសារ E3/5521 ដែរគឺត្រង់ចម្លើយទី៤៥ លោកថានៅឃុំញ៉ែងញ៉ង លោកទទួល -- លោកជាអ្នកទទួល និងបែងចែកស្បៀងតាមសហករណ៍ ដែលថ្នាក់ស្រុកប្រគល់ជូន ប៉ុន្តែឃុំជាអ្នកសម្រេចឲ្យចែក។ ខ្ញុំចង់ជម្រាបសួរលោកថា តើលោកបែងចែកស្បៀងទាំងនោះដូចម្តេចដែរ?

**ឆ៖** ការបែងចែកនេះ ខ្ញុំគ្រាន់តែចែកទេ គឺកំណត់របស់ឃុំមានតួលេខចេញឲ្យ ភូមិនេះប៉ុន្មាន កងនេះប៉ុន្មានៗអីចឹងទៅ។ ទៅតាមជាក់ស្តែងតួលេខរបស់មេឃុំ។

**ស៖** តើត្រឹមថ្នាក់សម្រេចអំពីការបែងចែកហ្នឹងមានត្រឹមកម្រិតឃុំ ឬក៏មានកម្រិតលើសពីហ្នឹងទៅទៀត?

**ឆ៖** ការពិតទៅ ខាងស្រុកគេឲ្យមកជារួម ប៉ុន្តែឃុំជាអ្នកចែងទៅតាមកង។

**ស៖** អីចឹងជាសរុបទៅ តើការបែងចែកស្បៀងសម្រាប់ប្រជាជននៅកាលសម័យនោះមានភាពគ្រប់គ្រងដែរទេ?

[១១:៣៣:២០]

**ឆ៖** បែងចែកស្បៀងកាលនោះ មិនមានការគ្រប់គ្រាន់ទេ មានការខ្វះខាត ប្រជាពលរដ្ឋហូប មិនគ្រប់គ្រាន់។

**ស៖** ពាក្យថា "មិនគ្រប់គ្រាន់" នៅពេលហ្នឹង តើលោកចង់មានន័យថាយ៉ាងម៉េចដែរ?

**ឆ៖** បាទ ជួនបបរខ្លះទៅ ជួនដាំខ្លះទៅ។

**ស៖** លោកចង់មានន័យថាម៉េច ដាំហ្នឹង ដាំអីគេ?

**ឆ៖** បាទ បបរ គឺបបរបាយហូបប៉ិៗអ៊ីចឹងទៅ។ ដាំ គឺដាំបាយហូប។

**ស៖** ខ្ញុំចង់ជម្រាបសួរលោកពីខាងដើមហ្នឹង គឺពាក្យថា "មិនគ្រប់គ្រាន់" បានន័យថាម៉េច? ហូបអត់ឆ្អែត ឬក៏លោកប្រៀបធៀបទៅនឹងអ្វីមួយដែលពាក្យថា មិនគ្រប់គ្រាន់ហ្នឹង គ្រាន់ហ្នឹងម៉េច? ហើយម៉េចមិនគ្រប់ហ្នឹងយ៉ាងម៉េច? ចង់សុំឱ្យលោកបញ្ជាក់កន្លែងហ្នឹងឱ្យច្បាស់បន្តិច?

**ឆ៖** បាទ ហូបមិនឆ្អែត បានសេចក្ដីថាមិនគ្រប់គ្រាន់។

**ស៖** តើនៅចន្លោះឆ្នាំដែលលោកនៅឃុំញ៉ែងញ៉ង់ហ្នឹង មានប្រជាជនធ្លាក់ខ្លួនឈឺដែរឬទេ?

**ឆ៖** ប្រជាជនមានឈឺជាបន្តបន្ទាប់បាទ ភាគច្រើនគឺប្រជាជនថ្មី ដែលគាត់មិនធ្លាប់រស់នៅធ្វើការងារពលកម្ម រស់នៅស្រុកស្រែ មានការឈឺជាបន្តបន្ទាប់។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណសាក្សី។ ឥឡូវនេះ ដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីនេះទៅរហូតដល់ម៉ោងមួយសាមសិបនាទីរសៀលនេះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញ ដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឱ្យអញ្ជើញគាត់មកកាន់កន្លែងផ្ដល់សក្ខីកម្មនេះ នៅក្នុងបន្ទប់សវនាការនេះ រួមទាំងមេធាវីប្រឹក្សារបស់គាត់នៅវេលាម៉ោងមួយ និងសាមសិបនាទីរសៀលសនេះ។

ហើយបង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ត្រឡប់ទៅកាន់បន្ទប់រង់ចាំនៅខាងក្រោមសាលសវនាការនេះ និងបង្គាប់ឱ្យនាំខ្លួនគាត់ត្រឡប់មកចូលសវនាការ នៅក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះ ឱ្យបានមុនម៉ោងមួយនិងសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១១:៣៦ នាទី ដល់ម៉ោង ១៣:៣៥ នាទី)*

[១៣:៣៥:១៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

បាទ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនឹងផ្តល់វេទិកាជូនទៅក្រុមសហព្រះរាជអាជ្ញាដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។ សូមអញ្ជើញ។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

សូមអរគុណលោកប្រធាន ជម្រាបសួរភាគីទាំងអស់។

**ស៖** លោកសាក្សីខ្ញុំនឹងសួរលោកក្នុងពេលរសៀលនេះអំពីហេតុការណ៍ដែលបានកើតឡើងនៅចន្លោះឆ្នាំ៧៥ ដល់ ឆ្នាំ៧៨--

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោក រ៉ិចទ័រ កូប៉េ!

**លោក រ៉ិចទ័រ កូប៉េ៖**

ខ្ញុំចង់ដឹងថា តើមានព័ត៌មានអ្វីពាក់ព័ន្ធទៅនឹងកំណត់ហេតុស្តាប់ចម្លើយបន្ថែម ទោះបីជាកំណត់ហេតុស្តាប់ចម្លើយធ្វើឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ឬក៏សំណុំរឿង០០៣, ០០៤ ក៏ដោយ។ ខ្ញុំសង្ឃឹមថាប្រហែលជាក្នុងពេលសម្រាកអាហារថ្ងៃត្រង់ ខាងព្រះរាជអាជ្ញាអាចធ្វើការបង្ហាញព័ត៌មានបន្ថែម ឬក៏ស៊ើបដឹងព័ត៌មានបន្ថែម ហើយនឹងអាចពន្យល់យើងនៅទីនេះបាន។ សូមអរគុណ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

លោកប្រធានយើងបានស្វែងរក ក៏ប៉ុន្តែយើងអត់មានអីផ្តល់ចម្លើយបានទេ។ យើងមានតែកំណត់ហេតុពីរតែប៉ុណ្ណោះនៅក្នុងសំណុំរឿង។ ហើយសំណុំ០០៣, ០០៤ មិនបានផ្តល់ជូនមកឲ្យពួកយើងទេ អ៊ីចឹងយើងអត់មានអីអាចរកអីឃើញបានទេ ក្រៅតែពីកំណត់ហេតុពីរទេ។ ហើយកិច្ចសម្ភាសន៍ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជាក៏អត់មានដែរ នៅក្នុងវេបសាយរបស់ ឌី.ស៊ី.ខេម ក៏អត់មាន នៅក្នុងសំណុំរឿងក៏អត់មាន។ អ៊ីចឹងយើងមានតែកំណត់ហេតុពីរដែលបានធ្វើឡើងនៅចំពោះសហចៅក្រមស៊ើបអង្កេត

តែប៉ុណ្ណោះ។

**សួរដោយ លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** លោកសាក្សីដូចដែលខ្ញុំប្រាប់លោកអម្បាញ់មិញអ៊ីចឹង ខ្ញុំនឹងសួរលោក។ ជាដំបូងខ្ញុំចង់សុំឱ្យលោកឆ្លើយបញ្ជាក់។ លោកបានឆ្លើយថាលោកអត់មានឈ្មោះក្រៅ ឬក៏ឈ្មោះបដិវត្តទេនៅក្នុងកំណត់ហេតុលេខ E3/5521 នោះ។ ក៏ប៉ុន្តែលោកៗមានមុខងារផ្លូវការ លោកជាមេឃុំនៅស្រែរនោង។ អ៊ីចឹងតើនៅពេលនោះ កម្មាភិបាលឬក៏ប្រជាជន ហៅលោកយ៉ាងម៉េចដែរ នៅពេលដែលលោកធ្វើការនៅឃុំញ៉ែងញ៉ង និងឃុំស្រែរនោងនោះ?

[១៣:៣៨:០៨]

**លោក នុត នូវ៖**

**ឆ៖** បាទ អរគុណណាស់។ កាលនោះខ្ញុំប្រជាពលរដ្ឋ ហៅខ្ញុំហ្នឹងថា តាៗ អ៊ីចឹង។ ជាទូទៅហៅ “តា”។

**ស៖** អ៊ីចឹង តាហ្នឹង ម៉េចដែរ ជាឈ្មោះបដិវត្តន៍ ឬជាឈ្មោះអី?

**ឆ៖** គេនិយមហៅ “តា” អ៊ីចឹងតែម្តង។ លោកតាៗ អ៊ីចឹង។

**ស៖** គេមានហៅលោកថា តានូវ ទេ គេមានហៅលោកអ៊ីចឹងទេ? តានូវ?

**ឆ៖** ហៅ តានូវ។

**លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

លោកប្រធានខ្ញុំចង់ប្រគល់ឯកសារបីជូនសាក្សី។ ជាដំបូងគឺកំណត់ហេតុពីរ នៅចំពោះមុខអង្គ-- នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ហើយនិងឯកសារមួយទៀតគឺឯកសារលេខ E3/2452 គឺ -- ហើយចំពោះកំណត់ហេតុនោះគឺលេខ E3/5521 និងឯកសារ E319.1.17។ ដូច្នេះ ខ្ញុំសូមការអនុញ្ញាតពីលោកប្រធានដើម្បីប្រគល់ឯកសារទាំងបីនោះជូនទៅសាក្សី។ សូមលោកប្រធានមេត្តាអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

បាទអង្គជំនុំជម្រះអនុញ្ញាត!

[១៣:៤០:១៤]

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** សំណួរទី១ ដែលខ្ញុំចង់សួរទៅលោកពាក់ព័ន្ធនឹងឯកសារE3/2452។ ឯកសារហ្នឹងគឺ

សរសេរដែរអ៊ីចឹងរាងពិបាកមើលបន្តិចហើយ។ ខ្ញុំសូមអាន ERN ពាក់ព័ន្ធ ជាភាសាខ្មែរគឺ00270998, ជាភាសាអង់គ្លេស 00843036, ជាភាសាបារាំង 00872836។ ជាភាសាបារាំង គឺនៅទំព័រខាងក្រោម។ នេះជារបាយការណ៍ចុះថ្ងៃទី៨ ខែតុលា ឆ្នាំ១៩៧៧ ដែលធ្វើនៅស្រែរនោង ហើយមានចុះហត្ថលេខាដោយឈ្មោះ នូវ។ របាយការណ៍និយាយអំពីប្រជាជនថ្មីម្នាក់ឈ្មោះ សែន កែវ មកពីស្រុក១០៩ ដែលបានរត់ចេញពីកងស្រែរនោង ហើយទៅនៅលាយឫរក្នុងរយៈពេល២ថ្ងៃ។ លោកសាក្សីតើលោកអាចជម្រាបអង្គជំនុំជម្រះបានទេថាតើហត្ថលេខានេះ ជាហត្ថលេខារបស់លោក ឬក៏មិនមែន? យើងមើលនៅក្នុងឯកសារហ្នឹងឃើញដាក់ហត្ថលេខាហ្នឹង ដាក់ឈ្មោះថា នូវ អ៊ីចឹង នូវ នេះជាឈ្មោះលោកមែនទេ?

**លោក នុត នូវ៖**

**ឆ៖** បាទ ឯកសារនេះខ្ញុំមើលអត់ឃើញផង។ ហើយការសរសេរនេះ វាមិនមែនជាអក្សរខ្ញុំទៀត អាហ្នឹងសូមជម្រាបអង្គសវនាការ។

**ស៖** អ៊ីចឹងតើមានអ្នកណាម្នាក់ផ្សេងទៀត ដែលធ្វើការនៅស្រែរនោង ហើយឈ្មោះ នូវ ហ្នឹងដែរទេ បើមិនមែនជាលោកនោះ?

**ឆ៖** បាទ ការពិតទៅគ្មានទេ សរសេរនេះ ក្រែងលោអ្នកនៅស្មៀនសរសេរក៏មិនដឹង។ ប៉ុន្តែមិនមែនអក្សរខ្ញុំទេ។

[១៣:៤២:៥០]

**ស៖** ឥឡូវនេះខ្ញុំចូលទៅចំណុចផ្សេងទៀត។ នៅក្នុងកំណត់ហេតុ E3/5521 សូមលោកមេធាវីប្រឹក្សាជួយរកឲ្យគាត់ផងគឺសំណួរចម្លើយ២១៖ "គេឲ្យខ្ញុំទទួលខុសត្រូវផ្នែកប្រមូលស្បៀង ពេលនោះ ខ្ញុំដើរសុំម្ហូបអាហារ អង្ករ ត្រី សាច់ បន្លែ តាមភូមិដើម្បីបញ្ជូនទៅសមរភូមិមុខ។ ក្រៅពីនេះ ខ្ញុំជាអ្នកកត់ត្រា និងធ្វើបញ្ជីនៅក្នុងសាលាឃុំញ៉ែងញ៉ង"។ សូមបញ្ចប់ការដកស្រង់។ តើលោកអាចជម្រាបបានទេថា លោកកត់ត្រា និងធ្វើបញ្ជីនៅសាលាឃុំញ៉ែងញ៉ងហ្នឹងមានន័យថាម៉េច? មានការកត់ត្រាឯកសារអីខ្លះ? ហើយបញ្ជីហ្នឹងមានឯកសារអ្វីខ្លះដែរ?

**ឆ៖** សូមអរគុណ។ ក្នុងការធ្វើបញ្ជី និងកត់ត្រានេះ ចំពោះតួលេខ សេដ្ឋកិច្ចនៅក្នុងឃុំ ចំណូល និងចំណាយដូចជា អង្ករ ត្រី សាច់ បន្លែ ដែលយកពីតាមភូមិ ហើយធ្វើរបាយការណ៍កត់ចំនួនទាំងនេះ និងជូនទៅអង្គភាពនៅសមរភូមិមុខ។ បាទ មានបញ្ជីកត់ត្រា។

**ស៖** សូមអរគុណ។ ចុះអាហ្នឹងចំពោះការកត់ត្រា។ ចុះបញ្ជីនោះ តើលោកធ្វើបញ្ជីអ្វីដែរ លោក

អាចរៀបរាប់លម្អិតអំពីបញ្ជីហ្នឹងបានទេ?

**ឆ៖** ដូចខ្ញុំបានជម្រាបរួចហើយ បញ្ជីនេះគឺកត់ត្រាចំណូល និងចំណាយសេដ្ឋកិច្ច។

**ស៖** ចុះៗរបាយការណ៍ ហើយនិងលិខិតឆ្លើយឆ្លងរវាងឃុំញ៉ែងញ៉ង និងស្រុកហ្នឹង មានរក្សាទុកនៅក្នុងការកត់ត្រាហ្នឹងទេ?

[១៣:៤៥:៣២]

**ឆ៖** ការពិតទៅកាលណាសរសេរហើយ គឺបញ្ជូនលិខិតរបាយការណ៍ទៅស្រុកអត់មានកត់ត្រាទុកទេ អត់បានកត់ត្រាទុកទេ។

**ស៖** ហើយចុះឯកសារដែលមកពីថ្នាក់លើវិញ លោកមានរក្សាទុកក្នុងកំណត់ត្រាហ្នឹងទេ?

**ឆ៖** ឯកសារមកពីថ្នាក់លើ គឺមេឃុំគេអ្នកទទួល ខ្ញុំអត់បានទុកទេ។

**ស៖** អម្បាញ់មិញនេះ លោកនិយាយថាមានការធ្វើបញ្ជីប្រជាជន១៧មេសា និងប្រជាជនមូលដ្ឋាន។ តើលោកផ្ទាល់ជាអ្នករក្សាទុកបញ្ជីហ្នឹង ឬក៏មេឃុំគាត់ជាអ្នករក្សាទុកបញ្ជីឈ្មោះប្រជាជនហ្នឹង?

**ឆ៖** បាទ មេឃុំអ្នកទុក ចំនួនស្ថិតិក្នុងឃុំគឺមេឃុំអ្នកទុក។

**ស៖** ចុះអ្នកណាជាអ្នកធ្វើបញ្ជីហ្នឹងនៅក្នុងឃុំ? ជាអ្នកធ្វើការនៅក្នុងឃុំ ឬក៏ជាឈ្លប ឬក៏ជាអ្នកណាផ្សេង?

**ឆ៖** គេមានអ្នកកត់ត្រាផ្សេង ប៉ុន្តែស្លាប់បាត់ទៅហើយអ្នកកត់ត្រា ជាស្មៀនរបស់ឃុំ។ ខ្ញុំនេះគឺគ្រាន់តែប្រមូលផល ទទួលខាងសេដ្ឋកិច្ចទេ។

**ស៖** តើលោកកាន់បញ្ជីសេដ្ឋកិច្ចហ្នឹងរហូតដល់លោកចេញទៅឃុំញ៉ែងញ៉ងនៅឆ្នាំ១៩៧៧មែនទេ?

**ឆ៖** បាទ។

**ស៖** លោកអាចប្រាប់បានទេ ថានៅពេលណាឲ្យប្រាកដនៅឆ្នាំ៧៧ ហ្នឹងដែលលោកទៅកាន់ឃុំស្រែរនោងហ្នឹង?

**ឆ៖** បាទ កាលដែលខ្ញុំទៅកាន់ឃុំស្រែរនោងហ្នឹង មិនជាចាំប្រាកដទេ ប៉ុន្តែដឹងថាចុងឆ្នាំ៧៧-៧៨ ដើម៧៨។

[១៣:៤៨:៤៤]

**ស៖** នៅពេលដែលលោកនៅឃុំញ៉ែងញ៉ង លោកឆ្លើយនៅក្នុងកំណត់ហេតុ E3/5521 នៅចម្លើយទី២២ លោកថា ប៊ុន ស៊ី ជាលេខាឃុំញ៉ែងញ៉ង។ លោកអាចជម្រាបបានទេថា ប៊ុន ស៊ី ហ្នឹង

នៅជាមេឃុំហ្នឹងយូរទេ ហើយមានអ្នកណាដែលជំនួសគាត់ទេ នៅក្រោយមកទៀតនោះ?

**ឆ៖** ប៊ុន ស៊ី នៅជាមេឃុំរហូតឆ្នាំ១៩៧៧ ត្រូវអង្គការបញ្ជូនទៅខាងខេត្តកំពង់ចាម។ ក្រោយពី ប៊ុន ស៊ី មានអ្នកជំនួស ខ្ញុំទៅស្រែរនោងរួចហើយ គឺលោក តាស៊ុន–ឈ្មោះស៊ុន។

**ស៖** លោកស្គាល់ឈ្មោះ មាន ទេ គាត់នៅឃុំញ៉ែងញ៉ងហ្នឹងដែរ? ហើយប្រសិនបើលោកដឹងថាតើគាត់កាន់មុខងារអ្វីដែរ?

**ឆ៖** លោក មាន ហ្នឹង ស្គាល់ ពិតជាស្គាល់នៅឃុំញ៉ែងញ៉ង ប៉ុន្តែខ្ញុំអត់នៅនឹងទេ ខ្ញុំទៅហួសបាត់ទៅហើយ។ គាត់ជាអនុប្រធានឃុំ។

**ស៖** សូមអរគុណ។ នៅក្នុងកំណត់ហេតុដដែល គឺចម្លើយទី២៩ លោកនិយាយថា៖ “ដំបូងមិនមានការធ្វើប្រវត្តិអ្វីទេ” លោកនិយាយអំពីអ្នក១៧មេសា បន្ទាប់មកទៀតលោកថា៖ “ដល់ក្រោយមកប្រហែលជាមាន”។ ដូច្នេះចម្លើយនេះដូចជាស្រពេចស្រពិល។ ខ្ញុំចង់ដឹងថាតើការធ្វើប្រវត្តិរូបអ្នក១៧មេសា ដែលជម្លៀសមកពីភ្នំពេញហ្នឹង មានត្រូវបានគេធ្វើដែរឬក៏អត់ នៅក្នុងឃុំញ៉ែងញ៉ងហ្នឹង?

[១៣:៥១:២៤]

**ឆ៖** ការធ្វើប្រវត្តិរូបហ្នឹងមានគេចុះផ្សព្វផ្សាយ។ អ្នកដែលធ្វើជាទាហាន ជាអ្វីៗវគ្គផងទាំងពួងហ្នឹង គេថាឲ្យប្រាប់ត្រង់មក គេនឹងឲ្យទៅធ្វើការវិញ។

**ស៖** ដើម្បីបំភ្លឺបញ្ហានេះឲ្យច្បាស់ អ្នកដែលបានឆ្លើយតបទៅនឹងការប្រកាសថាខ្លួនជាអតីតយោធា ជាអតីតមន្ត្រីរដ្ឋការ ឬអតីតគ្រូបង្រៀនក្នុងសម័យលន់នល់នោះ តើគេធ្វើអ្វីដែរចំពោះគាត់ ពួកគាត់នៅពេលដែលពួកគាត់ទៅដល់ឃុំញ៉ែងញ៉ងនៅក្នុងឆ្នាំ១៩៧៥នោះ។ ក្រោយពីគាត់ប្រាប់ពីប្រវត្តិពិតនៃការងាររបស់ខ្លួននោះ?

**ឆ៖** ក្រោយពីគាត់ប្រាប់ការងាររបស់ខ្លួនគាត់ហ្នឹង មានខ្លះនៅ ខ្លះក៏បាត់ខ្លួនជាបន្តបន្ទាប់ បាទអត់មានឃើញទេ។

**ស៖** តើនៅពេលដែលគេប្រកាសហ្នឹង គេមានប្រាប់គាត់ថា ពួកគាត់ថា ពួកគាត់អាចទទួលបានមុខងារដដែល ឬក៏ទៅធ្វើការងារនៅកន្លែងផ្សេង ដើម្បីបម្រើរបបថ្មីទេ?

**ឆ៖** គេគ្រាន់តែប្រាប់ថាឲ្យធ្វើការវិញ។ បាទ អ្នកដែលមានចំណេះខាងគ្រូបង្រៀន ឬក៏ខាងទាហាន ឬក៏ការងារអ្វីវគ្គផងទាំងពួង។

**ស៖** ចំពោះអ្នកដែលបានលាក់ប្រវត្តិរបស់ខ្លួន ដែលថាខ្លួនជាអតីតទាហាន អតីតមន្ត្រីរដ្ឋការ

អតីតគ្រូបង្រៀនហ្នឹង តែពួកគាត់លាក់ប្រវត្តិ។ អ៊ីចឹង នៅពេលដែលគេស្រាវជ្រាវរកទៅឃើញថាពួកគាត់លាក់ ពួកគាត់កុហកអ៊ីចឹង តើគេធ្វើយ៉ាងម៉េចដែរ ចំពោះអ្នកដែលកុហកទាំងអស់ហ្នឹង?

[១៣:៥៤:១៥]

**ឆ៖** ចំពោះអ្នកដែលលាក់ បើគេស្រាវជ្រាវឃើញ អត់មានសកម្មភាពអីប្រឆាំងនឹងបក្សបដិវត្ត គឺគេអត់ធ្វើអីទេ។ បើប្រឆាំង គេយកទៅរៀនសូត្រ។

**ស៖** តើលោកដឹងទេថា នៅពេលដែលគេស្វែងរកឃើញថា នៅក្នុងចំណោមអ្នក១៧មេសាហ្នឹង មានមន្ត្រីជាន់ខ្ពស់ ឬក៏ទាហានជាន់ខ្ពស់នោះ តើគេធ្វើយ៉ាងម៉េចដែរចំពោះអ្នកទាំងអស់ហ្នឹង? គេមានជំរុញឲ្យអ្នកទាំងអស់ហ្នឹង ឆ្លើយប្រាប់ថាខ្លួនជាមន្ត្រីជាន់ខ្ពស់ ឬក៏នាយទាហានជាន់ខ្ពស់នៅសម័យ លន់ នល់ ទេ គេមានជំរុញឲ្យឆ្លើយអ៊ីចឹងទេ?

**ឆ៖** ដូចខ្ញុំបានជម្រាបហើយ អ្នកដែលគេជាមន្ត្រីជាន់ខ្ពស់ក្តី ដែលគ្មានសកម្មភាពប្រឆាំងនឹងបដិវត្ត ឃើញនៅជាហូរហែរអ៊ីចឹង គេអត់មានធ្វើអីទេ។ លុះត្រាតែអ្នកដែលជំទាស់នឹងបដិវត្ត អាហ្នឹងបានគេឲ្យទៅរៀនសូត្រ ដូចជម្រាបខាងដើម។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

លោកប្រធាន ខ្ញុំសូមការអនុញ្ញាតប្រគល់កំណត់ហេតុស្តាប់ចម្លើយរបស់សាក្សី 2-TCW-822 គឺកំណត់លេខ E319.1.1.2។ ខ្ញុំសូមការអនុញ្ញាតពីលោកប្រធាន ដើម្បីប្រគល់ឯកសារនេះជូនសាក្សី ហើយនិងសួរសំណួរ គឺឯកសារលេខ E319.1.32 លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។

[១៣:៥៦:៥៤]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** លោកសាក្សី ខ្ញុំសូមឲ្យលោកមើលទំព័រទី២នៃឯកសារនេះ។ សូមលោកកុំៗបញ្ចេញឈ្មោះសាក្សីរូបនេះ។

លោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេថា លោកស្គាល់ឈ្មោះម្នាក់ហ្នឹងទេ គាត់ធ្វើការនៅ

ស្រុកត្រាំកក់? សូមលោកមើល តែកុំបញ្ចេញឈ្មោះឲ្យសោះ។ គឺខ្ញុំគិត គឺគាត់ប្រហែលជាធ្វើនៅមន្ទីរពាណិជ្ជកម្មនៅត្រាំកក់។

**លោក នុត នូវ៖**

**ឆ៖** បាទ ខ្ញុំអត់ដែលស្គាល់ទេ។

**ស៖** មិនអីទេលោកសាក្សី ខ្ញុំនឹងឲ្យលោកឆ្លើយតបទៅនឹងចម្លើយរបស់គាត់ គឺគាត់ឆ្លើយនូវចម្លើយ១១៣។ សូមលោកបើកទៅទំព័រដែលមានចម្លើយ១១៣។ គេសួរថា៖ “តើលោកដឹងអ្វីខ្លះទាក់ទងនឹងការសម្លាប់ទាហាននិងគ្រួសាររបស់លន់ នល់ នៅស្រុក -- ទាហាន លន់ នល់ នៅខេត្តតាកែវ? ពេលនោះខ្មែរក្រហមប្រកាសជ័យជម្នះថា ឈ្នះហើយភ្នំពេញ។ បន្ទាប់មក គេបានជម្លៀសប្រជាជនពីភ្នំពេញទៅដាក់នៅវត្តចំប៉ាលើក ដែលស្ថិតនៅខាងលិចអង្គតាសោមពាបីគីឡូម៉ែត្រ ក្នុងស្រុកត្រាំកក់។ ក្នុងរយៈពេល៧ថ្ងៃ ខ្មែរក្រហមបានឃោសនាដោយស្វែងរកអ្នកដែលធ្លាប់មានបណ្ដាស័ក្តិឲ្យមកចុះឈ្មោះ។ ខ្មែរ-ក្រហមឃោសនាបានហើយ គេបញ្ជូនមនុស្សទាំងនោះចេញទៅបាត់។ គឺធ្វើដូច្នេះរហូត គឺមានរាប់រយរាប់ពាន់ ត្រូវគេបញ្ជូនចេញទៅបាត់”។ សូមបញ្ចប់ការដកស្រង់។

នៅពេលដែលលោកនិយាយថានៅក្នុងឃុំរបស់លោក គេបានសូមឲ្យយោធា មន្ត្រីរដ្ឋការ ឬក៏គ្រូបង្រៀនឆ្លើយហ្នឹង តើគេមានឲ្យពួកគាត់ទៅចុះឈ្មោះទេ? គេមានធ្វើជាបញ្ជីសម្រាប់ចុះឈ្មោះអ្នកទាំងអស់ហ្នឹងទេ?

**ឆ៖** បាទ ក្នុងករណីនេះ ខ្ញុំបាទមិនបានដឹងផងបាទ។

[១៣:៥៩:៥២]

**ស៖** ដូច្នេះ លោកអត់មានស្ដាប់ឮអំពីហេតុការណ៍ដែលកើតឡើងនៅវត្តចំប៉ាលើកនៅជិតអង្គតាសោមនេះទេមែនទេ បន្ទាប់ពីការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញហើយនោះ?

**ឆ៖** បាទ ពេលនោះ គឺខ្ញុំនៅតែក្នុងមន្ទីរទេ ប៉ុនគេប្រមូលប្រជាជនទៅដាក់នៅចំប៉ាលើក ខ្ញុំអត់បានដឹងដែរ ពីព្រោះពីញ៉ែងញ៉ងទៅកន្លែងហ្នឹងជា១០គីឡូឯណោះ។ ខ្ញុំចាំតែទទួលដែលគេចែកមកតាមឃុំ រកកន្លែងឲ្យគាត់នៅ។

**ស៖** អម្បាញ់មិញលោកឆ្លើយថាអ្នកដែលប្រឆាំងនឹងរបបនោះត្រូវបាត់ខ្លួន។ លោកចង់មានន័យថាម៉េច ពាក្យថា “ប្រឆាំងនឹងរបប”? លោកអាចឆ្លើយបញ្ជាក់ ឬក៏ឧទាហរណ៍បានទេថាមានអ្នកណាខ្លះដែលប្រឆាំងនឹងរបបនោះ?

**ឆ៖** បាទអរគុណក្នុងបញ្ហានេះ។ ពាក្យថា "ប្រឆាំងនឹងរបប" អ្នកដែលមិនឯកភាព ឬមិនស្រឡាញ់បដិវត្តន៍ តែងតែមានការទាស់នូវជាពាក្យ ជាសម្តី ជាអកប្បកិរិយាផ្សេងៗ។

**ស៖** តើអ្នក១៧មេសាហ្នឹង មានច្រើនទេដែលប្រឆាំងនឹងបដិវត្តន៍នោះ?

**ឆ៖** មានតិចតួចដែរទេ។ ភាគច្រើនគឺគេចូលរួមសស្រាក់សស្រាំក្នុងការងារក្នុងសហករណ៍។

**ស៖** ចុះក្នុងចំណោមប្រជាជនមូលដ្ឋាននោះ ពួកគេសប្បាយចិត្តទេក្នុងការធ្វើការក្នុងសហករណ៍ ហូបរួមអីចឹង? ហើយអ្នកមូលដ្ឋានហ្នឹងមានអ្នកណាជំទាស់ទៅនឹងរបបទេ?

[១៤:០២:១៥]

**ឆ៖** ការពិតគឺកាលជំនាន់នោះ គឺមិនមានអ្នកជំទាស់ទេ ជាទូទៅទៅហើយ មិនហ៊ានជំទាស់។ ការនឹកឃើញពិបាកក្នុងការហូប នឹកឃើញដូចតែគ្នា ប៉ុន្តែមិនហ៊ាន។ ទាំងខ្ញុំផ្ទាល់ហ្នឹងក៏មិនហ៊ានថាយ៉ាងម៉េចដែរ ពិបាកហូបយ៉ាងម៉េច ក៏នៅតែចេះតែទ្រាំហូបជាមួយគ្នាទៅ។

**ស៖** ខ្ញុំនឹងត្រឡប់មកនិយាយអំពីចំណុចនេះវិញ ពាក់ព័ន្ធទៅនឹងអ្នករអ៊ូរទាំ ឬក៏អ្នកប្រឆាំងនឹងរបប ក៏ប៉ុន្តែមុននឹងទៅដល់ចំណុចនេះ ខ្ញុំចង់បង្ហាញនូវសម្រង់មួយទៀតនៃកំណត់ហេតុស្តាប់ចម្លើយរបស់មនុស្សម្នាក់ដែលត្រូវបានសហចៅក្រមស៊ើបអង្កេតស្តាប់ចម្លើយគឺឯកសារលេខ E319/12.3.2។ ខ្ញុំសូមប្រគល់ឯកសារនេះជូនទៅសាក្សី ហើយនិងសួរសំណួរដូចឯកសារមុនអីចឹង។ សួរថាតើលោកស្គាល់ឯកសារនេះឬក៏អត់? សូមលោកប្រធានមេត្តាអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាងលេ៖**

**ស៖** សុំលោកមើលឈ្មោះសាក្សីរូបនេះ ដែលសួរដោយសហចៅក្រមស៊ើបអង្កេត ប៉ុន្តែសុំលោកកុំបន្លឺបឈ្មោះ ហើយលោកអាចប្រាប់បានទេថាលោកស្គាល់គាត់ឬក៏អត់ ហើយលោកមានតួនាទីអ្វីដែរនៅស្រុកត្រាំកក់ ហើយនិងនៅក្នុងឃុំត្រាំកក់នោះ?

**លោក នុត នូវ៖**

**ឆ៖** បាទ ខ្ញុំមិនដែលស្គាល់ទេសាក្សីរូបនេះ។

**ស៖** លោកសាក្សី លោកច្បាស់ទេ? គឺគេស្គាល់គាត់ហ្នឹងច្រើនណាស់នៅក្នុងស្រុកហ្នឹង។ អីចឹងនៅពេលដែលលោកនិយាយថាលោកមិនស្គាល់ ខ្ញុំដូចជាភ្ញាក់ផ្អើលបន្តិចដែរ។

[១៤:០៥:០៦]

**ឆ៖** អភ័យទោស អម្បាញ់មិញច្រឡំ មើលឈ្មោះមិនដាច់។ ប៉ុន្តែឈ្មោះនេះ អាចស្គាល់។ បាទ សូមអភ័យទោស សូមអធ្យាស្រ័យ ដោយភ្នែកវាងងឹត មើលមិនសូវឃើញ។

**ស៖** តើសាក្សីហ្នឹងជាមេឃុំមែនទេ នៅក្នុងរបបនោះ?

**ឆ៖** គាត់ជាមេឃុំៗ។

**ស៖** សូមអរគុណ។ ខ្ញុំនឹងអានសំណួរចម្លើយ២៥៤, ២៥៥ នៃឯកសារនេះ។ ខ្ញុំអាននឹងអានជាភាសាអង់គ្លេស ពីព្រោះឯកសារនេះមិនទាន់បានបកប្រែជាភាសាបារាំងទេ។

(អានជាភាសាអង់គ្លេស៖) "សំណួរ២៥៤ ពេលដែលមេឃុំចាប់ផ្តើមប្រមូលប្រវត្តិរូបពីប្រជាជន ហើយរកឃើញថា អ្នកណាម្នាក់ជាប់ពាក់ព័ន្ធរបបលន់ នល់ តើមានអ្វីកើតឡើងចំពោះអ្នកដែលគេរកឃើញថាជាប់ពាក់ព័ន្ធនឹងរបបលន់ នល់ នោះ? ឆ្លើយ២៥៤៖ នៅពេលដែលចាប់ផ្តើមរបបខ្មែរក្រហម ភ្លាម គឺចាប់ផ្តើមធ្វើប្រវត្តិរូប ថាអ្នកណាខ្លះធ្លាប់ជាគ្រូបង្រៀន អ្នកណាជាប៉ូលិស ឬក៏ជាមន្ត្រីរាជការនៅក្នុងរបបលន់នល់។ បន្ទាប់មកបញ្ជូនប្រវត្តិរូបទាំងអស់នេះទៅខាងលើ។ នេះគឺជាបញ្ជាពីខាងលើមកឲ្យខ្ញុំធ្វើដូច្នេះ។ សំណួរ២៥៥៖ តាមអ្វីដែលលោកស្រីដឹង តើមានអ្វីកើតឡើងចំពោះអ្នកដែលពាក់ព័ន្ធនឹងរបបលន់នល់? ឆ្លើយ៖ ក្រោយប្រវត្តិរូបបញ្ជូនទៅលើហើយ ខាងលើបានស្រង់ឈ្មោះអ្នកទាំងនោះមកឲ្យខ្ញុំ។ បន្ទាប់មក ខ្ញុំបញ្ជាឲ្យគេដើរចាប់អ្នកទាំងអស់នោះ រួចបញ្ជូនទៅខាងលើវិញ។ មានអ្នកខ្លះក៏បានត្រឡប់មកវិញ ហើយអ្នកខ្លះក៏មិនបានត្រឡប់មកវិញទេ។ មនុស្សដែលត្រូវចាប់ខ្លួនភាគច្រើនគឺជាទាហាននិងប៉ូលិស គ្រូបង្រៀនមិនស្រូវត្រូវបានបញ្ជូនទៅនោះទេ"។ សូមបញ្ចប់ការដកស្រង់។

[១៤:០៧:៥៦]

ដូច្នេះនៅទីនេះយើងឃើញហើយថា កម្មាភិបាលជាន់ខ្ពស់ខ្មែរក្រហមរូបនេះជាមេឃុំនោះបានបញ្ជាក់ថា ប្រវត្តិរូបត្រូវបានធ្វើឡើងដោយឃុំ គឺវាពាក់ព័ន្ធទៅនឹងគ្រូបង្រៀន នគរបាល ឬមន្ត្រីរាជការលន់ នល់។ ហើយពេលធ្វើហើយ បញ្ជូនទៅថ្នាក់លើ ហើយបន្ទាប់មកទៀតថ្នាក់លើបានប្រាប់ឲ្យមេឃុំចាប់អ្នកដែលពាក់ព័ន្ធនៅក្នុងរបបលន់នល់ ហើយនិងបញ្ជូនទៅឲ្យខាងលើ។ តើបែបបទនេះធ្វើឲ្យលោកនឹកឃើញឡើងវិញទេ ពាក់ព័ន្ធទៅនឹងវិញដែលបានកើតឡើងនៅក្នុងឃុំញ៉ែងញ៉ង បន្ទាប់ពីការជម្លៀសនៅខែមេសា ឆ្នាំ៧៥ គឺបន្ទាប់ពីអ្នកទាំងអស់នោះត្រូវបានមកដល់ក្នុងស្រុកត្រាំកក់នោះ។ លោកមានចងចាំឡើងវិញទេ?

**ឆ៖** បាទ សូមជម្រាបថា ពេលនោះក្រុមជាសេដ្ឋកិច្ចនៅអ្នកមន្ទីរ អត់មានធ្វើបញ្ជីអីទេ គឺខាងឃុំអ្នកធ្វើ មានស្មៀនឃុំ។ ចំពោះខ្ញុំអត់ដែលបានធ្វើជាបញ្ជីប្រវត្តិរូបទាហាន គ្រូបង្រៀន អ្នករាជការកាលជំនាន់នោះទេ។

**ស៖** តើលោកមានបានដឹង ឬក៏ស្តាប់ឮទេថា គេពិតជាធ្វើប្រវត្តិរូបមែន ហើយបន្ទាប់ពីថ្នាក់លើវិភាគទៅលើប្រវត្តិទាំងអស់ហ្នឹងហើយ គេចាប់ខ្លួនមនុស្សមួយចំនួនដែលមានប្រវត្តិរូបនោះ?

**ឆ៖** បាទ មិនយល់សំណួរនេះ មិនយល់។

**ស៖** ខ្ញុំនឹងព្យាយាមសួរឲ្យស្រួលស្តាប់។ លោកធ្លាប់ឮ ឬក៏ធ្លាប់ដឹងទេ នៅពេលដែលលោកធ្វើការនៅឃុំញ៉ែងញ៉ង់ថាគេធ្វើប្រវត្តិរូបប៉ូលិស មន្ត្រីរដ្ឋការ ឬក៏ទាហានលន់នល់ ឬគ្រូបង្រៀននៅសម័យលន់នល់នោះ ហើយបន្ទាប់ពីគេធ្វើហើយគេបញ្ជូនទៅថ្នាក់ស្រុក ក្រោយមកថ្នាក់ស្រុកបានបញ្ជាមកថ្នាក់ឃុំវិញឲ្យចាប់ខ្លួនអ្នកដែលមានពាក់ព័ន្ធនៅក្នុងប្រវត្តិរូបហ្នឹង ដោយខាងឃុំ។ តើមានអ៊ីចឹងទេ?

**ឆ៖** បាទ អរគុណណាស់។ ខ្ញុំគ្រាន់តែឮ ប៉ុន្តែមិនបានឃើញទេ។ ក្នុងការធ្វើនេះគ្រាន់តែឮគេថាធ្វើប្រវត្តិរូប។

[១៤:១១:០៨]

**ស៖** ឥឡូវនេះ ខ្ញុំនឹងសួរសំណួរពាក់ព័ន្ធនឹងឃុំញ៉ែងញ៉ង់ ឃុំស្រែរនោង អង្គតាសោម និងឃុំផ្សេងទៀតនៅស្រុកត្រាំកក់ គឺវានៅឆ្នាំ១៩៧៧ ពីឆ្នាំក្រោយពីការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញហើយមកដល់ស្រុកត្រាំកក់។ ជាដំបូង ខ្ញុំសូមអានកំណត់ហេតុស្តាប់ចម្លើយរបស់លោក គឺឯកសារលេខ E3/5521។ ចម្លើយ៥៧ ដល់៦០។ “ចម្លើយ៥៧៖ នៅក្នុងការប្រជុំគេនិយាយអំពីការបោសសម្អាតខ្មាំងក្នុងជួរនិងខ្មាំងក្រៅជួរ ដែលមាននិន្នាការជាមួយពួក លន់ នល់ ហើយអ្នកដែលនៅក្នុងជួរបក្ស បើមាននិន្នាការមិនល្អក៏មានការបោសសម្អាតដែរ។ សូម្បីតែក្នុងនាមខ្ញុំជាគណៈឃុំក៏មានការភ័យខ្លាចដែរ ព្រោះខ្លាចដើរខុសមាគ៌ារបស់បក្ស។ ខ្មាំងក្នុងជួរ គឺកម្មាភិបាល។ ចំណែកឯខ្មាំងក្រៅជួរ គឺប្រជាជនធម្មតា។ សំណួរទី៥៨៖ “តើការប្រជុំដែលនិយាយអំពីការបោសសម្អាតនេះ នៅក្នុងឆ្នាំណាដែរ? ចម្លើយ៖ ក្នុងឆ្នាំ១៩៧៧ ឬ១៩៧៨។ ទោះបីជាខ្ញុំនៅក្នុងឃុំស្រែរនោងក៏មានការប្រជុំអ៊ីចឹងដែរ។ សំណួរ៦០៖ តើការសម្រេចឲ្យចាប់ គឺជាការសម្រេចរបស់ថ្នាក់ស្រុក ឬថ្នាក់តំបន់? លោកបានឆ្លើយនៅពេលនោះថាប្រហែលជាថ្នាក់តំបន់ទៅភូមិភាគហើយ”។ សូមបញ្ចប់ការដកស្រង់។

ដើម្បីឲ្យមានភាពពេញលេញ ខ្ញុំសូមអានកំណត់ហេតុមួយទៀត ដែលលោកបានឆ្លើយនៅចំពោះ

មុខសហចៅក្រមស៊ើបអង្កេតដែរ គឺឯកសារលេខ E319.1.17។ សំណួរ១៦ ដល់១៨។ “សំណួរទី១៦៖ តើលោកដឹងថា ធ្លាប់មានគេប្រជុំនិយាយអំពីការបោសសម្អាតខ្មាំងដែរឬទេ? ចម្លើយ៖ មានគេនិយាយដែរ នៅពេលប្រជុំថ្នាក់ស្រុក ឬថ្នាក់តំបន់។ ចម្លើយ១៧៖ ខ្ញុំធ្លាប់ប្រជុំជាបន្តបន្ទាប់ដែរ កាលនោះ គេនិយាយពីកម្មាភិបាលដែលធ្វើខុស ដែលស្ទាក់ស្ទើរមិនដើរតាមមាគ៌ាបក្សនោះ គឺត្រូវគេបោសសម្អាត។ តើអ្នកណាដែលនិយាយពីការបោសសម្អាតនោះ ហើយអ្នកណាជាអ្នកបញ្ជាឲ្យបោសសម្អាត? ចម្លើយ១៨៖ អ្នកចេញបញ្ជានោះ គឺចេញពីភូមិភាគតែម្តង ហើយបញ្ជូនបន្តមកថ្នាក់តំបន់ និងថ្នាក់ស្រុក”។ សូមបញ្ចប់ការដកស្រង់។

[១៤:១៤:២៩]

លោកសាក្សីក្នុងឋានៈលោកជាកម្មាភិបាលឃុំញ៉ែងញ៉ង និងជាមេឃុំស្រែរនោង តើលោកបានចូលរួមប្រជុំថ្នាក់ស្រុកត្រាំកក់ហ្នឹងញឹកញាប់ដែរឬទេ? ហើយប្រសិនបើចូលរួមមែននោះ តើលោកចូលរួមប៉ុន្មានដងដែរ ក្នុង១ខែ ក្នុង១ឆ្នាំ?

**ឆ៖** បាទអរគុណណាស់ កាលនៅស្រែរនោង អ៎! កាលនៅញ៉ែងញ៉ង ខ្ញុំគ្មានតួនាទីចូលប្រជុំទេ ព្រោះខ្ញុំវានៅមន្ទីរ ប៉ុន្តែទៅដល់នៅឃុំស្រែរនោង មានការចូលរួមប្រជុំជាមួយថ្នាក់ស្រុក ថ្នាក់តំបន់យ៉ាងហោចណាស់ ក៏១ខែម្តងដងដែរ។ នេះការពិត គឺបានប្រជុំ។ ឯការសម្រេចអ្វីផ្សេងៗក្នុងពិធីបោសសម្អាតកម្ទេចនេះ ខ្ញុំនិយាយដោយស្មោះត្រង់ ខាងឃុំគ្មានតួនាទីបោសសម្អាតទេ។ គេបានណែនាំអីចឹងគឺមានតែតំបន់ និងភូមិភាគ ដែលអាចចាប់ចង និងកម្ទេច។

**ស៖** បាទ លោកសាក្សី តើលោកអាចជម្រាបជូនតុលាការបានដែរឬទេ ថាលោកបានទៅចូលប្រជុំនៅក្នុងស្រុក១០៥ ឬក៏ក្នុងតំបន់១៣ហ្នឹង ដែលមានក្នុងកិច្ចប្រជុំនោះគេនិយាយអំពីការបោសសម្អាតខ្មាំង រួមបញ្ចូលទាំងការបោសសម្អាតអ្នកដែលមានទំនាក់ទំនងជាមួយរបបលន់នល់ផងដែរ។ តើការប្រជុំបែបនេះមានញឹកញាប់ដែរឬទេ ដែលគេនិយាយអំពីករណីទាំងអស់នេះ?

[១៤:១៦:៣១]

**ឆ៖** បាទ អរគុណ។ ក្នុងការប្រជុំនេះ ខ្ញុំឡើងឃុំ ឆ្នាំ១៩៧៨។ កាលនៅមន្ទីរខ្ញុំមិនបានចូលរួមដូចជម្រាបខាងដើម។ ហើយការប្រជុំនេះគេបាននិយាយសំខាន់ ខ្ញុំឡើងទៅគឺការងារធ្វើស្រែឲ្យបាន៣តោនក្នុង១ហិកតា។ សំខាន់គឺផ្តោតទៅលើធ្វើស្រែឲ្យបាន៣តោនក្នុង១ហិកតា។ កម្មាភិបាលដែលដឹកនាំធ្វើមិនបាន គឺឲ្យចុះចេញពីតំណែង។ នេះមានប៉ុណ្ណឹង។

**ស៖** ក៏ប៉ុន្តែលោកនិយាយថានៅក្នុងកិច្ចប្រជុំទាំងអស់ហ្នឹង គេនិយាយអំពីការបោសសម្អាតខ្មាំងក្នុងជួរ និងក្រៅជួរដែលមានសមាជិក ឬមាននិន្នាការទៅខាងលន់នល់ ឬក៏មាននិន្នាការអាក្រក់។ តើលោកអាចចាំបានទេ ថាតើក្នុងថ្នាក់ស្រុក ហើយនិងថ្នាក់តំបន់នោះ គេមានបាននិយាយអំពីខ្មាំង ហើយនិងការបោសសម្អាតខ្មាំងទាំងអស់ហ្នឹងបានដែរឬទេ? លោកអាចប្រាប់ឈ្មោះមេស្រុក ចៅហ្វាយស្រុក ឬក៏ប្រធានតំបន់បានដែរឬទេ?

**ឆ៖** ប្រធានតំបន់កាលនោះមានឈ្មោះ តាសោម ប៉ុនមិនដឹងស្អី សោម គេហៅថា តាសោម ហើយក្រោយមកមានឈ្មោះ តាប្រាក់ ប៉ុន្តែ តាប្រាក់ ហ្នឹងគេចាប់គាត់ទៅ។ អ៊ីចឹងអ្នកមកជំនួសជាខាងក្រោយក្នុងតំបន់ មានឈ្មោះតារ៉ន។ តារ៉ន ហ្នឹងក៏មិនដែលបានជួបបានស្គាល់ទេ ហើយអត់ដែលបានចូលរួមប្រជុំជាមួយគាត់ទេ បាទ។

[១៤:១៨:៥៤]

**ស៖** ក៏ប៉ុន្តែលោកបាននិយាយថាលោកបានចូលរួម ចូលសមាជនៅតំបន់១៣ ពីរដង នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោកមួយគឺឯកសារ E319.1.17 នៅពេលសមាជហ្នឹង។ តើក្នុងចំណោម តាសោម តាប្រាក់ និង តារ៉នហ្នឹង អ្នកណាជាអ្នកដឹកនាំមហាសន្និបាតហ្នឹង ឬក៏កិច្ចប្រជុំហ្នឹង?

**ឆ៖** កិច្ចប្រជុំគឺ តាសោម គាត់អ្នកដឹកនាំ។

**ស៖** បាទ ឥឡូវខ្ញុំសូមបង្ហាញឯកសារមួយចំនួនជូនលោកទាំងអស់តែម្តង ព្រោះថានៅក្នុងឯកសារហ្នឹង សំណុំឯកសារមានរបាយការណ៍មួយចំនួនដែលមកពីស្រុកត្រាំកក់ ដែលទាក់ទងនឹងការចាប់យោធានៅសម័យលន់នល់ដែលមានស័ក្តិធំ។ ខ្ញុំចង់ចោទសំណួរទៅលោកទាក់ទងទៅនឹងរបាយ-ការណ៍ទាំងអស់នេះគឺមានបួនឯកសារ ដែលខ្ញុំចង់បង្ហាញជូនលោក ហើយនិងសុំការអនុញ្ញាតពីអង្គជំនុំជម្រះដើម្បីបង្ហាញឯកសារទាំងអស់នេះគឺឯកសារ E3/2048, E3/2917, E3/2432 ហើយនិង E3/2450។ បាទលោកប្រធានតើខ្ញុំអាចប្រគល់ឯកសារនេះជូនទៅសាក្សី និងសុំការអនុញ្ញាតបញ្ចាំងឯកសារនេះៗជាបន្តបន្ទាប់ជូនសាក្សីមើល លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ បាន អង្គជំនុំជម្រះអនុញ្ញាត។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** បាទ គឺឯកសារដំបូងគេគឺ E3/2048 ទំព័រជាភាសាខ្មែរគឺ 00079089, ឯកសារ ERN

ជាភាសាអង់គ្លេសគឺ 00276562 ទៅដល់ 63, ជាភាសាបារាំងគឺទំព័រទី២ គឺ ERN គឺ 00611659។ នេះគឺជារបាយការណ៍របស់មឿន។ មឿនជាអ្នកធ្វើរបាយការណ៍នេះចេញមកពីឃុំជាងទង ផ្ញើជូននៅថ្ងៃទី៣០ មេសា ឆ្នាំ១៩៧៨ អ៎! ៧៧ ទៅថ្នាក់ដឹកនាំអង្គការស្រុកត្រាំកក់ដែលមានសរសេរដូចតទៅនេះ ខ្ញុំសូមដកស្រង់៖ “ទាក់ទងទៅនឹងស្ថានភាពខ្មាំងនៅស្រុកត្រាំកក់ នៅមូលដ្ឋានយើងខ្ញុំក្រោយពីទទួលបានការណែនាំជាបន្តបន្ទាប់ពីអង្គការក្នុងការប្រុងប្រយ័ត្នចំពោះខ្មាំង និងការបោសសម្អាតពួកទាហានខ្មាំងដែលមានបណ្តាស័ក្តិ ក្នុងការតាមដាននិងពិនិត្យ ឃើញមានឈ្មោះដូចខាងក្រោមនេះ”។ សូមបញ្ចប់ការដកស្រង់។

[១៤:២២:៤៤]

បាទ ឯកសារទី២ បាទគឺលេខយោងឯកសារដដែលទេ ប៉ុន្តែទំព័រក្រោយហ្នឹងមួយទំព័រ។ គឺឯកសារE3/2048, ERNជាភាសាខ្មែរគឺ 00079091, ជាភាសាអង់គ្លេសគឺ 00276564, ជាភាសាបារាំង 00611661។ អានេះជារបាយការណ៍ចេញពី ឃុំតាភេម ផ្ញើនៅក្នុងរយៈពេលដដែល ត្រង់កន្លែងនេះចុះថ្ងៃទី២៨ មេសា ឆ្នាំ១៩៧៨ ដែលរៀបរាប់ថាឃុំ -- ខ្ញុំសូមដកស្រង់៖ “បន្ទាប់ពីបានទទួលបទបញ្ជា សេចក្តីណែនាំពីបក្ស បានពិនិត្យនិងសម្អាតខ្មាំងដែលជាអ្នកមានបណ្តាស័ក្តិ”។ សូមបញ្ចប់ការដកស្រង់។

បាទឯកសារបន្ទាប់ទៀតនេះគឺឯកសារ E3/2917 ជាភាសា ERN ជាភាសាខ្មែរគឺ 00079090 បាទ ខ្ញុំគិតថាដូចជាមានការច្រឡំហើយ។ ERN ជាភាសាអង់គ្លេសគឺ 00742890 ហើយជាភាសាបារាំងគឺ 00810574។ បាទលោក -- ឯកសារនោះគឺមានតែមួយទំព័រទេចំពោះលោកហ្នឹង នេះគឺជារបាយការណ៍ចេញពីឃុំពពេល ដែលរៀបរាប់ថានៅថ្ងៃទី៤ ឧសភា ឆ្នាំ១៩៧៧ គឺបី -- ពីរបីថ្ងៃក្រោយពីរបាយការណ៍ទាំងពីរដែលខ្ញុំបានរៀបរាប់អម្បាញ់មិញ “គឺថាក្រុមគ្រួសារយោធាដែលស្លាប់ ឬត្រូវបានកម្ទេចដោយអង្គការ មាន១០៦គ្រួសារ គឺត្រូវនឹង៣៩៣នាក់”។ របាយការណ៍ហ្នឹងក៏រៀបរាប់ផងដែរគឺថា “ឃុំខំព្យាយាមកំណត់អត្តសញ្ញាណពួកគេក្នុងចំណោមក្រុមគ្រួសារផ្សេងទៀត ដើម្បីឲ្យដឹងថាពួកគេជាគ្រួសារយោធា ឬក៏អត់”។

[១៤:២៥:១៤]

បាទ របាយការណ៍ទី៤ ដែលមានលេខ E3/2432 មានតែមួយទំព័រទេ របាយការណ៍នេះ។ នេះជា -- ហ្នឹងជាបញ្ជីដែលចុះថ្ងៃទី១៨ មេសា ដែលធ្វើដោយឃុំញ៉ែងញ៉ង ដែលបានកំណត់សញ្ញាណ

យោធាមានឋានន្តរស័ក្តិចំនួន១១នាក់នៃរបបលន់នល់។ ដូចមានមេបញ្ជាពីរនាក់ ស័ក្តិ២ ប្រាំនាក់ ហើយ និងស័ក្តិ៣ ស័ក្តិ២ -- អ៎! ស័ក្តិ១ (សូមទោស) ស័ក្តិ១ បួននាក់ ហើយនិង -- ហើយមានឯកសារមួយទៀត គឺឯកសារ E3/2450, ERN ជាភាសាខ្មែរគឺ 00270746, ជាភាសាអង់គ្លេសគឺ 00322161, ជាភាសាបារាំងគឺ 00623747 គឺជាលិខិតរបស់មេឃុំញ៉ែងញ៉ង ឬក៏ជារបស់អនុប្រធាន គាត់ដែលឈ្មោះ មាន ដែលផ្ញើទៅប្រធានមន្ទីរសន្តិសុខក្រាំងតាចាន់ ដែលបានកំណត់អតីតទាហានលន់នល់បីនាក់ នាយទាហានបីនាក់ គឺមានស័ក្តិ២ ពីរនាក់ ស័ក្តិ១ម្នាក់ ដែលត្រូវបានគេផ្ញើទៅមន្ទីសន្តិសុខបន្ទាប់ពីអង្គការចេញសេចក្តីសម្រេច។ ឯកសារសរសេរដូចតទៅ ខ្ញុំសូមដកស្រង់៖ “ទាក់ទងទៅនឹងកំហុសពួកវាមិនមានអីធ្ងន់ធ្ងរនោះទេ។ ពួកនេះត្រូវបានចាប់ខ្លួន ពីព្រោះវាមានឋានន្តរស័ក្តិខ្ពស់”។ សូមបញ្ចប់ការដកស្រង់។ បាទខ្ញុំមានសំណួរពីរបី។ តើសម្រង់ទាំងប្រាំនៃឯកសារទាំងបួននេះ ធ្វើឲ្យលោកនឹកឃើញពីទាក់ទងទៅនឹងការណែនាំ មានការណែនាំជាក់លាក់ ដែលស្រុកត្រាំកក់ផ្តល់ឲ្យទៅឃុំនៅឆ្នាំ១៩៧៧ ទាក់ទងទៅនឹងការកំណត់សញ្ញាណជាដើម ការធ្វើបញ្ជី ការតាមដានទាហានជាដើម។ តើមានទេករណីហ្នឹង កាលសម័យនោះ?

[១៤:២៧:៥៤]

**ឆ៖** បាទ ចំពោះនៅឃុំខ្ញុំគឺគ្មាន។ នេះជាឃុំដទៃដែលគេគ្រប់គ្រង ខ្ញុំមិនដែលបានចូលរួមទេ។ មានឃុំជាងទង ឃុំពពេល ឃុំញ៉ែងញ៉ងនេះ គឺខ្ញុំចេញរួចទៅហើយ។ សូមអរគុណ។

**ស៖** តើនៅពេលកិច្ចប្រជុំ នៅពេលដែលលោកជាមេឃុំនៅពេលនោះ នៅឃុំស្រែរនោង នៅឆ្នាំ១៩៧៨។ នៅពេលប្រជុំ តើលោកមានឲ្យសេចក្តីណែនាំច្បាស់លាស់ទាក់ទងទៅនឹងរបាយការណ៍ដែលត្រូវធ្វើទាក់ទងទៅនឹងអតីតយោធា មានឋានន្តរសក្តិខ្ពស់នៃរបបលន់នល់នេះ ដែរឬទេ?

**ឆ៖** បាទ អរគុណណាស់ក្នុងបញ្ហានេះ។ ចំពោះក្រុមដែលឡើងទៅឃុំស្រែរនោង គឺមេឃុំមុនគេបានបោសសម្អាតរួចទៅស្រេចទៅហើយ។ បើអ៊ីចឹងខ្ញុំទៅនេះ គឺអត់មានចាប់ចង ឬធ្វើទោស ទុក្ខទោសដល់ជនណាម្នាក់ទេ នៅឃុំស្រែរនោង ឆ្នាំ១៩៧៨។

**ស៖** ក៏ប៉ុន្តែខ្ញុំបានដកស្រង់របាយការណ៍នៃឃុំផ្សេងៗទៀត។ កាលនោះ អំមិញនោះ មានវានៅឃុំជាងទង គឺរបាយការណ៍ចុះថ្ងៃទី៣០ មេសា ឆ្នាំ១៩៧៧។ នៅឃុំតាភេម នៅថ្ងៃទី២០ មេសា ៧៨ ហើយនិងឃុំពពេល ៧៧។ ឃុំញ៉ែងញ៉ងនោះ គឺនៅថ្ងៃទី១៧ មេសា ប៉ុន្តែអត់ឃើញចុះឈ្មោះ -- ចុះឆ្នាំទេ។ របាយការណ៍ហ្នឹង គឺថាធ្វើពីឃុំផ្សេងៗទៀត ធ្វើនៅរយៈពេលតែមួយ ហើយនៅក្នុងពេលហ្នឹង

លោកជាមេឃុំញ៉ែងញ៉ង។ ឥឡូវនេះលោកនិយាយថា រឿងហ្នឹងបានកើតឡើងនៅពេលដែលលោកចេញពីឃុំហើយ ហើយអ៊ីចឹងសួរថាតើនៅពេលលោកនៅហ្នឹង លោកមានឮគេនិយាយពីការបោសសម្អាតអ្នកដែលមានឋានន្តរសក្តិធំនៃរបបលន់នល់ទេ ពេលដែលដល់ស្រែរនោងនោះ?

[១៤:៣០:២៨]

**ឆ៖** បាទ សរសេរនៅញ៉ែងញ៉ងមែន ប៉ុន្តែកាលនោះខ្ញុំមិនមែនមេឃុំទេ សូមជម្រាប។ ខ្ញុំជាសេដ្ឋកិច្ចឃុំ មេឃុំឈ្មោះផ្សេង។ កិច្ចការអ្វីពាក់ព័ន្ធទាំងពួង គេអត់ប្រាប់អ្នកនៅមន្ទីរទេ គេធ្វើតែការងារគេ។

**ស៖** តើពាក្យ "សម្អាត"នេះ –"បោសសម្អាត" គេប្រើច្រើនដងដែរឬទេ នៅពេលកិច្ចប្រជុំនោះ? ហើយនៅសម័យខ្មែរក្រហមនុ៎ង មានន័យថាយ៉ាងម៉េចដែរ លោកដឹងពាក្យហ្នឹងមានន័យថាម៉េចទេ "បោសសម្អាត"ហ្នឹង?

**ឆ៖** ការបោសសម្អាតនេះគឺគេសម្អាតផ្ទៃក្នុងជួរ។ ទី១ អ្នកដែលមិនស្មោះត្រង់នឹងបក្ស។ អ៊ីចឹងគេត្រូវបោសសម្អាតចេញពីក្នុងជួរ។ ទោះបីតែមេឃុំក្តី សមាជិកក្តី មេឃុំក្តី ក៏តែងតែមានការបោសសម្អាតដូចតែគ្នា។ ចំពោះខ្លួនខ្ញុំ មានការព្រួយបារម្ភដែរ អ៊ីចឹងខិតខំធ្វើការ១ថ្ងៃៗដូចប្រជាជនដទៃដែរ។ ចូលរួមក្នុងការប្រមែប្រមូលជីធម្មជាតិ ដើម្បីសម្រេចភារកិច្ច៣តោន ព្រោះខ្លាចបាទ។

**ស៖** ដើម្បីឲ្យច្បាស់តែម្តង នៅពេលដែលលោកនិយាយថាបោសសម្អាតឲ្យស្អាត គឺមានន័យថាចង់បានន័យថា បោសសម្អាតនៅក្នុងជួរ។ ហ្នឹងគឺចង់និយាយថាម៉េច ចង់និយាយថា អ្នកដែលនៅក្នុងជួរហ្នឹង ត្រូវបានគេកម្ទេចោល ឬក៏យ៉ាងណា?

[១៤:៣២:៣៤]

**ឆ៖** នៅក្នុងជួរ ព្រោះមានគេចាប់ជាបន្តបន្ទាប់។

**ស៖** នៅពេលពួកនុ៎ងត្រូវបានគេចាប់ខ្លួនហើយ តើគេមានជោគវាសនាយ៉ាងណាដែរ? តើពេលក្រោយមកហ្នឹង គេមានបានឃើញមុខពួកគាត់វិញទេ?

**ឆ៖** ជារួម ភាគច្រើន អត់ឃើញទេ។ ដូចថានៅស្រែរនោង មុនខ្ញុំទៅ គេដកឃុន – ដកតាឃុនហ្នឹង ដកហ្នឹង គឺអត់បានឃើញគ្នារហូតមកទេ មិនដឹងគេដកទៅទុកកន្លែងណា។

**ស៖** ឥឡូវនេះ ខ្ញុំសូមដកស្រង់ដោយមិនបាច់ផ្តល់ឯកសារទេ គឺថាសាក្សី 2-TCW-860 ក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់គាត់ គឺ E3/5511 ចម្លើយទី៩ គាត់ឆ្លើយដូចតទៅនេះ ខ្ញុំគ្រាន់តែផ្តល់ពី

បរិបទទេ គឺថាគាត់ជាអនុប្រធានពេទ្យស្រុកត្រាំកក់។ នៅចម្លើយទី៩ របស់គាត់ហ្នឹង គាត់ពណ៌នាអំពីមហាសន្និបាតមួយនៅក្នុង*ឌីសស្ត្រិច* ដែលកម្មាភិបាលទាំងអស់ត្រូវបានគេផ្តល់ដំណឹង ជូនដំណឹងអំពីប្រភេទមនុស្សដែលត្រូវបោសសម្អាត។ គាត់និយាយដូចតទៅនេះ៖ “ប្រជាជនដែលគេកំណត់ត្រូវកម្ទេចនោះ នៅផ្នែកយោធាដែលមានតំណែងចាប់ពីថ្នាក់អាស៊ីដង់ឡើងទៅ។ ហើយចំពោះអ្នកដែលធ្វើការនៅក្នុងផ្នែករដ្ឋបាល គឺចាប់ពីជំទប់ទី១ឡើងទៅ”។ បាទសូមបញ្ចប់ការដកស្រង់។

[១៤:៣៤:៤៦]

បាទ លោកនិយាយថាការបោសសម្អាតនៅស្រែរនោងនោះ ត្រូវបានធ្វើរួចហើយនៅពេលលោកទៅដល់នោះ។ តើលោករូបលោកផ្ទាល់នោះ លោកមានបានចូលរួមសន្និបាតនៅក្នុងស្រុកនោះ ដល់ពេលដែលគេកំណត់ថាប្រភេទមនុស្សប្រភេទណាដែលត្រូវ -- នៅក្នុងចំណោមអតីតទាហានលន់នល់ ហើយនិងមន្ត្រីរដ្ឋការនុង់ដែលត្រូវបោសសម្អាតនោះ?

**ឆ៖** កន្លែងនេះ ខ្ញុំមិនបានចាំពិតទេ ព្រោះគិតអាយុកាលជំនាន់នោះខ្ទង់៣០ ហើយមកនេះជាង៣០ឆ្នាំហើយ វាអាចភ្លេចភ្លាំងខ្លះដោយមិនបានត្រៀមទុក។ បាទសូមអរគុណ។

**ស៖** អម្បាញ់មិញលោកនិយាយពីមហាសន្និបាតមួយនៅតំបន់១៣ ដែលដឹកនាំដោយ តាសោម តើនៅ -- តាសោមហ្នឹងគាត់បានដឹកនាំមហាសន្និបាតប្រភេទហ្នឹងនៅឆ្នាំណា? ជាពិសេសសន្និបាតដែលលោកបានចូលរួមហ្នឹងណា នៅឆ្នាំណាដែរ?

**ឆ៖** នៅក្នុងឆ្នាំ១៩៧៧ និងឆ្នាំ១៩៧៨។

[១៤:៣៦:៣១]

**ស៖** តើវាល់ដងហ្នឹង តាសោម ជាអ្នកដឹកនាំមហាសន្និបាតហ្នឹង ក្នុងឆ្នាំ៧៧ក៏គាត់អ្នកធ្វើ ៧៨ក៏គាត់ធ្វើ។ អម្បាញ់មិញលោកនិយាយថា តាសោម មានអ្នកឡើងជំនួសគាត់ជាច្រើននាក់ មានតាប្រាក់ ហើយនិង តារ៉ន។ អ៊ីចឹង លោកអាចបញ្ជាក់បានទេថា តាសោម ហ្នឹងគាត់ជាអ្នកដឹកនាំសន្និបាតទាំងពីរដងហ្នឹង ឬក៏មានអ្នកផ្សេងទៀត?

**ឆ៖** បាទ សូមជម្រាបថា តារ៉ន និងតាប្រាក់ មិនដែលទេ មិនដែលធ្វើសន្និបាតទេគាត់ឡើងមក។ តាប្រាក់ ឡើងមកតំបន់តាកែវហ្នឹងបានតែ៣ខែ វាចាប់គាត់បាត់ទៅ បាទ។ ឯតារ៉ន ឡើងមកបាន -- ខ្ញុំមិនច្បាស់ មិនដឹងប៉ុន្មានខែទេ គាត់ទៅសន្និបាតនៅភ្នំពេញ ត្រូវរទេះភ្លើងបុកបាក់ជើងខូចទៅ។ បាទ ហើយឡើងក្រោយៗមក អត់ដែលធ្វើសន្និបាតទេ ដែលធ្វើជំនាន់ តាសោម។

**ស៖** តើមានអ្នកណាឡើងជំនួស តារ៉ន ទេ ក្រោយពីពេលដែលគាត់មានគ្រោះថ្នាក់មកហ្នឹង?

**ឆ៖** ឡើងជំនួសហ្នឹងមានជំនួសតារ៉ន តាទិត្យ គេហៅតាទិត្យ ហ្នឹង មិនដឹងជាស្អី ទិត្យ ទេ។ ខ្ញុំមិនបានស្គាល់ប្រាកដទេ។ ក្រោយពី តាទិត្យ ឡើងទៅណាបាត់ទៅ គេដាក់ តាគិត ម្តង – តាគិត។

[១៤:៣៨:៣៤]

**ស៖** បាទ ខ្ញុំយល់ហើយថា ការទាក់ទងកាលបរិច្ឆេទហ្នឹងជាការលំបាក ព្រោះថាពេលវេលាកន្លងផុតទៅ៤០ឆ្នាំហើយ។ ខ្ញុំសុំនិយាយពីអ្នកដែលប្រឆាំងអង្គការនៅក្នុងឃុំញ៉ែងញ៉ង ហើយនិងស្រែរនោង នៅចម្លើយទី៣០ នៃកំណត់ហេតុស្តាប់ចម្លើយរបស់លោកគឺឯកសារ E3/5521 លោកឆ្លើយថា៖ "អ្នកដែលមិនយល់ស្រប ឬក៏បង្ហាញថាខ្លួនឯងប្រឆាំងអ្វីនោះពួកគេត្រូវបានគេបញ្ជូនទៅរៀនសូត្រដើម្បីអប់រំ ហើយអ្នកទាំងអស់នោះមិនដែលឃើញត្រឡប់មកវិញទេ"។ មុនពេលសម្រាកនេះ ខ្ញុំសុំផ្តល់ឯកសារ ហើយនិងបញ្ចាំងឯកសារទៅលើអេក្រង់គឺឯកសារ E3/409 -- បាទសុំទោសគឺឯកសារ E3/4098។ លោកប្រធានខ្ញុំសុំអនុញ្ញាតជូនឯកសារនេះទៅសាក្សី និងបញ្ចាំងផងលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** បាទ ERN ជាភាសាខ្មែរគឺ 00271030 រហូតដល់ 31, ជាភាសាអង់គ្លេសគឺ 003221 14 ដល់15, ជាភាសាបារាំងគឺ 00623837 ទៅដល់38។ នេះគឺជារបាយការណ៍ចុះថ្ងៃទី៤ សីហា ឆ្នាំ១៩៧៦ ផ្ញើទៅបក្ស ផ្ញើដោយតាអាន -- តាអាន់ (សូមទោស) ដែលជាប្រធានមន្ទីរក្រាំងតាចាន់ ស្តីអំពីចម្លើយសារភាពរបស់អ្នកទោស។ របាយការណ៍នេះពិភាក្សាអំពីករណីអ្នកទោសម្នាក់នៅក្នុងឃុំញ៉ែងញ៉ង មានឈ្មោះថា តោន ទៀន។ នៅក្នុងរបាយការណ៍នេះ គឺបង្ហាញថា តោន ទៀន នេះធ្វើការរិះគន់ ហើយនិងមិនគោរពរបបកម្ពុជាប្រជាធិបតេយ្យនៅក្នុងកិច្ចប្រជុំក្នុងឃុំ ហើយគាត់ត្រូវបានគេបបួលឲ្យរត់ទៅប្រទេសថៃ។ នៅចំណុចខាងឆ្វេងមានចំណារមួយដែលលើកឡើងដូចតទៅនេះ ខ្ញុំសូមដកស្រង់. "បន្ទាប់ពីការសួរចម្លើយវា ត្រូវតែសម្លាប់ -- ត្រូវកម្ទេច"។ សូមបញ្ចប់ការដកស្រង់។ តើលោកស្គាល់ឈ្មោះ ទាន់ ទៀន (សូមទោស) ទាន់ ទៀន នេះទេ ដែលមុនរបបកម្ពុជាប្រជាធិបតេយ្យហ្នឹង គាត់ធ្វើការជាអ្នកលក់ថ្នាំនៅក្នុងហ្វាម៉ាស៊ីមួយនៅក្នុងភូមិឫស្សី ក្នុងឃុំញ៉ែងញ៉ង។ តើលោកស្គាល់ឈ្មោះ ទាន់ ទៀន នេះទេ?

[១៤:៤១:៥៣]

**លោក នុត នូវ៖**

**ឆ៖** ការពិតទៅ ខ្ញុំអត់បានស្គាល់ទេ ទាន់ ទៀន នេះប៉ុន្តែឮគេហៅ ទៀនៗ មួយនៅឫស្សីស្រុក ពីសង្គមចាស់ហ្នឹង ឃើញថាឈ្មោះ ទៀន – ទាន់ ទៀនហ្នឹង។ ប៉ុន្តែដល់ក្រោយមក ខ្ញុំអត់ស្គាល់ទេ។

**ស៖** តើករណី ទាន់ ទៀន ដែលគាត់បានរិះគន់ ឬក៏គេបកស្រាយថា ជាការមិនគោរពរបបហ្នឹង អ៊ីចឹងតើប្រភេទ -- ចង់និយាយថាក្នុងឃុំមួយៗហ្នឹង គឺថានៅប្រភេទការរិះគន់បែបណា ដែលគេចាត់ទុកថាជាគ្រប់គ្រាន់ ដើម្បីចាប់ខ្លួនហ្នឹង ហើយយកទៅសម្លាប់ជាដើមនៅពេលក្រោយ?

**ឆ៖** បាទ ចំពោះការរិះគន់នេះ--

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញ លោក វ៉ិចទ័រ កូប៉េ!

[១៤:៤៣:១២]

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ ខ្ញុំសូមជំទាស់ទៅលើសំណួរនេះ។ ជាដំបូង គឺសាក្សីមិនដឹងអំពីឯកសារនេះទេ។ ទី២ គឺមានការទាយស្មានយ៉ាងច្រើននៅក្នុងចម្លើយដែលថាមនុស្សជាច្រើនត្រូវបានគេសម្លាប់ ហើយខ្ញុំគិតថាសំណួរដែលលើកឡើងដោយព្រះរាជអាជ្ញានេះ គឺជាសំណួរនាំមុខ មិនគួរជាសំណួរនាំមុខ ហើយត្រូវផ្អែកទៅលើចម្លើយ។ ដូច្នេះខ្ញុំសូមជំទាស់ទៅលើបណ្តុំនៃការសួរសំណួររបៀបនេះ។

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

លោកប្រធាន ខ្ញុំសូមឆ្លើយតប។ ពីព្រោះថា ខ្ញុំដកស្រង់អ្វីដែលលោកសាក្សីបាននិយាយទាក់ទងនឹងការសម្តែងការប្រឆាំងណាមួយ ដែលថាគាត់មិនស្របនឹងរបបហ្នឹង ហើយបន្ទាប់មកគេបញ្ជូនគាត់ទៅអប់រំ ហើយអត់មានឃើញត្រឡប់មកវិញទេ។ អ៊ីចឹងខ្ញុំមានសិទ្ធិក្នុងសួរគាត់ថា រឿងអ្នកទោសម្នាក់ហ្នឹងដែលគាត់បានរិះគន់ប្រព័ន្ធ ឬក៏របបមួយហ្នឹង គ្រាន់តែរិះគន់ហ្នឹង វាជាគ្រប់គ្រាន់ដើម្បីឲ្យគេចាប់ខ្លួន ហើយយកទៅសម្លាប់ចោលនៅក្នុងឃុំដែលគាត់ធ្វើការហ្នឹង លោកប្រធាន គ្រាន់តែចង់សួរប៉ុណ្ណឹងទេ គ្រាន់តែរិះគន់ប៉ុណ្ណឹងជាការគ្រប់គ្រាន់ ឬក៏យ៉ាងម៉េច?

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះបដិសេធនូវសេចក្តីជំទាស់របស់មេធាវីការពារក្តី នួន ជា ចំពោះសំណួរនេះ ហើយអង្គជំនុំជម្រះត្រូវការស្តាប់នូវចម្លើយតបរបស់សាក្សីចំពោះសំណួរដែលសួរចុងក្រោយដោយសហព្រះរាជអាជ្ញាអន្តរជាតិ។

សាក្សីសូមឆ្លើយតបនឹងសំណួរចុងក្រោយនេះ!

[១៤:៤៤:៥៥]

**លោក នុត នូវ៖**

ខ្ញុំភ្លេចបាត់អស់ហើយ។ សូមជម្រាបដូចច្រឡំភ្លេចភ្លាំងបាត់សំណួរ។

**ប្រធានអង្គជំនុំ៖**

សហព្រះរាជអាជ្ញារងអន្តរជាតិសូមតាំងសំណួរជាថ្មីម្តងទៀត។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្វាឯល៖**

**ស៖** បាទ លោកសាក្សី ខ្ញុំចង់សួរលោកថា តើរិះគន់របបនុ៎ង ឬក៏អ្វីដែលគេថា គេបកស្រាយថាមិនគោរពរបបហ្នឹងៗ ជាការគ្រប់គ្រាន់ហើយដើម្បីឲ្យគេចាប់ខ្លួន ហើយយកទៅសម្លាប់នៅក្នុងឃុំញ៉ែងញ៉ង់ហ្នឹង ឬក៏នៅក្នុងឃុំផ្សេងទៀតនៃស្រុកត្រាំកក់ដែលលោកស្គាល់ហ្នឹង។ អ៊ីចឹង ខ្ញុំចង់សួរថា តើគ្រាន់តែរិះគន់ហ្នឹង ឬក៏គេបកស្រាយថាយើងរិះគន់ហ្នឹងជាការគ្រប់គ្រាន់ ឬក៏យ៉ាងម៉េចដើម្បីចាប់យើងយកទៅសម្លាប់ចោល?

**លោក នុត នូវ៖**

**ឆ៖** បាទ អារឿងនេះ ខ្ញុំមិនបានទទួលដឹងទេ ព្រោះជារឿងឃុំផ្សេង។ ខ្ញុំអត់នៅឃុំញ៉ែងញ៉ង់ទេកាលជំនាន់នុ៎ង គឺខាងមេឃុំញ៉ែងញ៉ង់ផ្សេង ដែលគេសម្រេចថាយ៉ាងម៉េចយ៉ាងម៉ា ខ្ញុំមិនបានដឹង ហើយក៏មិនបានយល់ដែរក្នុងសំណួរនេះ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណសាក្សី។

សហព្រះរាជអាជ្ញារង ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅទៅរហូតដល់ម៉ោងបីនិងប្រាំនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នក

ជំនាញ ដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់រួមទាំងមេធាវីប្រឹក្សារបស់គាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញ នៅវេលាម៉ោងបី និងប្រាំនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤៧ នាទី ដល់ម៉ោង ១៥:០៨ នាទី)*

[១៥:០៨:៥៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញាដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** លោកសាក្សីខ្ញុំសូមត្រឡប់មកនិយាយអំពីអ្វីដែលលោកបាននិយាយ ទាក់ទងទៅនឹងការប្រជុំមួយចំនួនដែលលោកបានចូលរួមនៅក្នុងតំបន់១៣។ កិច្ចប្រជុំដែលដឹកនាំដោយ តាសោម ហើយលោកបាននិយាយយ៉ាងដូច្នេះនៅពេលនោះគេនិយាយអំពីការបោសសម្អាតខ្មាំងក្នុងជួរនិងក្រៅជួរ ហើយនិងអ្នកដែលមាននិន្នាការ ទៅរបបលន់ នល់ ឬក៏មាននិន្នាការមិនល្អ។ តើលោកអាចជម្រាបជូនតុលាការបានដែរឬទេ? លោកសូមព្យាយាមចងចាំឡើងវិញនូវពាក្យពេចន៍ជាក់លាក់ដែលតាសោម និយាយទាក់ទងទៅនឹងខ្មាំង។ អ៊ីចឹងសូមលោកព្យាយាមនឹកឡើងវិញ តើគាត់បាននិយាយអីជាក់លាក់ទាក់ទងនឹងខ្មាំងនេះ? សូមអរគុណ។

**លោក នុត នូវ៖**

**ឆ៖** សូមជម្រាបទៅលោកជ្រាបថា ការនិយាយបោសសម្អាតខ្មាំងរបស់ប្រធានតំបន់ពេលនោះ គឺ កត្តាសំខាន់ហ្នឹង គឺអ្នកដែលប្រឆាំងនឹងរបបកម្ពុជាប្រជាធិបតេយ្យ នេះគេកំណត់ថាជាអ្នកអាចជាខ្មាំង។

**សៈ** បាទ អ៊ីចឹងលោកបានឆ្លើយនៅចម្លើយទី៣០ របស់លោក គឺឯកសារ E3/5521 លោកនិយាយថា អ្នកប្រឆាំងត្រូវគេបញ្ជូនទៅឲ្យរៀនសូត្រ ហើយគេមិនដែលឃើញត្រឡប់មកវិញទេ។ តើថ្នាក់ដែលមានអំណាច ដែលមានសិទ្ធិអំណាចសម្រេចថាអ្នកណាត្រូវបញ្ជូនទៅរៀនសូត្រនោះ? តើថ្នាក់ឃុំ ថ្នាក់ស្រុក ឬក៏ថ្នាក់តំបន់?

**ឆៈ** សូមជម្រាបថា ពេលនោះមានតែតំបន់ឬភូមិភាគទេ ដែលមានសិទ្ធិសម្រេចថាឲ្យនរណាមួយឲ្យទៅរៀនសូត្រ ខាងឃុំគឺគ្មានតួនាទីទេ។

[១៥:១១:៤៥]

**សៈ** អ៊ីចឹងខាងឃុំហ្នឹង ថាកម្រិតខ្លួនត្រឹមថាធ្វើរបាយការណ៍ទាក់ទងទៅនឹងការជំទាស់របស់បុគ្គលមួយចំនួននោះ។ តើជាការត្រឹមត្រូវដែរឬទេ? ខាងឃុំគ្រាន់តែធ្វើរបាយការណ៍ទេ រាយការណ៍ទៅលើ?

**ឆៈ** បាទពិតណាស់ខាងឃុំគ្រាន់ធ្វើរបាយការណ៍ ខាងលើអ្នកសម្រេច។

**សៈ** នៅពេលដែលលោកនិយាយអំពីកិច្ចប្រជុំផ្តល់សេចក្តីណែនាំតើ -- ឬក៏អប់រំនោះ រៀនសូត្រ តើវាជាការបញ្ជូនមនុស្សដែលថ្នាក់ភូមិភាគ ហើយនិងតំបន់អ្នកកំណត់មក ហើយកំណត់ហើយត្រូវបញ្ជូនទៅមន្ទីរអប់រំកែប្រែឬក៏យ៉ាងណា?

**ឆៈ** ជាទម្លាប់ គឺខាងលើគេបញ្ជូនអ្នកដែលគេមក ហៅទៅ។

**សៈ** នៅរបបកម្ពុជាប្រជាធិបតេយ្យនោះ លោកធ្លាប់មានឮឈ្មោះ តាអាន់ ដែលជាប្រធានមន្ទីរអប់រំកសាងក្រាំងតាចាន់ដែរឬទេ?

**ឆៈ** តាអាន់ហ្នឹងឮឈ្មោះ ប៉ុន្តែខ្ញុំមិនដែលស្គាល់គាត់ទេ ព្រោះក្រាំងតាចាន់ខ្ញុំឮតែឈ្មោះ ហើយតាអាន់ហ្នឹង ក៏ឮឈ្មោះ សូម្បីគណៈឃុំមិនដែលទៅបៀតនឹងទេ។ សូមអរគុណ។

**សៈ** លោកបាននិយាយដូច្នេះ នៅក្នុងឯកសារ E3/5521 នៅចម្លើយ៤១។ ខ្ញុំសូមដកស្រង់៖ “តើលោកដឹងថាអ្នកណាជាអ្នកស៊ើញសំបុត្រដើម្បីកំណត់ថាបញ្ជូនអ្នកណាដែល -- ឬក៏ត្រូវចាប់ខ្លួនអ្នកណា ឬបញ្ជូនអ្នកណាទៅមន្ទីរអប់រំកែប្រែទេ? លោកឆ្លើយថា៖ គឺជាអ្នកខាងសន្តិសុខ ដែលគេសរសេរសំបុត្រទៅឈ្លបឃុំ”។ ហើយក្រោយមកទៀតនៅក្នុងចម្លើយ៤២ហ្នឹង លោកនិយាយថា៖ “ឈ្លបនោះរាយការណ៍ទៅឃុំ ហើយមានតែឈ្លបហ្នឹងទេ ដែលមានសិទ្ធិចាប់ចងនោះ”។ ហើយនៅក្នុងចំណុចនេះលោកនិយាយថាអ្នក “ខាងសន្តិសុខដែលសរសេរទៅឈ្លប”។ លោកចង់មានន័យថាយ៉ាងម៉េចអ្នក

ខាងសន្តិសុខនោះតើចង់និយាយថាតើជាប្រធានសន្តិសុខឃុំ ឬក៏ស្រុក ឬក៏តំបន់ ឬក៏បុគ្គលផ្សេងទៀតដែលទទួលបន្ទុកខាងសន្តិសុខនៅក្នុងតំបន់ហ្នឹង?

[១៥:១២:២៧]

**ឆ៖** ពាក្យនេះ ខ្ញុំចង់ជម្រាបទៅលោកជ្រាបផងដែរថា ឈ្លបនេះគឺសន្តិសុខ។ សន្តិសុខនៅក្នុងតំបន់ហ្នឹង គេអ្នកទាក់ទងជាមួយនឹងឈ្លបនៅមូលដ្ឋាន ឈ្លបនៅឃុំ។

**ស៖** អ៊ីចឹងពេលលោកនៅនិយាយនៅទីនេះ ដែលគេបកប្រែថាជាភ្នាក់ងារសម្ងាត់ហ្នឹង គឺសំដៅទៅលើឈ្លបឃុំហ្នឹងឯង។ អ៊ីចឹងមែនទេ?

**ឆ៖** ពិតហើយ។

**ស៖** បាទឥឡូវខ្ញុំសូមត្រឡប់មកនិយាយអំពីសហករណ៍ ហើយនិងអង្គភាពផ្សេងៗ។ លោកនិយាយថាគេបង្កើតសហករណ៍ដោយឈរលើមូលដ្ឋានគឺថាបែងចែកប្រភេទប្រជាជន ជាបែងចែកជាបីអង្គភាព ជាប្រភេទខុសគ្នា គឺថាប្រជាជនពេញសិទ្ធិ ប្រជាជនត្រៀម ហើយនិងប្រជាជនមូល -- ត្រៀមនេះគឺថាជាប្រជាជនដែលមានបងប្អូនត្រូវបានអង្គការសម្លាប់ ឬក៏ប្រជាជនដែលមានកូនចៅមាននិន្នាការជាមួយនឹងរបបចាស់។ ហើយបន្ទាប់មកទៀតលោកបាននិយាយថា មានប្រជាជនបញ្ញើ គឺថាអ្នកដែលគេជម្លៀសមកពីទីក្រុងភ្នំពេញជាដើមនេះ។ នៅពេលដែលសហករណ៍ អង្គភាពផ្សេងៗទៀតនៅក្នុងសហករណ៍ដែលបែងចែកជាបីក្រុមដែលត្រូវបានបង្កើតឡើងនេះ អ៊ីចឹងខ្ញុំសួរថាតើប្រភេទមនុស្សទាំងបីក្រុមហ្នឹងនៅមានទីតាំងនៅកន្លែងណា នៅក្នុងឃុំលោកហ្នឹង?

**ឆ៖** សូមជម្រាបថាការរៀបចំសហករណ៍នេះ គេបែងចែកដូចលោកមានប្រសាសន៍ហើយ ប្រជាជនពេញសិទ្ធិ ប្រជាជនត្រៀម ប្រជាជនបញ្ញើ។ រឿងនេះខ្ញុំបានជម្រាបរួចហើយប្រជាជនហ្នឹងគេធ្វើផ្ទះចែកជាកងបាទ។ កងនីមួយៗមានកងលេខ១ លេខ២ រហូតលេខ៧អ៊ីចឹងទៅ។

[១៥:១៨:០៦]

**ស៖** តើជាការត្រឹមត្រូវដែរឬទេ គឺថាប្រជាជនពេញសិទ្ធិនោះ គឺកងទី១ ហើយប្រជាជនត្រៀមនៅកងទី២ ហើយប្រជាជនបញ្ញើហ្នឹងនៅកងទី៣។ តើហើយ -- សួរថាត្រឹមត្រូវដែរឬទេការបែងចែកដូច្នេះ ហើយតើទាំងបីកងហ្នឹងស្ថិតនៅទីតាំងខុសគ្នា ឬក៏យ៉ាងណា?

**ឆ៖** ការបែងចែកនេះ ទាំងបីប្រភេទ អាហ្នឹងមិនមែនបីកងទេ បីប្រភេទនេះ គឺនៅដាច់ពីគ្នា។ កង មួយកងមួយប្រភេទអ៊ីចឹងទៅ មួយកងមួយប្រភេទ បាទតាមការងារជាក់ស្តែង ភូមិណាតិចកង

ក៏តិចទៅ ភូមិណាច្រើនក៏មានបួន ប្រាំ ប្រាំមួយកងអ៊ីចឹងទៅ។

**ស៖** បាទ តើៗមានកងដែលមានតែអ្នក១៧មេសាដែរឬទេ?

**ឆ៖** បាទ មាន ១៧មេសា។ ប៉ុន្តែជាប្រធានកង ប្រធានក្រុម គឺប្រជាពលរដ្ឋមូលដ្ឋាន ប្រជា-ពលរដ្ឋចាស់ ប្រជាជនចាស់។

**ស៖** នៅពេលដែលការកំណត់ប្រភេទប្រជាជនត្រូវបានធ្វើហើយ តើកាលនោះលោកនៅញ៉ែងញ៉ង់ដដែល ឬក៏លោកបានផ្លាស់ទៅស្រែរនោងហើយកាលនោះ?

[១៥:២០:០០]

**ឆ៖** បាទ អរគុណ។ ខ្ញុំបានផ្លាស់ទៅខាងឃុំស្រែរនោងរួចហើយ។

**ស៖** តើអ្នកថា កងទី១ គឺថាប្រជាជនពេញសិទ្ធិនោះ លោកនិយាយថា ពួកគេនេះត្រូវបានចាត់ទុកថាជាអ្នកស្មោះត្រង់នឹងបក្ស។ តើបក្សចាត់ទុកថា អ្នកធ្វើការទាំងអស់នេះជាអ្នកស្អាតស្អំជាងគេដែរឬទេ?

**ឆ៖** តាមអ្នកធ្វើការទាំងអស់នេះ កំណត់ថាប្រភេទទី១ហ្នឹង ជាអ្នកត្រឹមត្រូវ ជាអ្នកបដិវត្តត្រឹមត្រូវពិតប្រាកដ។

**ស៖** តើអ្នកធ្វើការនៅប្រភេទក្រុមទី២ ចង់និយាយថាអ្នកដែលមានបងប្អូនមានជាប់ពាក់ព័ន្ធនឹងរបបចាស់នោះ តើគេទុកចិត្តគាត់ស្មើនឹងទុកចិត្តប្រភេទក្រុមទី១ទេ?

**ឆ៖** ប្រភេទទី២ ជាជនគឺគេទុកចិត្ត ពីព្រោះប្រជាជននេះជាអ្នកនៅរស់នៅក្នុងមូលដ្ឋាន ប៉ុន្តែគ្រាន់អ្នកមាន -- គ្រាន់តែមានៗមានបងប្អូន ញាតិមិត្ត សាច់សាលោហិត នៅក្នុងតំបន់ខ្មាំងប៉ុណ្ណឹង គេចាត់ទុកថា ប្រជាពលរដ្ឋត្រៀម – ត្រៀមបម្រុងនឹងឡើងទៅពេញសិទ្ធិ។ សូមអរគុណ។

[១៥:២២:១០]

**ស៖** ទាក់ទងទៅនឹងអ្នក១៧មេសា ដែលមកពីទីក្រុងនោះ ដែលនៅតែបន្តរស់នៅតាមក្រុងដែលក្រោម -- ស្ថិតក្រោមការគ្រប់គ្រងរបស់ លន់ នល់ នោះ តើពួកគាត់ហ្នឹងត្រូវបានចាត់ទុកពីកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាហ្នឹងថា ជាអ្នកដែលមិនគួរឲ្យទុកចិត្តទេ។ អ៊ីចឹងមែនទេ?

**ឆ៖** ភាគតិចណាស់ដែលគេមិនទុកចិត្ត។ ភាគច្រើនគឺគេទុកចិត្ត ព្រោះគេមករស់នៅជាមួយបក្សកុម្មុយនីស្តកម្ពុជាទៅហើយ។

**ស៖** តើលោកមានធ្លាប់ឮពាក្យដែលគេហៅថាឈ្លើយសឹកដែរឬទេ? ដែលគេ -- ពាក្យហ្នឹង

ដែលគេប្រើសម្រាប់សំដៅទៅលើប្រជាជន១៧ មេសា នោះ?

**ឆ៖** ពាក្យនេះមានការនិយាយជាហូរហែរអ៊ីចឹងដែរហ្នឹង ល្ហើយសឹក។ ល្ហើយសឹកហ្នឹង មានការនិយាយ ប៉ុនក្រោយមកគេហៅថាប្រជាជនជម្លៀសចេញពីក្រុង។

**ស៖** បាទ ឥឡូវខ្ញុំអានសម្រង់មួយ គឺឯកសារ E3/5521 កំណត់ហេតុស្តាប់ចម្លើយរបស់លោក កាលនោះលោកនិយាយនៅចម្លើយ៤៧ថា៖ "ការហូបចុកខ្វះខាត មានអ្នកខ្លះហ្នឹងមានតែបបរ ហូប ប៉ុណ្ណឹងទេ"។ សូមចប់ការដកស្រង់។

[១៥:២៤:២៤]

**ស៖** តើអ្នកណាដែលគេថាមានតែបបរហូបនោះ? តើជាប្រភេទទី១ ឬក៏ប្រភេទទី២ ឬក៏ប្រភេទទី៣?

**ឆ៖** បាទ មានបបរហូប បើបបរ បបរទាំងអស់គ្នា ហូបទាំងអស់គ្នា អត់មានប្រភេទទី១ ទី២ទេ ប៉ុន្តែនៅក្នុងឃុំខ្ញុំ នៅស្រែរនោង ១០ថ្ងៃរៀបចំបបរគ្រឿងម្តង មួយពេល ហើយនិងកាប់គោ កាប់ជ្រូក មួយពេលក្នុងរយៈកាល១០ថ្ងៃ។ នេះនៅក្នុងឃុំស្រែរនោង ឃុំដទៃទៀត ខ្ញុំមិនបានដឹងទេ។

**ស៖** លោកសាក្សី លោកហ្នឹងលោកស្ថិតនៅក្នុងប្រភេទណា? ប្រភេទទី១ ទី២ ទី៣?

**ឆ៖** បាទ ខ្ញុំមិនយល់សំណួរនេះ។

**ស៖** តើលោកជាប្រជាជនមូលដ្ឋានដែលស្ថិតនៅក្នុងប្រភេទទី១ ឬក៏លោកស្ថិតនៅក្នុងប្រភេទទី២ ដែលគេថាមានបងប្អូនជាប់ពាក់ព័ន្ធរបប លន់ នល់ ឬក៏លោកជាអ្នកដែលគេជម្លៀសមកទីក្រុងភ្នំពេញ គឺប្រភេទទី៣ បាទ។

**ឆ៖** បាទ ខ្ញុំជាប្រជាពលរដ្ឋ ប្រជាជននៅក្នុងមូលដ្ឋាន ប៉ុន្តែមិនទាន់បានចូលប្រភេទទី១ទេ។ គណៈឃុំហ្នឹងមិនទាន់បានចូលប្រភេទទី១ ពីព្រោះ ប៉ុល ពត បាត់ -- យកប្អូនខ្ញុំមួយបាត់ កូនប្រុសច្បងរបស់ខ្ញុំមួយបាត់។ អ៊ីចឹងគឺជាប្រជាជនត្រៀម ប៉ុន្តែតួនាទីគឺថាអ្នកហ្នឹងធ្វើការល្អស្មោះត្រង់។ អ៊ីចឹងគេឲ្យឡើងទៅ ឆ្នាំ១៩៧៨ -- ៧៧-៧៨ ហ្នឹង។

**ស៖** តើលោកជាបក្សជននៃបក្សកុម្មុយនីស្តកម្ពុជាដែរឬទេនៅពេលដែលលោកជាមេឃុំស្រែរនោងនោះ?

**ឆ៖** ខ្ញុំសូមជម្រាបថា ជាបក្សជនត្រៀម មិនទាន់ជាបក្សជនពេញសិទ្ធិទេ ជាបក្សជនត្រៀម។

[១៥:២៧:២៧]

**ស៖** លោកឆ្លើយនៅចម្លើយទី៥៥ របស់លោកគឺថា អ្នកជំងឺភាគច្រើនហ្នឹងជាអ្នក១៧មេសា ពីព្រោះថា ពួកគេមិនមានបទពិសោធន៍ក្នុងការធ្វើការនៅស្រុកស្រែ ការងារស្រែចម្ការ។ ចម្លើយ៥៣ របស់លោក "តើមានមនុស្សស្លាប់ច្រើនដែរឬទេ?" -- ៥៣ សុំទោសគឺថា "មានស្លាប់ហ្នឹងវាពិតជាមានហើយ។ បើសិនជាអ្នកជំងឺភាគច្រើនហ្នឹងជាអ្នក១៧មេសា តើមានចំនួនអ្នក១៧មេសាធ្វើការនៅក្នុងឃុំញ៉ែងញ៉ង់ចុះបន្តិចម្តងៗ ឬក៏យ៉ាងណា? ហើយនៅដូចគ្នាដែរនៅឃុំស្រែរនោងហ្នឹងអ៊ីចឹងដែរឬក៏យ៉ាងម៉េច? អ្នក១៧មេសា ចំនួនអ្នកធ្វើការចុះរហូត"។

**ឆ៖** បាទ នៅខាងឃុំស្រែរនោងដែលខ្ញុំទៅនៅកន្លែងហ្នឹងដោះស្រាយជីវភាពបានមួយចំនួន។ ប៉ុន្តែអ្នកឈឺនៅតែមានទេ បាទ។ វានៅតែឈឺ មានបញ្ជូន ពីមុនហ្នឹងមានបញ្ជូនទៅប្រធានតំបន់នៅអង្គរនាប បាទ។

[១៥:២៨:៥៥]

**លោក វ៉ាំងសង់ វ៉ាយឌ៍ ដេស្មាឯល៖**

បាទ ឥឡូវខ្ញុំសុំបង្ហាញឯកសារ E3/2436 ទៅសាក្សីហើយនិងសុំបញ្ចាំងនៅលើអេក្រង់ផង លោកប្រធាន។ សុំអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

**សួរដោយលោក វ៉ាំងសង់ វ៉ាយឌ៍ ដេស្មាឯល៖**

**ស៖** បាទ គឺជារបាយការណ៍ឃុំញ៉ែងញ៉ង់ដែលចុះហត្ថលេខាដោយ មាន--ឈ្មោះមាន ដែលផ្ញើជូនទៅអង្គការស្រុកចុះថ្ងៃទី២៨ មេសា ឆ្នាំ១៩៧៧។ របាយការណ៍នេះទាក់ទងនឹងបុគ្គលម្នាក់ដែលមានឈ្មោះ មូ ផុន ជាប្រជាជនថ្មី ហើយដែលជាអតីតទាហានលន់ នល់។ នៅកថាខណ្ឌទី៣ នៃរបាយ-ការណ៍នេះ មាន ហ្នឹងទិតៀន មូ ផុន ដូចតទៅ ខ្ញុំសុំដកស្រង់៖ "នៅពេលដែលគេចាត់តាំងឲ្យធ្វើការជីកប្រឡាយ មូ ផុន នេះគឺជំទាស់មិនព្រមធ្វើទេ ដោយយកលេសថាគេហ្នឹងវាហត់ គ្រាំគ្រាដោយលី ដែលរែកដី។ នៅពេលដែលគេយើងចាត់តាំងឲ្យទៅធ្វើជី គេថាគេឈឺពោះ មិនអាចធ្វើការ -- ធ្វើជីហ្នឹងបានទេ អ៊ីចឹងវាមិនដែល -- សឹងតែមិនដែលធ្វើការអីទេ អាហ្នឹងវាឆ្លាតណាស់ មានល្បិចច្រើន។ ខ្ញុំបញ្ជាក់ថាវាមិនស្គមទេ វាធាត់ទៀតផង"។ តើៗមានមនុស្សហេវហត់អស់កម្លាំងខ្លាំងដែរទេ នៅក្នុងសហករណ៍ហ្នឹង ដែលមិនអាចធ្វើការបាន?

**លោក នុត នូវ៖**

**ឆ៖** បាទ នៅឃុំស្រែរនោង អត់ដែលមានមនុស្សហាត់ហេវខ្លាំងទេ។ នេះៗ ឯកសារនេះ ឯកសាររបស់ឃុំញ៉ែងញ៉ង ហើយញ៉ែងញ៉ងនេះ ខ្ញុំចេញទៅបាត់ហើយទៅស្រែរនោងបាត់ទៅហើយ។ បាទ សូមអរគុណ។

**សៈ** ទីបញ្ចប់ តើលោកអាចបញ្ជាក់បានទេថា ពេលណាលោកចេញពីឃុំញ៉ែងញ៉ងពីព្រោះថា នេះជាឯកសារដែលចុះថ្ងៃទី២៨ មេសា ឆ្នាំ១៩៧៧? ហើយអម្បាញ់មិញ ខ្ញុំបង្ហាញឯកសារមួយដែល ចុះខែមិថុនា ឆ្នាំ១៩៧៦ ហើយទាំងពីរដងនេះលោកបាននិយាយថា កាលនោះ ខ្ញុំចេញពីឃុំញ៉ែងញ៉ង ហើយៗ។ បើអ៊ីចឹង ខ្ញុំសួរលោកថាតើ ឲ្យជាក់លាក់តែម្តងនោះ លោកចេញពីឃុំញ៉ែងញ៉ងនេះនៅពេល ណា?

[១៥:៣១:៤០]

**ឆ៖** បាទ ចេញពីឃុំញ៉ែងញ៉ងនេះ ចុង៧៧-៧៨ ដើម៧៨។

**សៈ** អ៊ីចឹង លោកយល់ស្របនឹងខ្ញុំថា របាយការណ៍ដែលចុះថ្ងៃទី២៨ មេសា ឆ្នាំ១៩៧៨ហ្នឹង ត្រូវបានធ្វើឡើងនៅពេលដែលលោកធ្វើការនៅញ៉ែងញ៉ងនៅឡើយទេ។ សំណួរមួយទៀត គឺថាតើមាន អ្នកជំងឺនុំង ដែលគេចោទប្រកាន់ថាពុតៗថាឈឺ ហើយមិនទៅធ្វើការ។ តើករណីនេះលោកធ្លាប់ឮគេ និយាយច្រើនទេ រឿងថាឈឺមិនអាចទៅធ្វើការបាន ពុត?

**ឆ៖** ក្នុងករណីនេះ ចំពោះឃុំរបស់ខ្ញុំមិនដែលមានឮទេ ពុត។ បើឈឺ ឈឺជាក់ស្តែង ឲ្យពេទ្យគេ ពិនិត្យ។ សូមអរគុណ។

**សៈ** នៅខាងក្រោមរបាយការណ៍ដដែលអម្បាញ់មិញនេះ គឺមានចំណារសរសេរដៃមួយ សរសេរ ដោយ គិត មានន័យថាឲ្យឈ្មោះ ផុន នេះស្នើចាប់ចុះ។ អ៊ីចឹងមិនដឹងថា គិត នេះជាអ្នកណា ហើយគាត់ កាន់មុខតំណែងអីដែរនៅពេលនោះ?

[១៥:៣៣:២១]

**ឆ៖** គិត–តាគិតនេះ កាលពេលនោះ គឺគាត់នៅគណៈស្រុកត្រាំកក់។

**សៈ** បាទ សូមអរគុណ។ ខ្ញុំមានឯកសារពីរទៀត ដែលៗជូនលោកឲ្យមើល។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្បាឯល៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតដាក់បញ្ហាំងលើអេក្រង់ផងដែរ គឺឯកសារ E3/2450 ហើយនិង

ឯកសារ E3/2453។ សូមអនុញ្ញាតលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

[១៥:៣៤:១៥]

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** ចំពោះឯកសារទី១ គឺ E3/2450, ERN គឺជាភាសាខ្មែរ 00270748, ជាភាសាអង់គ្លេស 00322163, ជាភាសាបារាំង 00623749។ នេះជារបាយការណ៍មួយដែលផ្ញើទៅដោយមេឃុំ -- ផ្ញើដោយមេឃុំញ៉ៀងញ៉ង ឬអនុឃុំឈ្មោះ មាន ផ្ញើទៅប្រធានគុកក្រាំងតាចាន់ អាន់។ របាយការណ៍នេះពាក់ព័ន្ធនឹងស្ត្រីមួយរូប នៅឃុំញ៉ៀងញ៉ងដែលមាន អូអា។ គាត់ជាប្រពន្ធរបស់មេទាហានសម័យលន់នល់ ដែលត្រូវបានចាប់ខ្លួនតាមអនុសាសន៍របស់អង្គការពីព្រោះគាត់រអ៊ូរទាំថា -- ខ្ញុំសូមដកស្រង់ "ធ្វើបដិវត្តន៍ពិបាកណាស់ ធ្វើការទាំងយប់ទាំងថ្ងៃ ហើយស៊ីបបរ មិនចេះរស់នៅទេ"។ សូមបញ្ចប់ការដកស្រង់។ ឯកសារទី២ គឺE3/2453, ERN ជាភាសាខ្មែរ 00270780 ទៅដល់ 81, ជាភាសាអង់គ្លេស 00388583, ជាភាសាបារាំង 00611773។ នេះជារបាយការណ៍មួយចុះថ្ងៃទី៦ ខែតុលា ឆ្នាំ១៩៧៧ ផ្ញើទៅស្រុក ដោយឃុំញ៉ៀងញ៉ង ចុះហត្ថលេខាដោយឈ្មោះ ស៊ីម។ ស៊ីម រាយការណ៍ពីប្រពន្ធរបស់ទាហាន ដែលបានរិះគន់បដិវត្តន៍ពីព្រោះដោយសារតែពួកគេគ្មានអីហូបចុក ហូបតែបបរ។ កាលពីសម័យចាស់ គឺហូបចុកគ្រប់គ្រាន់។ ប្រពន្ធទាហានទាំងអស់នេះនិយាយថា កាលពីសម័យមុន គឺហូបចុកគ្រប់គ្រាន់ ហើយសប្បាយណាស់។ តើមានអ្វីកើតឡើងចំពោះអ្នកនៅឃុំញ៉ៀងញ៉ងដែលរអ៊ូរទាំពីការខ្វះខាតអាហារហូបចុក ពីការលំបាកក្នុងការរស់នៅ និងធ្វើការ? តើលោកអាចបញ្ជាក់បានទេ?

**ឆ៖** ក្នុងលិខិតទាំងពីរនេះ ខ្ញុំមិនបានដឹង ហើយមិនអាចបញ្ជាក់បានទេ។ ព្រោះ ស៊ីម មកនៅឃុំញ៉ៀងញ៉ងហ្នឹង ខ្ញុំទៅនោះបាត់ទៅហើយ។ តាមាន មកនៅហ្នឹង ក៏ខ្ញុំចេញពីហ្នឹងទៅដែរ។ នេះសូមជម្រាបដោយស្មោះត្រង់ ខ្ញុំមិនអាចសម្រេចថាយ៉ាងម៉េចយ៉ាងម៉ាបានទេ ក្នុងលិខិតទាំងពីរនេះ។

[១៥:៣៧:៥០]

**ស៖** អ៊ីចឹងតើឃុំមានបានទទួលបញ្ជាពីថ្នាក់ស្រុក ឬថ្នាក់តំបន់ឲ្យរាយការណ៍អំពីអ្នកដែលរអ៊ូរទាំថា ហូបចុកខ្វះខាត ឬក៏រអ៊ូរទាំថា ធ្វើការងារពិបាកទេ?

**ឆ៖** ចំពោះនៅឃុំខ្ញុំ បើអ្នកដែលរអ៊ូរទាំ អ្នកដែលថាធ្វើការលំបាក យើងប្រជុំធ្វើការងារសតិ-

អារម្មណ៍ឲ្យគាត់យល់អំពីកិច្ចការដែលត្រូវធ្វើដើម្បីផលប្រយោជន៍រួមទាំងអស់គ្នា។ បាទ អត់ដែលបញ្ជូនរបាយការណ៍ទៅស្រុកទេ។ បាទ សូមជ្រាប។

**ស៖** តើឈ្មោះ សឹម ដែលបានចុះហត្ថលេខានៅក្នុងរបាយការណ៍ដែលផ្ញើដោយឃុំញ៉ែងញ៉ង នេះជាអ្នកណានៅពេលហ្នឹង លោកថាពេលហ្នឹងគឺលោកនៅទីនោះដែរ។ អ៊ីចឹងខ្ញុំចង់ដឹងថា សឹម ហ្នឹងជាអ្នកណាដែរ?

**ឆ៖** មេឃុំញ៉ែងញ៉ង។

**ប្រធានអង្គជំនុំ៖**

ឆ្លើយម្ដងទៀតសាក្សី គាត់អំមិញឆ្លើយពាក់កណ្ដាលដាច់ មិនបាន -- ក្បាលមេក្រូហ្វូនអត់ប្រតិបត្តិការ។

**លោក នុត នូវ៖**

**ឆ៖** បាទ សូមជម្រាបថាឈ្មោះ សឹម ហ្នឹងជាមេឃុំញ៉ែងញ៉ង។ ខ្ញុំអត់បាននៅជាមួយគាត់ទេ ខ្ញុំទៅបាត់ហើយ។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

**ស៖** សូមអរគុណ។ ខ្ញុំមិននិយាយពីឃុំស្រែរនោង និងអំពីលោកជាមេឃុំទេ។ អ៊ីចឹងខ្ញុំចង់ដឹងថា តាមលោកដឹងនោះ តើឃុំមានរាយការណ៍អំពីអ្នកណាដែលព្យាយាមរត់ចេញពីកម្ពុជាទេ?

**លោក នុត នូវ៖**

**ឆ៖** បញ្ហានេះ បើមានគេអាចធ្វើរបាយការណ៍ទៅស្រុក ប៉ុន្តែបើឃុំណាអត់មាន អាហ្នឹងជាធម្មតាទៅ។ ឃុំណាដែលមាន ពិតជាគេធ្វើរបាយការណ៍ទៅស្រុក។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

សូមអរគុណ ខ្ញុំមានឧទាហរណ៍បីពាក់ព័ន្ធនឹងការរាយការណ៍បែបនេះ។ អ៊ីចឹងខ្ញុំសូមការអនុញ្ញាតពីលោកប្រធាន ដើម្បីផ្ដល់ឯកសារនេះ។ គឺឯកសារ D150.90 សូមទោស D157.90, E3/2453 និងឯកសារ E3/2452។ ដូច្នេះ សូមការអនុញ្ញាតពីលោកប្រធាន ដើម្បីប្រគល់ឯកសារនេះ ជូនសាក្សីលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។

[១៥:៤១:១៧]

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាងលេ៖**

**ស៖** ឯកសារទី១ គឺចេញមកពីឃុំញ៉ែងញ៉ង គឺនៅ -- គឺមានតែមួយទំព័រទេ។ គឺជារបាយ-ការណ៍ចុះ ចុងខែវិច្ឆិកា ឆ្នាំ១៩៧៧ ស្ដីពីការសួរចម្លើយយុវជនមួយរូបដែលចាប់ខ្លួននៅក្នុងឃុំញ៉ែងញ៉ង ដែលព្យាយាមប៉ុនប៉ងរត់គេចទៅវៀតណាម។ របាយការណ៍នេះពន្យល់ថា "ទាហានស្រុកហ្នឹងបាន បាញ់បីគ្រាប់មុននឹងចាប់បុគ្គលនេះបាន ហើយបន្ទាប់មកគេបញ្ជូនទៅឲ្យមន្ទីរអប់រំនគរបាលស្រុក"។ ឯកសារទី២ គឺឯកសារ E3/2453 ទំព័រពាក់ព័ន្ធជាខ្មែរ គឺ 00270779, ជាភាសាអង់គ្លេស 00388582, ជាភាសាបារាំង 00611772។ របាយការណ៍នេះ ធ្វើឡើងដោយឈ្មោះ យុន នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ១៩៧៧ មេឃុំស្រែរនោង ផ្ញើជូនបក្សស្រុក ពាក់ព័ន្ធនឹងកសិករមួយរូបដែលបានគេចចេញពីឃុំ បន្ទាប់មកត្រូវបានចាប់ខ្លួននៅស្រុក១០៧ ហើយបញ្ជូនទៅស្រែរនោងវិញ។

ជាចុងក្រោយគឺឯកសារ E3/2452, ជាភាសាខ្មែរ 00270998, ជាភាសាអង់គ្លេស 00843036, ជាភាសាបារាំង 00872836។ ឯកសារនេះ ខ្ញុំបានបង្ហាញជូនតាំងពីដំបូងមកហើយ គឺរបាយ-ការណ៍ដោយផ្នែក ចុះថ្ងៃទី៨ តុលា ៧៧ ធ្វើនៅស្រែរនោង ដោយឈ្មោះ នូវ។ របាយការណ៍នេះ និយាយអំពីមនុស្សម្នាក់នៅស្រុក១០៩ ដែលបានរត់គេចចេញពីកងរបស់ខ្លួននៅស្រែរនោង ហើយទៅលាយបូរ។ គឺយើងមានឧទាហរណ៍ពាក់ព័ន្ធមួយចំនួន ដូចដែលលោកបានឃើញហ្នឹងហើយ។

អម្បាញ់មិញនេះលោកនិយាយថា មានការរាយការណ៍ដែលត្រូវផ្ញើជូនថ្នាក់ស្រុក។ អ៊ីចឹងខ្ញុំចង់ដឹងថាតើថ្នាក់ស្រុកមានណែនាំជាក់លាក់យ៉ាងម៉េចពាក់ព័ន្ធទៅនឹងអ្នកដែលព្យាយាមរត់គេចចេញពីកម្ពុជានេះ ជាពិសេសគឺរត់គេចដោយសារតែការរស់នៅ និងការធ្វើការមានការលំបាកនេះ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប។

សូមអញ្ជើញលោកមេធាវី គង់ សំអុន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ទាក់ទងនឹងការប្រើប្រាស់ឯកសារចុងក្រោយរបស់សហព្រះរាជអាជ្ញាអន្តរជាតិ។ សហព្រះរាជអាជ្ញាអន្តរជាតិរង បានលើកថាឯកសារនេះធ្វើឡើងដោយឈ្មោះ នូវ ក៏ប៉ុន្តែសាក្សីបានឆ្លើយបញ្ជាក់នៅពេលដែលចម្លើយនេះ ថាគាត់មិនអាចអានបានថាជាអ្វីទេ ហើយក៏មិន

ដឹងថាជាឯកសារនេះ ធ្វើឡើងដោយអ្នកណាដែរ។ ហេតុដូច្នេះ ខ្ញុំយល់ថាការសន្និតរបស់សហព្រះរាជអាជ្ញាថាជាឈ្មោះ នួវ ហ្នឹង គឺមិនត្រឹមត្រូវទេ ខុសពីអង្គហេតុ។ បាទ សូមអរគុណ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្បាឯល៖**

ខ្ញុំមិនបានបំប្លែងចម្លើយសាក្សីទេ ខ្ញុំមិនបានថាសាក្សីហ្នឹងគាត់ជាអ្នកចុះហត្ថលេខាទេ។ សំណួរខ្ញុំហ្នឹងគឺជាលក្ខណៈទូទៅទេ គឺយើងឃើញហើយថាមានរបាយការណ៍ដែលធ្វើនៅឃុំ ដែលជាកន្លែងរស់នៅ និងកន្លែងធ្វើការរបស់សាក្សី ហើយខ្ញុំសួរគាត់ហ្នឹង សួរចង់ដឹងថាតើមានរបាយការណ៍ដែលធ្វើដោយឃុំ នៅពេលធ្វើដោយឃុំហ្នឹង ចង់ដឹងថាតើថ្នាក់ស្រុកហ្នឹងមានណែនាំមកយ៉ាងម៉េចចំពោះអ្នកដែលរត់ចេញពីកម្ពុជាដោយសារតែការធ្វើការ ហើយនិងការរស់នៅលំនៅលំបាកហ្នឹង?

[១៥:៤៥:៤៤]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះបដិសេធនូវសេចក្ដីជំទាស់របស់មេធាវីការពារក្ដី ហើយចំពោះសំណួរនេះ ហើយសំណួរនេះ គឺមានមូលដ្ឋានសម្រាប់ដែលអង្គជំនុំជម្រះគប្បីស្ដាប់ចម្លើយតបរបស់សាក្សីទៅនឹងសំណួរនេះ។ បាទ សូមសាក្សីឆ្លើយតបទៅនឹងសំណួរដែលសួរដោយសហព្រះរាជអាជ្ញាចុងក្រោយអម្បាញ់មិញនេះ។

**លោក នុត នួវ៖**

**ឆ៖** សំណួរចុងក្រោយនេះ ខ្ញុំបានជម្រាបជូនម្ដងហើយ ថារឿងនេះខ្ញុំបាទមិនដឹងទេ ហើយអក្សរនេះក៏មិនមានជាអក្សររបស់ខ្ញុំ ហើយបើឈ្មោះពិតប្រាកដហើយកាលនោះ ខ្ញុំនៅស្រែរនោងហើយមិនប្រកែកទេ ពិតជាឈ្មោះរបស់ខ្ញុំ។ ឯទី២ និងទី -- ទី១ និងទី២ នេះ គឺខាងញ៉ែងញ៉ង ខ្ញុំបាទមិនទទួលដឹងទេ សូមអង្គសវនាការជ្រាប។

[១៥:៤៦:៥៦]

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្បាឯល៖**

**ស៖** សូមអរគុណ ពាក់ព័ន្ធទៅនឹងការប្រជុំនោះតើលោកចូលរួមប្រជុំនៅថ្នាក់ស្រុករៀងរាល់ខែទេ? ហើយនៅពេលប្រជុំហ្នឹង គេមានចេញបញ្ហា ចេញការណែនាំច្បាស់ទេ ថាត្រូវតែរាយការណ៍ទាំងអស់ ចំពោះអ្នកណាក៏ដោយ ដែលប៉ុនប៉ងរត់ចេញពីប្រទេសកម្ពុជានោះ?

**ឆ៖** ការប្រជុំនេះ វាមានការប្រជុំជួនក៏មួយខែម្ដង ជួនក៏ពីរខែម្ដងទៅ ដោយយោងទៅតាម

កិច្ចការមមាញឹកក្នុងការងារបង្កបង្កើនផលក្នុងរដូវវស្សាអ៊ីចឹងទៅ ប្រជុំយូរៗម្តង។ ឯការងារដែលគ្មានការងារចាំបាច់បំផុតដែលត្រូវធ្វើហ្នឹង គឺប្រជុំ បាទ មានការប្រជុំហ្នឹងគឺ ប្រជុំហ្នឹងគឺណែនាំអំពីរឿងធ្វើស្រែឱ្យបាន៣តោន ដូចខ្ញុំជម្រាបខាងដើមអ៊ីចឹង ធ្វើម៉េចឱ្យបាន៣តោន កម្មាភិបាលត្រូវចុះប្រឡូកក្នុងចលនាបង្កបង្កើនផល។ នេះជាទ្រឹស្តីតំបន់ភូមិភាគ បាទ។ សូមអរគុណ។

**ស៖** សូមអរគុណលោកសាក្សី។ ក៏ប៉ុន្តែនេះមិនមែនជាសំណួររបស់ខ្ញុំទេ ខ្ញុំចង់ដឹងថានៅពេលប្រជុំម្តង ឬក៏ពីរដងនៅក្នុងមួយខែនោះ ខ្ញុំចង់ដឹងថាគេនិយាយពីបញ្ហាសន្តិសុខដែរឬទេ? គេមានប្រាប់ទៅដល់មេឃុំឱ្យបានច្បាស់ថា ត្រូវក្នុងករណីណាៗត្រូវតែធ្វើការរាយការណ៍ពាក់ព័ន្ធនឹងបញ្ហាវិន័យ។ ជាពិសេសហ្នឹង គឺពាក់ព័ន្ធនឹងអ្នកដែលព្យាយាមរត់គេចចេញពីប្រទេសកម្ពុជានោះ តើគេមានណែនាំឱ្យច្បាស់លាស់ទេ?

[១៥:៤៨:៥៦]

**ឆ៖** បាទ នៅខាងក្រោមនេះ មិនមានដែលគេប្រជុំផ្សព្វផ្សាយថាចំពោះអ្នករត់ចេញអី គេអត់មានការនិយាយទេ បាទ។ ខ្ញុំមិនដែលបានដឹង ហើយក៏មិនដែលបានឮដែរ បាទ សូមអរគុណ។

**ស៖** លោកនិយាយថាឃុំត្រូវរាយការណ៍ពីអ្នកដែលប៉ុនប៉ងរត់គេចចេញពីកម្ពុជា។ ហេតុអ្វីបានជាឃុំត្រូវរាយការណ៍បើអត់មានការណែនាំអីពីថ្នាក់លើផង?

**ឆ៖** បាទនេះ សភាពការណ៍ផ្សេងៗប្រចាំខែ តែងតែធ្វើរបាយការណ៍ ការងារនយោបាយសេដ្ឋកិច្ច សន្តិសុខ បាទគ្រប់បែបយ៉ាងទាំងអស់។ អ៊ីចឹងការងារសន្តិសុខបើយើងអត់មាន ហៅថាប្រជាពលរដ្ឋចង់រត់ចេញ អាហ្នឹងយើងអត់ដាក់ទៅ បើការងារហ្នឹងថាមានប្រជាពលរដ្ឋដែលចង់រត់គេចវេះអីយើងសរសេរជាលាយលក្ខណ៍អក្សរទៅតាមហ្នឹង។ ហើយខាងយើងខ្ញុំនេះ មិនសូវបានសរសេរទេ ច្រើនតែស្មៀននៅប្រចាំការនៅការិយាល័យ។ បាទ សូមអរគុណ។

**ស៖** នៅក្នុងចម្លើយ--

[១៥:៥០:៣៨]

**ប្រធានអង្គជំនុំ៖**

សហព្រះរាជអាជ្ញារង។ បាទ អង្គជំនុំជម្រះសូមអរគុណចំពោះលោក នុត នូវ។ ដំណើរការស្តាប់សក្ខីកម្មរបស់លោកនៅក្នុងឋានៈជាសាក្សីនៅមិនទាន់ចប់នៅឡើយទេ អង្គជំនុំជម្រះកោះអញ្ជើញលោកឱ្យមកបន្តផ្តល់សក្ខីកម្មនៅថ្ងៃចន្ទ ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៥ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ។

ហើយសវនាការនៅថ្ងៃចន្ទនេះ អង្គជំនុំជម្រះនឹងបន្តស្តាប់សក្ខីកម្មរបស់លោកឲ្យបានចប់ ហើយអង្គជំនុំជម្រះសូមអរគុណ ហើយដំណើរការសវនាការនេះសម្រាកថ្ងៃនេះត្រឹមនេះហើយលើចំពោះលោកការស្តាប់សក្ខីកម្មរបស់លោក ព្រោះតុលាការមានកិច្ចការមួយចំនួនពិភាក្សាជាមួយភាគីទៀត។ ដូច្នេះលោកអាចវិលត្រឡប់ទៅកាន់ទីកន្លែងដែលលោកស្នាក់បានហើយ។ ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ជូនលោក នុត នូវ វិលត្រឡប់ទៅកាន់កន្លែងដែលគាត់ស្នាក់នៅវិញចុះ និងសូមឲ្យអញ្ជើញគាត់ត្រឡប់មកចូលរួមសវនាការនៅបន្ទប់សវនាការនេះវិញ នៅថ្ងៃច័ន្ទទី១៦ ខែមីនា ដើមសប្តាហ៍ក្រោយនៅវេលាម៉ោងប្រាំបួនព្រឹក។ ហើយលោកមេធាវី មឿន សុវណ្ណ អរគុណហើយសូមអញ្ជើញចូលរួមប្រឹក្សាសាក្សីនៅថ្ងៃច័ន្ទតាមពេលវេលាបានកំណត់។

អញ្ជើញចាកចេញចុះ!

[១៥:៥២:១០]

បាទជាបន្តទៅនេះ អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅមេធាវី វ៉ិចទ័រ កូប៉េ ដើម្បីឡើងនូវបង្ហាញ -- ឡើងបង្ហាញនូវសំអាងហេតុបន្ថែមលើសំណើសុំរបស់លោកដែលបានស្នើសុំកន្លងមកនេះ សុំឲ្យអង្គជំនុំជម្រះធ្វើដំណើរទៅពិនិត្យទីតាំងកន្លែងសម្លាប់មនុស្សក្រាំងតាចាន់ ដូចដែលចៅក្រម ក្លូឌា ហ្វែនស៍ បានជម្រាបលោកមេធាវីកាលពីព្រឹកមិញរួចហើយ ដោយហេតុថានៅក្នុងអង្គហេតុនេះ គឺទីកន្លែងកើតហេតុនោះ បានកើតឡើងនៅជិត៤០ឆ្នាំហើយៗមានការប្រែប្រួលទី១។ ទី២ គឺនៅក្នុងសំណុំរឿងមានឯកសារ មានរូបថត មានផែនទីជាច្រើននៅក្នុងសំណុំរឿង ដូចជាក្រុណ្ឌមួយដែលអង្គជំនុំជម្រះបានជម្រាបជូនលោកកាលពីព្រឹកមិញ។ ហើយដើម្បីឲ្យច្បាស់លាស់ និងមានមូលដ្ឋានក្នុងការសម្រេចលើសំណើសុំរបស់លោកនេះ សូមឲ្យលោកបន្ថែម បង្ហាញបន្ថែមនូវសំអាងហេតុនៅ ប្រសិនបើលោកមានបំណងធ្វើដូច្នេះ។ បាទសូមអញ្ជើញ!

[១៥:៥៣:១២]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំបានគិតអំពីសំណើនេះពេញមួយរសៀលនេះ ប៉ុន្តែខ្ញុំមិនប្រាកដថាតើខ្ញុំមានអ្វីបន្ថែមឲ្យបានលើសពីអ្វីដែលខ្ញុំបានបន្ថែមរួចទៅហើយក្នុងពេលកន្លងមកនោះទេ គឺអ្វីដែលខ្ញុំបាននិយាយនៅពេលខែមុននោះទេ។ ប៉ុន្តែខ្ញុំសូមបញ្ជាក់សាជាថ្មីឡើងវិញថា ចំពោះខ្ញុំផ្ទាល់ក៏ដូចជាក្រុមការងាររបស់ខ្ញុំ ខ្ញុំគិតថាវាជាការមួយដ៏មានប្រយោជន៍យ៉ាងសំខាន់ដែលថាយើងមិនគ្រាន់តែត្រូវ

សិក្សាផែនទីដែលគូរឡើងដោយការិយាល័យសហចៅក្រមស៊ើបអង្កេត ឬក៏រូបភាពនោះទេ ប៉ុន្តែយើងគួរតែចុះទៅមើលទីតាំងដោយផ្ទាល់។ ខ្ញុំគិតថា ខ្ញុំអាចធ្វើការប្រៀបថា ប្រៀបធៀបថាជាទូទៅប្រសិនបើយើងចង់ទិញផ្ទះ យើងមិនមែនមើលតែរូបភាពហើយទិញផ្ទះទេ ទាល់តែទៅមើលដោយផ្ទាល់នៅផ្ទះនោះ ទើបយើងសម្រេចចិត្តធ្វើការទិញផ្ទះ។ ដូច្នេះ ប្រសិនបើយើងទៅមើលដោយផ្ទាល់នៅទីតាំងនោះ យើងអាចនឹងឃើញបញ្ហាជាច្រើន បញ្ហាមួយដែលខ្ញុំបានបង្ហាញរួចមកហើយគឺថា នៅក្នុងដីកាដំណោះស្រាយ គឺមានការចោទប្រកាន់មួយដែលថាមានមនុស្សប្រហែលជា១៥០៥នាក់ -- ១៥០០នាក់ ត្រូវបានសម្លាប់នៅក្រាំងតាចាន់។ ហើយខ្ញុំគិតថានៅក្នុងសារណាបញ្ចប់ការពិភាក្សាដេញដោលខ្ញុំៗនឹងសសេរពីចំណុចនេះដែរ ព្រោះថាវាមិនអាចនោះទេ ដែលថាយើងអាចកប់សាកសព១៥០០០នាក់ នៅតាមរណ្តៅ ឬក៏កន្លែងកប់សាកសពនានានៅទីនោះបាន។ ដូច្នេះហើយ ខ្ញុំគិតថាយើងអាចពិភាក្សាអំពីការប្រើប្រាស់អំពី*ស្ថាទិស្ទិក* ក្នុងការពិភាក្សា។ ខ្ញុំចង់ឲ្យមានការចាប់អារម្មណ៍ទៅលើចំណុចនេះមួយ។ ក្រៅពីនេះ ក៏មានបញ្ហាជាច្រើនដែលខ្ញុំបានពិភាក្សាកន្លងមកហើយកាលពីខែមុន គឺអំពីទីតាំងនៃច្រកចូល ក៏ដូចជាទីតាំងជើងភ្នំ។ ដូច្នេះ យើងឃើញថា វាមានបញ្ហាជាច្រើនដែលយើងពិបាកក្នុងការធ្វើការសម្រេចដោយផ្អែកទៅលើឯកសារ ប៉ុន្តែប្រសិនបើយើងទៅមើលដោយផ្ទាល់ គឺយើងឃើញទិដ្ឋភាពកាន់តែច្បាស់ ហើយបញ្ហាកាន់តែអាចដោះស្រាយបានច្បាស់។ ដូច្នេះហើយទើបខ្ញុំធ្វើការស្នើសុំភ្លាមៗ សុំឲ្យមានការពិនិត្យមើលផ្ទាល់នៅទីតាំង។

សាក្សីក៏បានផ្តល់សក្ខីកម្មអំពីការសម្លាប់ ការធ្វើទារុណកម្មនៅទីតាំងនោះផងដែរ។ ហើយមានសាក្សីជាសន្តិសុខមួយរូបដែលគាត់ថាគាត់មិនបានឃើញ មិនបានមើលឃើញអ្វីទាំងអស់។ ដូច្នេះហើយយើងឃើញថាសេណារីយ៉ូទាំងពីរនេះ វាហាក់ដូចជាមិនស៊ីចង្វាក់ជាមួយគ្នាទាល់តែសោះ។ ខ្ញុំគិតថា ខ្ញុំបានបញ្ជាក់ឡើងវិញរួចមកហើយលើអ្វីដែលខ្ញុំចង់និយាយ ប៉ុន្តែនៅមានបញ្ហាមួយទៀតដែលពាក់ព័ន្ធផងដែរទៅនឹងបញ្ហានេះ គឺការស៊ើបអង្កេតដោយអង្គជំនុំជម្រះសាលាដំបូង ព្រោះយើងមិនអាចធ្វើការស៊ើបអង្កេតបានទេ ឧទាហរណ៍ដូចជា ចេតិយនៅៗទីតាំងនុំង ដែលជាចេតិយដែលមានលលាដ៍ក្បាលអ្នកដែលគេចោទប្រកាន់ថាត្រូវបានសម្លាប់នៅទីនោះ។ ដូច្នេះ យើងអាចទៅមើលពិនិត្យមើល ថាតើមានលលាដ៍ក្បាលប៉ុន្មាននាក់។ នៅពេលនោះយើងអាចដឹងថា -- វាជាចំណុចមួយដែលអាចបង្ហាញថាមានមនុស្សប៉ុន្មាននាក់ដែលត្រូវបានសម្លាប់នៅក្រាំងតាចាន់។

[១៥:៥៧:១៤]

ហើយទី២ ថាតើក្រាំងតាចាន់ គឺជាកន្លែងកប់សាកសពឬក៏អត់ ក៏ដូចជា បានន័យថាអ្វីៗដែលយើងដឹងនេះ គឺយើងមិនអាចធ្វើការពិនិត្យមើលឲ្យច្បាស់លាស់នោះទេ។ នៅពេលដែលយើងចុះទៅពិនិត្យមើលដោយមានការអមដំណើរដោយអាជ្ញាធរមូលដ្ឋាន យើងអាចនឹងទទួលបានចម្លើយច្បាស់។

ហេតុផលសំខាន់មួយទៀត ដែលយើងបានស្នើ ដែលៗយើងស្នើនេះ គឺថាតាមបទពិសោធន៍របស់យើង ហើយខាងព្រះរាជអាជ្ញាក៏ប្រហែលជាស្របខាងខ្ញុំ គឺថានៅពេលដែលយើងចុះទៅដោយផ្ទាល់ យើងដើរមើលឃើញទីតាំង ការដ្ឋាន ក៏ដូចជាអគារនានា។ យើងនឹងឃើញភាពខុសគ្នាខ្លាំង។ នៅពេលនុង យើងនឹងអាចធ្វើការវាយតម្លៃដែលបានត្រឹមត្រូវ នៅពេលដែលយើងទៅដល់ផ្ទាល់។

និយាយឲ្យពិតទៅ គឺជា -- អង្គជំនុំជម្រះ ត្រឹមត្រូវ និយាយបានត្រឹមត្រូវ ព្រោះថាមានរូបភាពមានការគូរ ក៏ដូចជាមានការបញ្ជាក់ផ្សេងៗ ប៉ុន្តែយើងត្រូវស្វែងរកការពិត។ ដូច្នេះហើយ គួរតែអង្គជំនុំជម្រះធ្វើការសម្រេចចិត្តនៅពេលដែលបានទៅមើលផ្ទាល់ ដោយមានការអមដំណើរដោយភាគីនានា។

**ប្រធានអង្គជំនុំ៖**

អរគុណ។ សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមបន្ថែមបន្តិចទៅនឹងអ្វីដែលខ្ញុំបានលើកឡើងកាលពីមុនហើយ។ ជាគោលការណ៍ វាជាការគួរឲ្យចាប់អារម្មណ៍ណាស់ ដែលតុលាការចុះទៅបែបនេះ។ វាមានបញ្ហាផ្សេងៗជាច្រើន។ ទី១ យើងមានការកំណត់ទី -- យើងមានរបាយការណ៍កំណត់ទីតាំងអត្តសញ្ញាណរួចហើយដែលមាននៅក្នុងសំណុំរឿង ហើយមានដូចជាសព្វជ្រុងជ្រោយទៅហើយ។ វាមានទិន្នន័យ ជី.ភី.អេសមានរូបថត ដែលបានភ្ជាប់ទៅក្នុងឯកសារនោះ ហើយយើងមានប្លង់ដែលផ្អែកទៅលើកន្លែងផ្សេងៗដែលចង្អុលបង្ហាញដោយសាក្សី ដែលបាននាំ ឬក៏ដើមបណ្ដឹងរដ្ឋប្បវេណីដែល -- ដើមបណ្ដឹងរដ្ឋប្បវេណីដែលបាននាំអ្នកស៊ើបអង្កេតទៅ។ ដូច្នេះ ខ្ញុំកត់សម្គាល់ឃើញថា មេធាវីការពារក្ដីក៏បានចង្អុលបង្ហាញថា ប្លង់ហ្នឹងគួរឲ្យចាប់អារម្មណ៍ណាស់។ ហើយនៅពេលសវនាការ ក៏គាត់បានប្រើប្រាស់ប្លង់ដែលរៀបចំដោយអ្នកយាមនៅទីនោះដែរ។ ដូច្នេះ តាមរយៈរូបថតទាំងអស់ហ្នឹង យើងអាចយល់ច្បាស់ហើយ ពីព្រោះដើមបណ្ដឹងរដ្ឋប្បវេណីគាត់បានចង្អុលបង្ហាញទីតាំងមួយចំនួន ហើយឥឡូវនេះលែងមានហើយទីតាំងនុំង។ ហើយយើងឃើញមានស្លាកស្នាមរណ្ដៅ ហើយចំពោះអគារអត់មានទៀតទេ។ អ៊ីចឹង យើងចាំបាច់អីទៅទៀត។ អគារដែលបានសាងសង់ក្រោយមកទៀតនេះ គឺជាអគារដែលមេធាវីការពារក្ដី

កំពុងតែនិយាយ ក៏ប៉ុន្តែប្រហែលជាពេលហ្នឹងអត់មានទេអគារទាំងអស់ហ្នឹង។ អ៊ីចឹង ដូចជាយើងមិនមានចាំបាច់អីត្រូវចុះទៅចំណាយពេលអង្គជំនុំជម្រះទៅពិនិត្យមើលអគារថ្មីដែលសង់ក្រោយមកនោះទេ ហើយចំពោះរណ្ដៅនោះ មេធាវីការពារក្ដី នួន ជា បាននិយាយថា ខ្លួនមិនអាចស្រមៃមើលថា តើសាកសព១៥០០០ អាចកប់នៅក្នុងនោះបាន។ ខ្ញុំគិតថា យើងបានដឹងទាំងអស់គ្នាហើយថា សក្ខីកម្មរបស់សាក្សីនោះគាត់បាននិយាយថា សាកសពហ្នឹងគឺថា មានការជញ្ជូនចេញទៅក្រៅពីក្រៅរបងទី១នោះ។

[១៦:០០:៥៩]

ចំណុចមួយផ្សេងទៀត គឺពាក់ព័ន្ធទៅនឹងភាពអាចប្រមើលមើលបានអំពីកន្លែងសម្លាប់មនុស្ស កន្លែងសួរចម្លើយ យើងដឹងហើយថាអគារទាំងអស់ហ្នឹងលែងមានទៀតហើយ ហើយដើមឈើហ្នឹងក៏មិនមែនដើមឈើនៅសម័យហ្នឹងទៀតដែរ។ អ៊ីចឹង យើងដូចជាមិនគួរអីទៅមើលទេ ព្រោះថាអ្វីៗវាថ្មីទៅហើយ ហើយយើងក៏មានរបាយការណ៍ដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេតរួចទៅហើយ ប្រសិនបើចាំបាច់ត្រូវទៅមើលកន្លែងទាំងអស់នុ៎ង យើងគិតថាដូចជាមិនមានតម្លៃបន្ថែមអីទៀតទេក្នុងការចុះទៅមើលទីតាំងឧក្រិដ្ឋកម្មទាំងអស់ហ្នឹង ពីព្រោះថាអ្វីៗយើងមាននៅក្នុងរបាយការណ៍យើងរួចទៅហើយ។ សូមអរគុណ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អរគុណសហព្រះរាជអាជ្ញារង។ សូមអញ្ជើញសហព្រះរាជអាជ្ញាអន្តរជាតិនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី -- មេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណី។ បើកក្បាលមីក្រូហ្វូន។

[១៦:០២:១៨]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សុំអធ្យាស្រ័យលោកប្រធាន។ សូមអរគុណលោកប្រធាន។ យើងមិនមានឱកាសច្រើនក្នុងការនិយាយពាក់ព័ន្ធទៅនឹងសំណើដែលមេធាវី កូប៉េ បានលើកឡើងនៅក្នុងសវនាការនោះទេ។ ចំពោះយើង យើងជំទាស់ទៅនឹងការចុះទៅអង្កេតនេះ យើងគិតថាវាហួសពេលទៅហើយ។ នៅក្នុងសំណុំរឿងយើងមានការស៊ើបអង្កេតអស់រួចរាល់អស់ទៅហើយ។ ហើយនៅក្នុងឱកាសនោះនោះ មេធាវី នួន ជា ក៏គាត់មានឱកាសក្នុងការស្នើសុំការចុះទៅពិនិត្យមើលបែបហ្នឹង គួរតែធ្វើតាំងពីពេលហ្នឹងមកហើយ ប៉ុន្មានឆ្នាំមកហើយ។ ឥឡូវយើងកំពុងតែជំនុំជម្រះទៅហើយ អ៊ីចឹងការចុះទៅស៊ើបអង្កេតហ្នឹងគឺត្រូវតែបង្ហាញពីធាតុផ្សំថ្មីពាក់ព័ន្ធទៅនឹងការស៊ើបអង្កេត ដើម្បីអនុញ្ញាតឲ្យអង្គជំនុំជម្រះអាចចុះទៅពិនិត្យបាន។ គឺមិន

ហើយជាចុងក្រោយនោះ សហព្រះរាជអាជ្ញាបានបញ្ជាក់រួចទៅហើយ យើងៗបានទៅផ្ទាល់ទៅក្រាំងតាចាន់។ យើងអាចបញ្ជាក់បានគឺថា អត់មានអគារដើមទេគឺគេមានគម្រោងរបស់អង្គការសហប្រជាជាតិ -- យុវសន្តិភាពដែលបានសាងសង់អគារថ្មីៗនៅកន្លែងហ្នឹង។ អ៊ីចឹង នៅពេលដែលយើងចុះទៅអត់មានអគារដើម មានតែអគារថ្មី ដូចជាអត់មានពាក់ព័ន្ធអីទេនៅក្នុងដំណាក់កាលនៃការជំនុំជម្រះនេះ។

ដូច្នេះយើងត្រូវតែថ្លឹងថ្លែងរវាងការចង់បង្ហាញការពិត ហើយនិងទម្ងន់នៃការចុះទៅស៊ើបអង្កេតនៅទីកន្លែងហ្នឹង យើងត្រូវមានសហព្រះរាជ -- យើងត្រូវចំណាយពេលមិនមែនតែ១ថ្ងៃទេ។ យើងមានតាំងពីក្រឡាបញ្ជី មានចៅក្រម មានភាគីចុះទៅច្រើនណាស់។ អ៊ីចឹង ដូចជាអត់ -- វាផ្ទុយទៅនឹងការលាតត្រដាងការពិតហើយ នៅពេលដែលយើងចុះទៅដោយអត់មានអគារដើមនោះ។ ដូច្នេះ នៅក្នុងសំណុំរឿងព្រហ្មទណ្ឌធម្មតាវាតែងតែមានការខ្វែងគំនិតគ្នា វាតែងតែមានសាក្សីនិយាយផ្ទុយគ្នាទៅនឹងអ្នកឃាម ឬក៏ឃាតករ។ វាជារឿងធម្មតាទេ ហើយអង្គជំនុំជម្រះជាអ្នកពិនិត្យថា អ្នកណានិយាយត្រូវ អ្នកណានិយាយខុស។ អ៊ីចឹងហើយជាតួនាទីរបស់អង្គជំនុំជម្រះ។ ដូច្នេះនៅពេលដែលយើងនិយាយថាមានសេណារីយ៉ូខ្វែងគំនិតគ្នាពាក់ព័ន្ធនឹងចំណុចនេះ យើងមិនបាន -- វាមិនមែនជាមូលហេតុដែលតម្រូវឲ្យយើងចុះទៅពិនិត្យផ្ទាល់នោះទេ។ ពួកគាត់ៗអាចធ្វើបាននៅពេលស៊ើបអង្កេត ឥឡូវនេះហួសពេលហើយ។ បើយើងទៅក្រាំងតាចាន់ដោយផ្ទាល់នោះ អ៊ីចឹងចំណុចផ្សេងទៀតក៏យើងគួរតែទៅដែរ ដូចជានៅកំពង់ឆ្នាំង នៅកន្លែងផ្សេងអីជាដើមនោះ បើសិនបើយើងបង្កើតយុត្តិសាស្ត្រមួយដែលថាភាគីទៅកន្លែងណាមួយនោះ យើងត្រូវទៅកន្លែងផ្សេងទៀត។ អ៊ីចឹង បើអ៊ីចឹងគឺថាវាធ្វើឲ្យយើងទៅមួយកន្លែងត្រូវ -- ពេលដែលមានពាក់ព័ន្ធនឹងកន្លែងផ្សេងទៀត ត្រូវចុះទៅទៀតបន្តិចៗម្តង ចុះទៅរហូតអ៊ីចឹងវាអត់មានប្រយោជន៍អីទេ។

[១៦:០៥:២០]

**ប្រធានអង្គជំនុំ៖**

ខៀវ សំផន ក្រៅពីការគាំទ្រពីលើកមុន មានអីបន្ថែមទេ?

**លោក អាកឡូវ វ៉ែកកែន៖**

យើងគាំទ្រចំពោះការចុះទៅពិនិត្យទីតាំង ហើយចំពោះបញ្ហារណ្តៅហ្នឹង ខ្ញុំយល់ដែរថាវាពិតជាមានការលំបាកហើយ យើងប្រហែលជាទៅមើលមិនមានឃើញអីទេ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណនូវរាល់មតិយោបល់ដែលបញ្ចេញដោយភាគីដទៃទៀតពាក់ព័ន្ធទៅលើសំណើសុំរបស់មេធាវីការពារក្តី នួន ជា ដែលសុំឱ្យអង្គជំនុំជម្រះចុះទៅពិនិត្យកន្លែងកើតហេតុ គឺទីតាំងសម្លាប់មនុស្សនៅក្រាំងតាចាន់នេះ។ ហើយអង្គជំនុំជម្រះនឹងពិនិត្យសម្រេចលើសំណើនេះនាពេលខាងមុខឆាប់ៗនេះ។

ហើយជាបន្តទៅនេះ អង្គជំនុំជម្រះសូមជម្រាបជូនភាគីនិងសាធារណជនថា សវនាការនៅថ្ងៃ -- នៅសប្តាហ៍ក្រោយនេះ នៅថ្ងៃចន្ទ អង្គជំនុំជម្រះនឹងបន្តស្តាប់សក្ខីកម្មសាក្សី នុត នូវ អង្គជំនុំជម្រះបានជម្រាបជូនរួចហើយអម្បាញ់មិញនេះ។ ហើយថ្ងៃបន្តបន្ទាប់ទៀត នៅក្នុងសប្តាហ៍ក្រោយនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មមួយចំនួនដែលសមស្រប ដែលមានឈ្មោះនៅក្នុងកាលវិភាគសវនាការដែលអង្គជំនុំជម្រះជម្រាបជូនភាគីរួចមកហើយ នៅក្នុងនោះគឺសាក្សីដែលមានរហស្សនាម 2-TCW-860 និង TCW-822។ ហើយអង្គជំនុំជម្រះក៏នឹងជម្រាបជូនភាគីតាមរយៈអ៊ីម៉ែល ដោយមន្ត្រីច្បាប់ជាន់ខ្ពស់នៅរសៀលនេះផងដែរ ដើម្បីជាការបន្ថែមលើការជូនដំណឹងនេះ។

[១៦:០៧:០៣]

ហើយមួយទៀត អង្គជំនុំជម្រះសូមចំពោះ -- សូមបញ្ជាក់និងជម្រាបជូនភាគី ជាពិសេសម្ចាស់សំណើគឺមេធាវីការពារក្តី នួន ជា ចំពោះសំណើសុំរបស់លោកមេធាវីការពារក្តី នួន ជា សុំឱ្យអង្គជំនុំជម្រះផ្អាកធ្វើសវនាការរយៈពេល៦សប្តាហ៍ ដើម្បីខ្លួនបានមានលទ្ធភាពអាចពិនិត្យវិភាគៗឯកសារថ្មីៗ អាន មានលទ្ធភាពអាន ពិនិត្យ វិភាគឯកសារថ្មីៗ ដែលបានដាក់ដោយសហព្រះរាជអាជ្ញា គឺបណ្តាឯកសារយកចេញពីសំណុំរឿង០០៣ និង០០៤ មកដាក់នៅក្នុងសំណុំរឿង០០២/០២ និងបញ្ហាពាក់ព័ន្ធទៅនឹងសំណើនេះ អង្គជំនុំជម្រះនឹងចេញសេចក្តីសម្រេចលើសំណើនេះនៅក្នុងសប្តាហ៍ក្រោយ។ នេះសូមជ្រាប។ ដោយសារស្ថានភាពនៃបញ្ហាគឺមានលក្ខណៈស្មុគស្មាញដោយមានការពាក់ព័ន្ធ ដូចខ្ញុំបានជម្រាបពីដើមសប្តាហ៍អ៊ីចឹង គឺពាក់ព័ន្ធផ្ទាល់ទៅនឹងអង្គភាពសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលមានបញ្ហាពាក់ព័ន្ធមួយចំនួន គឺអង្គជំនុំជម្រះបានធ្វើសំណើសុំដោយផ្អែកលើសំណើភាគី។ ដូច្នេះ គឺមិនទាន់មានភាពអីច្បាស់លាស់នៅឡើយទេ។ ហើយឯកសារហ្នឹងក៏មានបញ្ហា ចំនួនហ្នឹងក៏វាមានបញ្ហាកើនឡើងច្រើនដែរ។ ដូច្នេះ អង្គជំនុំជម្រះនឹងពិនិត្យពីបញ្ហានេះនៅក្នុងចុងសប្តាហ៍នេះ ហើយនិងសម្រេចចេញសេចក្តីសម្រេចជូនភាគីជ្រាបនៅក្នុងសប្តាហ៍ក្រោយ។ នេះសូមភាគីជ្រាប។

មានបញ្ហាអីទេ?

[១៦:០៨:៤៧]

បាទ ហើយសវនាការថ្ងៃនេះដល់ពេលឈប់សម្រាកហើយ ហើយអង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃចន្ទ ទី១៦ ខែមីនា ឆ្នាំ ២០១៥ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ។ ហើយដូចជម្រាបអ៊ីចឹង គឺសប្តាហ៍នៅថ្ងៃចន្ទនេះ អង្គជំនុំជម្រះនឹងបន្តស្តាប់សក្ខីកម្មសាក្សី នុត នូវ ។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនពួកគាត់ទាំងពីររូបត្រឡប់មកចូលរួមសវនាការវិញនៅថ្ងៃចន្ទ ទី១៦ ខែមីនា ឆ្នាំ២០១៥ ដើមសប្តាហ៍ក្រោយនេះឲ្យបានមុនម៉ោងប្រាំបួន។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:០៩ នាទី)*